**សាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច**

**Université Royale de Droit et des Sciences Economiques**

**Royal University of Law and Economics**

# សារណាបញ្ចប់ការសិក្សា

# ដំណើរការនៃការគ្រប់គ្រងរដ្ឋបាលស្រុក កៀនស្វាយ

# (២០២០ - ២០២៤)

ស្រាវជ្រាវពីថ្ងៃ០៨ ខែមេសា ឆ្នាំ២០២៤ ដល់ថ្ងៃ១០ ខែសីហា ឆ្នាំ២០២៤

ស្រាវជ្រាវដោយ

និស្សិតឈ្មោះ៖ កញ្ញា **គឹមសឿន រស្មី**

លោក **ឡុង ពិសាល**

ណែនាំដោយ

បណ្ឌិត **ជា គឹមឡេង**

ថ្នាក់បរិញ្ញាបត្រ **គ្រប់គ្រងធុរកិច្ច**

ជំនាន់ទី ០៨

ឆ្នាំចូលសិក្សា ២០២០

ឆ្នាំសរសេរសារណា ២០២៤

# សេចក្ដីថ្លែងអំណរគុណ

នាងខ្ញុំឈ្មោះ **គឹមសឿន រស្មី** និងខ្ញុំបាទឈ្មោះ **ឡុង ពិសាល** ដែលជានិស្សិតថ្នាក់បរិញ្ញាបត្រគ្រប់គ្រងធុរកិច្ចនៃសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច។ ពួកយើងមានសេចក្ដីសោមនស្សរីករាយក្រៃលែងដែលមានឱកាសក្នុងការសរសេរសារណាបញ្ចប់ថ្នាក់បរិញ្ញាបត្រក្រោមប្រធានបទ "**ដំណើរការនៃការគ្រប់គ្រងរដ្ឋបាលថ្នាក់ស្រុក**" ។ ក្នុងការសរសេរសារណាមួយនេះវាជាសមិទ្ធផលពីការខិតខំប្រឹងប្រែងរៀនសូត្រ ស្រាវជ្រាវ តស៊ូ ពុះពារ គ្រប់ឧបសគ្គ រួមទាំងការលះបង់របស់សាស្ត្រាចារ្យ។

យើងខ្ញុំទាំងពីរនាក់ សូមរំលឹកដល់គុណរបស់លោកអ្នកមានគុណរួមមាន **មាតា បិតា** ដែលលោកបានផ្ដល់កំណើត ព្រមជាមួយការចិញ្ចឹមបីបាច់ថែរក្សាទូន្មានប្រៀនប្រដៅប្រកបដោយព្រហ្មវិហារធម៌ និងសម្រក់គ្រប់ដំណក់ញើសឈាម មិនខ្លាចនឿយហត់ឆ្លងកាត់នូវការលំបាកគ្រប់បែបយ៉ាងក៏មិនដែលត្អូញត្អែរ គឺដើម្បីតែបញ្ជូនបុត្រាបុត្រី មកបន្តថ្នាក់ឧត្ដមសិក្សា ក្នុងការក្រេបជញ្ជក់នូវចំណេះដឹង ដើម្បីក្លាយជារូបវន្តបុគ្គលពោរពេញដោយ ចំណេះដឹង សីលធម៌ និងគុណធម៌។

ជាបន្តយើងខ្ញុំសូមសម្ដែងនូវសេចក្ដីអំណរគុណយ៉ាងក្រៃលែងចំពោះ **ឯកឧត្ដមបណ្ឌិតសាកលវិទ្យាធិការ សាកលវិទ្យាធិការរង ព្រឹទ្ធបុរស ព្រឹទ្ធបុរសរង សាស្ត្រាចារ្យ ព្រមទាំងបុគ្គលិកទាំងអស់** នៃសកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច ដែលបានយកចិត្តទុកដាក់បណ្ដុះបណ្ដាលនូវចំណេះដឹងទៅកាន់យុវជនកម្ពុជាពីមួយជំនាន់ទៅមួយជំនាន់ ដើម្បីធានាបាននូវធនធានមនុស្សពិតប្រាកដដែលជាសរសរទ្រូង និងជាកម្លាំងចលករសម្រាប់ ការអភិវឌ្ឍសង្គមប្រកបដោយនិរន្តរភាព ។

យើងខ្ញុំសូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅចំពោះសាស្ត្រាចារ្យ បណ្ឌិត **ជា គឹមឡេង** ដែលបានចំណាយពេលវេលាដ៏មានតម្លៃក្នុងការបង្ហាត់បង្រៀន ណែនាំទូន្មាន កែតម្រូវ បង្ហាញគន្លឹះព្រមទាំងការផ្ដល់ឱវាទដ៏មានតម្លៃ តាំងពីពេលចាប់ផ្ដើមរហូតដល់បានបញ្ចប់នូវសារណារបស់យើងខ្ញុំទាំងពីររូប។

ជាចុងបញ្ចប់យើងខ្ញុំទាំងពីររូបសូមគោរពជូនពរដល់មាតា បិតា គ្រូបាអាចារ្យ និងលោកអ្នកមានគុណទាំងឡាយ សូមមេត្តាទទួលដោយសេចក្ដីអនុគ្រោះឱ្យជួបតែសេចក្ដីសុខសេរីសុភមង្គល ក្បេមក្សាន្តចុំច្រើនរុងរឿង ជាដ៏រាបតរៀងទៅ។

# អារម្ភកថា

សាលាស្រុកគឺជាការិយាល័យធ្វើការរបស់ក្រុមប្រឹក្សាស្រុក និងគណៈអភិបាលស្រុកដែលត្រូវបើកធ្វើការ តាមពេលម៉ោងធ្វើការរបស់រដ្ឋ។ ក្នុងអំឡុងពេលម៉ោងធ្វើការងារ ប្រជាពលរដ្ឋមានសិទ្ធិ ៖

- ធ្វើទំនាក់ទំនង និងធ្វើការងារជាមួយក្រុមប្រឹក្សាស្រុក និងគណៈអភិបាលស្រុក
- ទទួលព័ត៌មានអំពីសំណើ និងការងារនានាពីរដ្ឋបាលស្រុក
- ចូលរួមយោបល់ ឬសំណូមពរលើបញ្ហាណាមួយ។

នៅថ្ងៃឈប់សម្រាកក្រុមប្រឹក្សាស្រុកនិងគណៈអភិបាលស្រុកត្រូវអោយមន្ត្រី បុគ្គលិកនៃរដ្ឋបាលរបស់ខ្លួនក្នុងចំនួនសមស្របប្រចាំការ ដើម្បីទទួលឬដោះស្រាយសំណូមពរបន្ទាន់ពិសេសនានា។

រដ្ឋបាលស្រុកត្រូវធ្វើជាម្ចាស់ និងទទួលខុសត្រូវចាត់ចែងលើរាល់លិខិតស្នាម ឯកសារទាំងអស់ដែលបានទទួលត្រឹមត្រូវស្របតាមច្បាប់ជាធរមាន។ រដ្ឋបាលស្រុកក៏ជាម្ចាស់ និងទទួលខុសត្រូវលើរាល់លិខិតស្នាម ឯកសារនានា ដែលបានរៀបចំឡើងដោយក្រុមប្រឹក្សាស្រុកឬក្នុងនាមក្រុមប្រឹក្សាស្រុកនិងដោយគណៈអភិបាលស្រុកក្នុងនាមរដ្ឋ ព្រមទាំងជាម្ចាស់លើឧបករណ៍ មធ្យោបាយ និងសម្ភារៈនានានៃរដ្ឋបាលរបស់ខ្លួន។ ដូច្នេះហើយទើបរដ្ឋបាលស្រុកត្រូវធានាទុកដាក់ ឯកសារ លិខិតស្នាម ឧបករណ៍ មធ្យោបាយ និងសម្ភារៈនានានៃរដ្ឋបាលរបស់ខ្លួនឱ្យបានត្រឹមត្រូវតាមការកំណត់ មានសណ្តាប់ធ្នាប់ល្អ និងគង់វង្ស។

ចំពោះត្រារដ្ឋបាលស្រុកត្រូវបានប្រគល់ឱ្យនាយករដ្ឋបាលសាលាស្រុករបស់ខ្លួន ដើម្បីទទួលខុសត្រូវនិងគ្រប់គ្រងសម្រាប់ក្រុមប្រឹក្សាស្រុក និងគណៈអភិបាលស្រុកប្រើប្រាស់។

រដ្ឋបាលស្រុកត្រូវរៀបចំឱ្យមានក្តារព័ត៌មានសាធារណៈនៅមុខសាលាស្រុករបស់ខ្លួន ដើម្បីអោយសាធារណជនអាចពិនិត្យមើលបានយ៉ាងងាយស្រួល។ ក្តារព័ត៌មានសាធារណៈនេះ ត្រូវសរសេរ ឬបិទផ្សាយសេចក្តីជូនដំណឹងជាផ្លូវការដល់សាធារណជន។ ការសរសេរ និងការបិទផ្សាយនេះត្រូវរក្សាទុកឱ្យបានយ៉ាងតិចដប់ថ្ងៃ។ ក្រៅពីក្តារព័ត៌មានសាធារណៈនៅមុខសាលាស្រុក ក្រុមប្រឹក្សាស្រុកត្រូវរៀបចំក្តារព័ត៌មានសាធារណៈនៅទីសាធារណៈដទៃទៀត ក្នុងស្រុករបស់ខ្លួនតាមការចាំបាច់។ ក្រុមប្រឹក្សាស្រុកត្រូវរកមធ្យោបាយផ្សព្វផ្សាយព័ត៌មានផ្សេងៗទៀត ដើម្បីជូនដំណឹងអំពីកិច្ចការនានានៃរដ្ឋបាលរបស់ខ្លួនដល់ប្រជាពលរដ្ឋ។

# មាតិកា

**ទំព័រ**

**បញ្ជីអក្សរកាត់**......vi

**បញ្ជីរូបភាព**......vii

**សេចក្ដីផ្ដើម**......១

១. លំនាំបញ្ហានៃការសិក្សាស្រាវជ្រាវ ......១

២. ចំណោទបញ្ហានៃការសិក្សាស្រាវជ្រាវ ......១

៣. គោលបំណងនៃការស្រាវជ្រាវ......២

៤. ទំហំ និងដែនកំណត់នៃការស្រាវជ្រាវ ......២

៥. សារសំខាន់នៃការសិក្សាស្រាវជ្រាវ ...... ៣

៦. វិធីសាស្ត្រនៃការស្រាវជ្រាវ ...... ៣

៦.១ ឧបករណ៍ស្រាវជ្រាវ ...... ៣

៦.២ ទម្រង់នៃការស្រាវជ្រាវ ......៤

៧. រចនាសម្ព័ន្ធនៃការស្រាវជ្រាវ ......៤

**ជំពូក ១**

**ទិដ្ឋភាពទូទៅនៃការគ្រប់គ្រងរដ្ឋបាលថ្នាក់ជាតិ**

១.១. សាវតារ......៦

១.២.កំណែទម្រង់រដ្ឋបាលនៅប្រទេសកម្ពុជា......៦

១.២.១.កំណែទម្រង់តាមបែបមជ្ឈការ......៦

១.២.២. កំណែទម្រង់តាមបែបវិមជ្ឈការ ...... ៧

១.២.៣. កំណែទម្រង់តាមបែបវិសហមជ្ឈការ...... ៧

១.២.៤. មូលហេតុនៃការអនុវត្តកំណែទម្រង់......៨

១.២.៥. គោលដៅនៃកំណែទម្រង់......៩

១.២.៦. ក្របខ័ណ្ឌគោលនយោបាយ និងច្បាប់គាំទ្រកំណែទម្រង់...... ១០

១.២.៦.១. ក្របខ័ណ្ឌគោលនយោបាយ ..... ១០
១.២.៦.២. ក្របខ័ណ្ឌច្បាប់ ..... ១១
១.៣.លិខិតរដ្ឋបាល ..... ១៣
១.៣.១. និយមន័យ ..... ១៣
១.៣.២. ប្រភេទនៃលិខិតរដ្ឋបាល ..... ១៣
១.៣.២. ទម្រង់នៃលិខិតរដ្ឋបាល ..... ១៦
១.៤.ការបង្កើតរដ្ឋ និងលិខិតបទដ្ឋាន ..... ១៨
១.៤.១.ការបង្កើតរដ្ឋ ..... ១៨
១.៤.២.លិខិតបទដ្ឋាន ..... ១៩
១.៤.២.១.និយមន័យ ..... ១៩
១.៤.២.២.ប្រភេទលិខិតបទដ្ឋាន ..... ២០
១.៥.ប្រព័ន្ធគ្រប់គ្រងរដ្ឋបាលថ្នាក់ជាតិនិងថ្នាក់ក្រោមជាតិ ..... ២០
១.៥.១.រដ្ឋបាលថ្នាក់ជាតិ ..... ២០
១.៥.២.រដ្ឋបាលថ្នាក់ក្រោមជាតិ ..... ២៦
១.៥.២.១. គោលការណ៍ ..... ២៦
១.៥.២.២. ការរៀបចំប្រព័ន្ធអភិបាលកិច្ចនៅថ្នាក់ក្រោមជាតិ ..... ២៩
១.៦.ការដោះស្រាយវិវាទ ..... ៣២
១.៦.១.ការដោះស្រាយវិវាទតាមរយៈតុលាការ ..... ៣២
១.៦.២.ការដោះស្រាយវិវាទក្រៅប្រព័ន្ធតុលាការ ..... ៣៣

## ជំពូក ២

## ស្ថានភាពនៃការគ្រប់គ្រងរដ្ឋបាលស្រុកអៀនស្វាយ

២.១. ស្ថានភាពទីតាំងភូមិសាស្ត្រនិងប្រជាសាស្ត្រ ..... ៣៥
២.១.១ ទីតាំងភូមិសាស្ត្រ ..... ៣៥
២.១.២.ស្ថានភាពប្រជាសាស្ត្រ ..... ៣៦
២.២.ស្ថានភាពសេដ្ឋកិច្ច ..... ៣៦
២.៣.ស្ថានភាពសង្គមកិច្ច ..... ៣៧

២.៣.១.វិស័យអប់រំ ...................................................................................................... ៣៧

២.៣.២.វិស័យសុខាភិបាល ........................................................................................... ៣៨

២.៣.៣.ស្ថានភាពយេនឌ័រ ................................................................................................ ៣៨

២.៣.៤.ភាពក្រីក្រ .................................................................................................................. ៤០

២.៣.៥. សាសនា ..................................................................................................................... ៤០

២.៣.៦. វិស័យអនាម័យនិងទឹកស្អាត .................................................................................. ៤០

២.៣.៧. ការរៀបចំដែនដី នគរូបនីយកម្ម សំណង់ និងភូមិបាល ............................................ ៤១

២.៤.រចនាសម្ព័ន្ធរបស់សាលាស្រុកកៀនស្វាយ .................................................................... ៤១

២.៤.១. តួនាទី ភារកិច្ចនិងអ្នកនាំរបស់សាលាស្រុកកៀនស្វាយ ............................................ ៤១

២.៤.២.អ្នកដឹកនាំរបស់សាលាស្រុកកៀនស្វាយ .................................................................. ៤៣

២.៤.៣.ការិយាល័យចំណុះរដ្ឋបាលស្រុកកៀនស្វាយ ............................................................ ៤៤

២.៤.៤.ការគ្រប់គ្រង់ហិរញ្ញវត្ថុនិងទ្រព្យសម្បត្តិរបស់សាលាស្រុកកៀនស្វាយ ............................ ៤៥

២.៤.៤.១.គោលការណ៍ ....................................................................................................... ៤៥

២.៤.៤.២.ការគ្រប់គ្រងហិរញ្ញវត្ថុ ........................................................................................ ៤៥

២.៤.៤.៣.ការគ្រប់គ្រងទ្រព្យសម្បត្តិ .................................................................................... ៤៧

២.៤.៥.ផែនការអភិវឌ្ឍន៍រយៈពេលប្រាំឆ្នាំ ២០២០ - ២០២៤ .................................................... ៤៧

២.៤.៥.១.ផ្នែកសេដ្ឋកិច្ច .................................................................................................... ៤៧

២.៤.៥.២.ផ្នែកសង្គមកិច្ច .................................................................................................... ៤៨

២.៤.៥.៣.ផ្នែកធនធានធម្មជាតិ បរិស្ថាន ការបន្សាំ និងការប្រែប្រួលអាកាសធាតុ ......................... ៥០

២.៤.៥.៤.ផ្នែករដ្ឋបាល និងសន្តិសុខសណ្តាប់ធ្នាប់សាធារណៈ .................................................. ៥០

២.៤.៦.រចនាសម្ព័ន្ធរបស់រដ្ឋបាលស្រុក .................................................................................. ៥២

២.៥.ការចុះបញ្ជីកំណើតនិងសណ្តាប់ធ្នាប់សន្តិសុខសាធារណៈ ................................................... ៥៣

២.៥.១.ការចុះបញ្ជីកំណើត .................................................................................................... ៥៣

២.៥.២.សណ្តាប់ធ្នាប់សន្តិសុខសាធារណៈ ............................................................................... ៥៤

២.៦.ការគ្រប់គ្រងឯកសារ ...................................................................................................... ៥៤

២.៦.១.និយមន័យ ................................................................................................................. ៥៥

២.៦.២.អត្ថប្រយោជន៍........................................................................................................................ ៥៥
២.៦.៣.ប្រភេទឯកសារ ........................................................................................................................ ៥៥
២.៦.៣.ការរក្សាទុកឯកសារ........................................................................................................................ ៥៥

## ជំពូក ៣

## បញ្ហាប្រឈម យុទ្ធសាស្ត្រដំណោះស្រាយដើម្បីអភិវឌ្ឍរបស់ស្រុកកៀនស្វាយ និងគំហើញ

៣.១. និយមន័យ ........................................................................................................................៥៧
៣.២. បញ្ហាប្រឈម........................................................................................................................៥៧
៣.២.១. បញ្ហាប្រឈមវិស័យសេដ្ឋកិច្ច........................................................................................................................៥៧
៣.២.១.១.បញ្ហាប្រឈមវិស័យកសិកម្ម........................................................................................................................ ៥៨
៣.២.១.២.ស្ថានភាពដីស្រែចំការរបស់កសិករ........................................................................................................................ ៥៨
៣.២.១.៣.វិស័យសេវាកម្មផ្សេងៗ ........................................................................................................................ ៥៩
៣.២.១.៤.ការស្វែងរកការងារធ្វើក្រៅស្រុក........................................................................................................................ ៥៩
៣.២.២. បញ្ហាប្រឈមវិស័យសង្គមកិច្ច ........................................................................................................................ ៦០
៣.២.៣. បញ្ហាប្រឈមវិស័យអប់រំ........................................................................................................................ ៦០
៣.២.៤. បញ្ហាប្រឈមវិស័យសុខាភិបាល........................................................................................................................ ៦១
៣.២.៥. បញ្ហាប្រឈមវិស័យការគ្រប់គ្រងធនធានធម្មជាតិ ........................................................................................................................ ៦១
៣.២.៦. បញ្ហាប្រឈមវិស័យគ្រប់គ្រងរដ្ឋបាល និងសណ្តាប់ធ្នាប់សាធារណៈ ........................................................................................................................៦២
៣.២.៦.១. បញ្ហាប្រឈមវិស័យគ្រប់គ្រងរដ្ឋបាលសាធារណៈ ........................................................................................................................៦២
៣.២.៦.២.បញ្ហាប្រឈមសណ្តាប់ធ្នាប់សាធារណៈ........................................................................................................................៦២
៣.៣. យុទ្ធសាស្ត្រអភិវឌ្ឍរបស់ស្រុកកៀនស្វាយ........................................................................................................................៦២
៣.៣.១.យុទ្ធសាស្ត្រអភិវឌ្ឍសេដ្ឋកិច្ច ........................................................................................................................៦២
៣.៣.២.យុទ្ធសាស្ត្រអភិវឌ្ឍសង្គមកិច្ច........................................................................................................................៦៣
៣.៣.៣.យុទ្ធសាស្ត្រអភិវឌ្ឍធនធានធម្មជាតិ បរិស្ថាន និង ........................................................................................................................ ៦៤
៣.៣.៤.យុទ្ធសាស្ត្រអភិវឌ្ឍគ្រប់គ្រងរដ្ឋបាល និងសន្តិសុខ ........................................................................................................................ ៦៥
៣.៤. របបគំហើញ ........................................................................................................................ ៦៦
៣.៤.១. ចំណុចខ្លាំង ........................................................................................................................ ៦៦

៣.៤.២. ចំណុចខ្សោយ ............................................................................................................. ៦៦
**សេចក្តីសន្និដ្ឋាន និងអនុសាសន៍** ............................................................................................. ៦៨
**ឯកសារយោង**
**ឧបសម្ព័ន្ធ**

# បញ្ជីអក្សរកាត់

គ.ក.ស.កៈ គណៈកម្មាធិការពិគ្រោះយោបល់កិច្ចការស្ត្រី និងកុមារ

អនក្រ.បកៈ អនុក្រឹតប្រកាស

NGO: Non Governmental Organizations

OADR: Office for Alternative Dispute Resolution

# បញ្ជីរូបភាព

រូបភាពទី១ ៖ ផែនទីស្រុកកៀនស្វាយខេត្តកណ្ដាល.....៣៦
រូបភាពទី២ ៖ រចនាសម្ព័ន្ធរដ្ឋបាលស្រុកកៀនស្វាយ.....៥២
រូបភាពទី៣ ៖ រចនាសម្ព័ន្ធរដ្ឋបាលខេត្ត.....៥៣

# សេចក្តីផ្តើម

# សេចក្តីផ្តើម

## ១. លំនាំបញ្ហានៃការសិក្សាស្រាវជ្រាវ

បើយោងតាមភាពរីកចម្រើននៃសាកលភាវូបនីយកម្ម ការអប់រំក៏មានការប្រែប្រួលទៅតាមរបបនៃសង្គម និងសម័យកាលនីមួយៗផងដែរ។ ការអប់រំជាវិស័យមួយដ៏សំខាន់ក្នុងការបណ្តុះបណ្តាលចរិតលក្ខណៈ និងធនធានមនុស្ស ជាពិសេសដំណើរការអភិវឌ្ឍប្រទេសជាតិ និងការកាត់បន្ថយភាពក្រីក្រ។ នៅតាមស្ថាប័នរដ្ឋនិងឯកជនតែងតែមានការគ្រប់គ្រងគ្រប់ផ្នែកទាំងអស់ មិនថាគ្រប់គ្រងធនធានមនុស្សគ្រប់គ្រងហិរញ្ញវត្ថុ អង្គភាពគ្រប់គ្រងរដ្ឋបាល និងការគ្រប់គ្រងផ្សេងៗទៀតទៅតាមស្ថាប័ណ្ឌនីមួយៗ។ ការកសាងរដ្ឋបាលសាធារណៈឲ្យកាន់តែមានប្រសិទ្ធភាពក្នុងការឆ្លើយតប ជំនឿទុកចិត្ត និងដើម្បីប្រែក្លាយរដ្ឋបាលសាធារណៈឲ្យទៅជាអ្នកផ្តល់សេវាដ៏មានប្រសិទ្ធភាព ដែលបម្រើប្រជាជនកាន់តែល្អប្រសើរឡើង។ តាមរយៈយុទ្ធសាស្ត្រចតុកោណរបស់រាជរដ្ឋាភិបាល ការកែទម្រង់ទាំងនេះដោយផ្តោតការយកចិត្តទុកដាក់ទៅលើ ការបន្តពង្រីកវិសាលភាពនៃការអនុវត្តការិយាល័យច្រកចេញចូលតែមួយឲ្យមាននៅគ្រប់ក្រុង ស្រុក ខណ្ឌ ទូទាំងប្រទេស និងបន្តជម្រុញធ្វើប្រតិភូកម្មមុខងារឲ្យកាន់តែទូលំទូលាយថែមទៀត។

ក្រៅពីនេះទៅក៏នៅមានការអភិវឌ្ឍធនធានមនុស្ស និងស្ថាប័នរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ ព្រមទាំងការពង្រឹងតួនាទី និងការទទួលខុសត្រូវរបស់រដ្ឋបាលថ្នាក់ក្រោមជាតិក៏រាជរដ្ឋាភិបាល បានផ្តោតការយកចិត្តទុកដាក់ផងដែរ។ ទន្ទឹមនឹងនេះការបន្តផ្តល់សិទ្ធិអំណាចទៅដល់រដ្ឋបាលថ្នាក់ក្រោមជាតិ ក្នុងការគ្រប់គ្រងមន្ត្រីរាជការស៊ីវិលរបស់ក្រសួង ស្ថាប័ននានាដែល បំពេញការងារនៅថ្នាក់ក្រោមជាតិ ក៏ត្រូវពង្រឹងប្រសិទ្ធភាព ដើម្បីសម្របសម្រួលនូវរាល់សកម្មភាពរដ្ឋបាលសាធារណៈថ្នាក់ក្រោមជាតិថែមទៀតផង។

ដោយចង់ស្វែងយល់ពីរបៀបនៃការគ្រប់គ្រងរដ្ឋបាល និងការដោះស្រាយបញ្ហាប្រឈមនៅក្នុងមូលដ្ឋាន។ ហេតុដូច្នេះហើយទើបក្រុមយើងខ្ញុំជ្រើសរើសយកប្រធានបទ “**ដំណើរការនៃការគ្រប់គ្រងរដ្ឋបាលស្រុកកៀនស្វាយ**” ដែលជាផ្នែកមួយនៃរដ្ឋបាលថ្នាក់ក្រោមជាតិមកធ្វើសារណាបញ្ចប់ការសិក្សាថ្នាក់បរិញ្ញាបត្រ ដើម្បីចូលរួមអនុវត្តកំណែទម្រង់នេះអោយកាន់តែមានប្រសិទ្ធភាព។

## ២. ចំណោទបញ្ហានៃការសិក្សាស្រាវជ្រាវ

យើងសង្កេតឃើញពីសារៈសំខាន់និងភាពចាំបាច់នៅក្នុងរដ្ឋបាលទើបធ្វើអោយមានការសិក្សស្រាវជ្រាវទៅលើប្រធានបទ “**ដំណើរការនៃការគ្រប់គ្រងរដ្ឋបាលថ្នាក់ស្រុកកៀនស្វាយ**” ដោយបានចោទជាសំណួរថា តើរដ្ឋបាលស្រុកកៀនស្វាយមានតួនាទីអ្វីខ្លះហើយគ្រប់គ្រងយ៉ាងដូចម្តេច? របាយការណ៍កម្មសិក្សាស្រាវជ្រាវនេះក្រុមយើងខ្ញុំនិងបកស្រាយយ៉ាងលម្អិតទៅតាមជំពូកនីមួយៗអោយបានក្បោះក្បាយ។

## ៣. គោលបំណងនៃការស្រាវជ្រាវ

គោលបំណងនៃការចុះកម្មសិក្សាស្រាវជ្រាវនេះគឺដើម្បីអនុវត្តការងារជាក់ស្តែងដែលផ្សាភ្ជាប់ទៅនិងទ្រឹស្តីនិងដំណើរការប្រចាំថ្ងៃរបស់រដ្ឋបាលស្រុកកៀនស្វាយ ក្នុងការផ្តល់អាជ្ញាប័ណ្ណផ្សេងៗ ឬសេវាកម្មផ្សេងៗទៀតជូនប្រជាពលរដ្ឋ។ ការសិក្សាស្រាវជ្រាវប្រធានបទ «**ដំណើរការនៃការគ្រប់គ្រងរដ្ឋបាលស្រុកកៀនស្វាយ**» មានគោលបំណងសំខាន់ៗជាច្រើនដូចជា ៖

- ស្ថានភាពទូទៅនៃការគ្រប់គ្រងរដ្ឋបាលរបស់ស្រុកកៀនស្វាយ
- សិក្សាតួនាទី ភារកិច្ច និងអ្នកដឹកនាំរបស់សាលាស្រុកកៀនស្វាយ
- ការរៀបចំយុទ្ធសាស្ត្រអភិវឌ្ឍដែនដី
- សិក្សាអំពីបញ្ហាប្រឈម និងយុទ្ធសាស្ត្រដំណោះស្រាយដើម្បីអភិវឌ្ឍរបស់សាលាស្រុកកៀនស្វាយ

## ៤. ទំហំ និងដែនកំណត់នៃការស្រាវជ្រាវ

ការចុះកម្មសិក្សានេះប្រព្រឹត្តទៅនៅរដ្ឋបាលស្រុកកៀនស្វាយនិងបានចុះអនុវត្តផ្ទាល់នៅការិយាល័យរដ្ឋបាល។ ការចុះកម្មសិក្សានេះបែងចែកជាបួនដំណាក់កាល គឺ

- ដំណាក់កាលទី១ ចាប់ពីថ្ងៃទី២០ ខែឧសភា ដល់ថ្ងៃទី២៤ ខែឧសភា ឆ្នាំ២០២៤ សិក្សាស្រាវជ្រាវឯកសារតាមការិយាល័យមួយចំនួន ចំណុះរដ្ឋបាលស្រុកកៀនស្វាយ
- ដំណាក់កាលទី២ ចាប់ពីថ្ងៃទី២៧ ខែឧសភា ដល់ថ្ងៃទី៣១ ខែឧសភា ឆ្នាំ២០២៤ សិក្សាស្រាវជ្រាវផ្តោតលើការងារការិយាល័យរដ្ឋបាល
- ដំណាក់កាលទី៣ ចាប់ពីថ្ងៃទី០៣ ខែមិថុនា ដល់ថ្ងៃទី០៧ ខែមិថុនា ឆ្នាំ២០២៤ សិក្សាស្រាវជ្រាវតួនាទី ភារកិច្ច និងអ្នកដឹកនាំរបស់សាលាស្រុកកៀនស្វាយ ការរៀបចំយុទ្ធសាស្ត្រអភិវឌ្ឍដែនដី សិក្សាអំពីបញ្ហាប្រឈម យុទ្ធសាស្ត្រដំណោះស្រាយដើម្បីអភិវឌ្ឍរបស់សាលាស្រុកកៀនស្វាយ និងគំហើញ
- ដំណាក់កាលទី៤ ចាប់ពីថ្ងៃទី១០ ខែមិថុនា ដល់ថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០២៤ សរសេររបាយការណ៍ និងត្រួតពិនិត្យក្រោមការសម្របសម្រួលពីប្រធានការិយាល័យ ។

របាយការណ៍កម្មសិក្សានេះគឺធ្វើការសិក្សាអំពីការបំពេញតួនាទី ភារកិច្ច របស់ការិយាល័យក្នុងអង្គភាពចំណុះរដ្ឋបាលស្រុក ជាពិសេសសិក្សាស៊ីជម្រៅលើការគ្រប់គ្រងរដ្ឋបាល ការផ្តល់អាជ្ញាបណ្ណអប់រំ សម្រាប់អនុញ្ញាតឱ្យ ដំណើរការសាលារៀនកម្រិតមត្តេយ្យសិក្សាឯកជន ទាំងកម្មវិធីជាតិ និងអន្តរជាតិ ឬដំណើរការថ្នាក់បណ្តុះបណ្តាលភាសាបរទេសវគ្គខ្លីៗតិចជាងមួយឆ្នាំ ដោយមិនលើកឡើងអំពីការបើកអាជីវកម្មកីឡា និងក្លឹប

ហាត់ប្រាណឡើយ។ ចំពោះអាជ្ញាបណ្ណអប់រំទទួលស្គាល់គ្រឹះស្ថានសិក្សា ឬច្រើនភូមិសិក្សាបញ្ចូលគ្នា(ទារកដ្ឋាន មត្តេយ្យសិក្សា និងបឋមសិក្សា ពីមត្តេយ្យសិក្សា រហូតដល់មធ្យមសិក្សាពី បឋមសិក្សារហូតដល់មធ្យមសិក្សា) ត្រូវស្នើសុំនៅច្រកចេញចូលតែមួយនៃក្រសួងអប់រំយុវជន និងកីឡា។

## ៥. សារសំខាន់នៃការសិក្សាស្រាវជ្រាវ

ការសិក្សាមួយនេះជាឯកសារបន្ថែមដែលអាចបម្រើដល់ការស្រាវជ្រាវសម្រាប់និស្សិតជំនាន់ក្រោយ សិក្សាបំពេញបន្ថែមលើចំណេះដឹង ហើយវាក៏ចូលជាប្រយោជន៍ដល់សាធារណៈជនក្នុងការពង្រីកចំណេះដឹង អំពីដំណើរការនៃការគ្រប់គ្រងរដ្ឋបាលថ្នាក់ស្រុក ជាពិសេសអោយដឹងកាន់តែច្បាស់ពីតួនាទី និងការបែងចែក មុខងាររបស់សាលាស្រុក។ របាយការណ៍នេះបានបង្ហាញពីការចុះកម្មសិក្សា និងផ្តល់ឱកាសដល់សិស្សមន្ត្រី សិស្សនិស្សិត សាធារណៈជនជំនាន់ក្រោយបានទទួលនូវទិន្នន័យចំណេះដឹងថ្មីៗបន្ថែមទៀតពាក់ព័ន្ធនឹងការ ចេញអាជ្ញាបណ្ណអប់រំ។

## ៦. វិធីសាស្ត្រនៃការស្រាវជ្រាវ

ទិន្នន័យដែលរំលេចក្នុងការរៀបចំរបាយការណ៍កម្មសិក្សានេះគឺបានមកតាមរយៈការអាន និងសិក្សា ស្រាវជ្រាវ លើលិខិតបទដ្ឋានគតិយុត្តិ លិខិតរដ្ឋបាល គោលនយោបាយ របាយការណ៍ និងឯកសារពាក់ព័ន្ធជា ច្រើនទៀតរបស់រដ្ឋបាលស្រុក ក៏ដូចជាការិយាល័យច្រកចេញចូលតែមួយដែលផ្តល់ជាធាតុចូលយ៉ាងសំខាន់ ក្នុងការរៀបចំសរសេររបាយការណ៍កម្មសិក្សានេះ។ លើសពីនេះខ្ញុំបាទទទួលបានព័ត៌មានតាមរយៈការអនុវត្ត ការងារជាក់ស្តែង ការអង្កេត សម្ភាសន៍ និងការផ្តល់មតិក៏ដូចជាអនុសាសន៍ល្អៗពីសំណាក់លោក លោកស្រី ប្រធាន និងមន្ត្រីក្នុងការិយាល័យក៏បានលើកយកមកបញ្ចូលក្នុងរបាយការណ៍នេះផងដែរ ដើម្បីឱ្យរបាយការណ៍ នេះមានភាពច្បាស់លាស់ត្រឹមត្រូវ។

### ៦.១ ឧបករណ៍ស្រាវជ្រាវ

យើងខ្ញុំប្រើប្រាស់ប្រភេទទិន្នន័យចំនួន២ ទិន្នន័យចម្បង(Primary Data) និងទិន្នន័យបន្ទាប់បន្សំ (Secondary Data)

#### ក. ទិន្នន័យចម្បង

ទិន្នន័យចម្បង (Primary Data): គឺជាប្រភេទទិន្នន័យដែលត្រូវបានប្រើប្រាស់សម្រាប់ការប្រមូលនូវ ព័ត៌មានសំខាន់ៗដែលផ្តោតលើគោលបំណងជាក់លាក់ មានលក្ខណៈពិតប្រាកដនិងផ្ទាល់។ តាមរយៈទិន្នន័យ ចម្បង យើងខ្ញុំប្រើប្រាស់នូវកម្រងសំណួរជាឧបករណ៍ជំនួយសម្រាប់ការប្រមូលយកទិន្នន័យ ដែលកម្រង សំណួរនេះត្រូវបានចងក្រងឡើងអំពីដំណើរការនៃការគ្រប់គ្រង ការអនុវត្តតួនាទី និងភារកិច្ច ។ តាមរយៈកម្រង សំណួរនេះនឹងអាចជួយអោយយើងខ្ញុំអាចបកស្រាយជាមួយនឹងសំណួរស្រាវជ្រាវខាងលើបាន។

### ខ. ទិន្នន័យបន្ទាប់បន្សំ

ទិន្នន័យបន្ទាប់បន្សំ (Secondary Data) គឺជាប្រភេទទិន្នន័យដែលត្រូវបានប្រើប្រាស់សម្រាប់ការប្រមូលនូវព័ត៌មានសំខាន់ៗដែលមានលក្ខណៈមិនផ្ទាល់។ តាមរយៈប្រភេទទិន្នន័យនេះ យើងខ្ញុំប្រើប្រាស់នូវការប្រមូលទិន្នន័យ និងឯកសារដែលពាក់ព័ន្ធជាច្រើនតាមរយៈគេហទំព័រផ្សេងៗទៀត និងបណ្តាប្រភពព័ត៌មានមួយចំនួនទៀតដូចជា កិច្ចការស្រាវជ្រាវបញ្ចប់ការសិក្សារបស់បណ្តាសិស្សច្បងដែលបានចងក្រងទុក និងដាក់តាំងនៅក្នុងបណ្ណាល័យនៃសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច និងប្រព័ន្ធអ៊ីនធឺណេត ដើម្បីយកមកបកស្រាយបន្ថែមអោយកាន់តែស៊ីជម្រៅបន្ថែមទៀត ។

### ៦.២ ទម្រង់នៃការស្រាវជ្រាវ

ទម្រង់នៃការស្រាវជ្រាវនេះ គឺត្រូវបានធ្វើឡើងតាម ៦ដំណាក់កាលដូចខាងក្រោម៖

- ដំណាក់កាលទី១៖ រៀបចំបំពេញសំណុំបែបបទស្នើសុំចុះកម្មសិក្សាស្រាវជ្រាវ និងសុំការអនុញ្ញាតពីការិយាល័យស្រាវជ្រាវរបស់សាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច ដើម្បីសុំលិខិតចុះកម្មសិក្សាស្រាវជ្រាវនៅក្នុងក្នុងសាលាស្រុកកៀនស្វាយ
- ដំណាក់កាលទី២៖ សុំការអនុញ្ញាតពីថ្នាក់ដឹកនាំសាលាស្រុកកៀនស្វាយ
- ដំណាក់កាលទី៣៖ រង់ចាំការយល់ព្រម និងឯកភាពឲ្យចុះកម្មសិក្សាស្រាវជ្រាវ
- ដំណាក់កាលទី៤៖ ចុះកម្មសិក្សាស្រាវជ្រាវតាមកាលបរិច្ឆេទកំណត់
- ដំណាក់កាលទី៥៖ ប្រមូល និងចងក្រងរបាយការណ៍កម្មសិក្សាស្រាវជ្រាវ
- ដំណាក់កាលទី៦៖ ទទួលបានលិខិតបញ្ជាក់កម្មសិក្សាស្រាវជ្រាវពីសាលាស្រុកកៀនស្វាយ។

## ៧. រចនាសម្ព័ន្ធនៃការស្រាវជ្រាវ

របាយការណ៍កម្មសិក្សាស្តីពីការផ្តល់អាជ្ញាបណ្ណអប់រំតាមរយៈការិយាល័យច្រកចេញចូលតែមួយនេះត្រូវបានរៀបចំជាជំពូកសំខាន់ៗ ដែលក្នុងនោះមានដូចខាងក្រោម៖

សេចក្តីផ្តើម៖ មានបង្ហាញពីលំនាំបញ្ហា ចំណោទបញ្ហា ចំណូលបញ្ហា គោលបំណងនៃកម្មសិក្សាស្រាវជ្រាវ ដែនកំណត់ និងវិសាលភាពនៃការចុះកម្មសិក្សា សារៈសំខាន់នៃការចុះកម្មសិក្សា វិធីសាស្ត្រនៃការសរសេររបាយការណ៍កម្មសិក្សាស្រាវជ្រាវ។

ជំពូក ១ ៖ ការពិនិត្យលើទ្រឹស្តី មានបង្ហាញពីទិដ្ឋភាពទូទៅនៃប្រព័ន្ធគ្រប់គ្រងរដ្ឋបាលរបស់ប្រទេសកម្ពុជា។

ជំពូក ២ ៖ និយាយទៅលើដំណើរការនៃការគ្រប់គ្រងរបស់រដ្ឋបាលស្រុកកៀនស្វាយ និងបង្ហាញអំពីសកម្មភាពការងារនៅក្នុងសាលាស្រុក។

ជំពូកទី ៣ ៖ បញ្ហាប្រឈមនិងយុទ្ធសាស្ត្រដំណោះស្រាយដើម្បីអភិវឌ្ឍរបស់ស្រុកកៀនស្វាយ

សេចក្តីសន្និដ្ឋាន និងការផ្តល់អនុសាសន៍។

**រចនាសម្ព័ន្ធនៃការស្រាវជ្រាវ**



# ជំពូក ១

# រំលឹកទ្រឹស្តី

# ជំពូក ១

# ទិដ្ឋភាពទូទៅនៃការគ្រប់គ្រងរដ្ឋបាលថ្នាក់ជាតិ

## ១.១. សេចក្តីផ្តើម

បន្ទាប់ពីប្រទេសជាតិទទួលបានសន្តិភាព ស្ថេរភាពនយោបាយ ឯកភាពជាតិ និងឯកភាពទឹកដីពេញលេញ តាមរយៈការអនុវត្ត "នយោបាយឈ្នះ-ឈ្នះ" ដែលផ្តួចផ្តើមគំនិត និងដឹកនាំអនុវត្តដោយ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា** នាចុងឆ្នាំ១៩៩៨ រាជរដ្ឋាភិបាលកម្ពុជា នីតិកាលទី២នៃរដ្ឋសភាបានសម្រេចចិត្តអនុវត្តកំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការនៅថ្នាក់ឃុំ សង្កាត់ តាមរយៈការដាក់ចេញច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាល ឃុំ សង្កាត់ ច្បាប់ស្តីពីការរៀបចំការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សា ឃុំ សង្កាត់ នៅឆ្នាំ២០០១ ឃុំ សង្កាត់ អាណត្តិទី០១ នៅឆ្នាំ២០០២។ បានរៀបចំបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សា។

ដោយមានបទពិសោធន៍ជោគជ័យនៃការអនុវត្តនយោបាយវិមជ្ឈការ និងវិសហមជ្ឈការនៅថ្នាក់ឃុំ សង្កាត់ រាជរដ្ឋាភិបាលបានសម្រេចពង្រីកវិសាលភាពនៃការអនុវត្តកំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការនៅថ្នាក់ក្រោមជាតិទាំងមូល ដោយបានដាក់ចេញនូវច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ និងច្បាប់ស្តីពីការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សារាជធានី ក្រុមប្រឹក្សាខេត្ត ក្រុមប្រឹក្សាក្រុង ក្រុមប្រឹក្សាស្រុក ក្រុមប្រឹក្សាខណ្ឌ នៅឆ្នាំ២០០៨។

ក្របខ័ណ្ឌយុទ្ធសាស្ត្រស្តីពីកំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការបានកំណត់គោលដៅយុទ្ធសាស្ត្រនៃកំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការនៅកម្ពុជាដូចខាងក្រោម៖

- ពង្រឹង និងពង្រីកលទ្ធិប្រជាធិបតេយ្យនៅមូលដ្ឋាន
- ជម្រុញការអភិវឌ្ឍនៅមូលដ្ឋាន និងការកាត់បន្ថយភាពក្រីក្រ។[1]

## ១.២.កំណែទម្រង់រដ្ឋបាលនៅប្រទេសកម្ពុជា

### ១.២.១.កំណែទម្រង់តាមបែបមជ្ឈការ

មជ្ឈការគឺជាប្រព័ន្ធនៃការគ្រប់គ្រងរដ្ឋមួយដែលមានសិទ្ធអំណាចនិងការសម្រេចចិត្តនានា ធ្វើឡើងដោយអំណាចកណ្តាល(រាជរដ្ឋាភិបាល)។[2]

[1] (សាលាជាតិរដ្ឋបាលមូលដ្ឋាន ឆ្នាំ២០២០, ការគ្រប់គ្រងរដ្ឋបាលក្រុង,ទំព័រ១)

[2] (សាកលវិទ្យាល័យវេស្ទើន,ឆ្នាំ២០១០-២០១១, សៀវភៅប្រព័ន្ធគ្រប់គ្រងរដ្ឋបាល,ទំព័រ១)

➢ **គុណសម្បត្តិ**

- ពង្រឹងអំណាចរដ្ឋ
- ពង្រឹងឯកភាពជាតិ
- ធ្វើឲ្យមានសមភាពចំពោះពលរដ្ឋ
- រដ្ឋអាចក្តោបស្ថានការណ៍ទាំងអស់ទូទាំងប្រទេសទាំងនយោបាយនិងសន្តិសុខជាតិ។

➢ **គុណវិបត្តិ**

- រដ្ឋបាលថ្នាក់ជាតិទទួលបន្ទុកច្រើនពេក
- ការប្រមូលផ្តុំអំណាចនៅរដ្ឋបាលថ្នាក់ជាតិ
- ការដាក់ផែនការនិងគម្រោងផែនការអភិវឌ្ឍផ្សេងៗ។

**១.២.២. គំរំណែទម្រង់តាមបែបវិមជ្ឈការ**

វិមជ្ឈការ គឺជាប្រព័ន្ធនៃការគ្រប់គ្រងរដ្ឋមួយដែលរដ្ឋបាលកណ្តាលប្រគល់ភាពជាម្ចាស់លើសិទ្ធអំណាច មុខងារ ធនធាន និងទទួលខុសត្រូវដល់រដ្ឋបាលមូលដ្ឋានដើម្បីឆ្លើយតបនិងតម្រូវការរបស់ប្រជាពលរដ្ឋ។

➢ **គុណសម្បត្តិ**

- អំពីនយោបាយ(ប្រជាធិបតេយ្យ)
- អំពីរដ្ឋបាល(ពង្រឹងសមត្ថភាពរដ្ឋបាលថ្នាក់ក្រោមជាតិនិងការទទួលខុសត្រូវ)។

➢ **គុណវិបត្តិ**

- អំណាចរដ្ឋចុះខ្សោយ
- សមត្ថភាពនិងការទទួលខុសត្រូវរបស់រដ្ឋបាលថ្នាក់ក្រោមជាតិអាចមានកម្រិត។

**១.២.៣. គំរំណែទម្រង់តាមបែបវិសហមជ្ឈការ**

វិសហមជ្ឈការគឺជាប្រព័ន្ធគ្រប់គ្រងរដ្ឋមួយដែលរដ្ឋបាលកណ្តាលបានធ្វើប្រតិភូកម្ម មុខងារ សិទ្ធអំណាច និងធនធានទៅរដ្ឋបាលដើម្បីអនុវត្តមុខងារទាំងនោះក្នុងនាមរាជរដ្ឋាភិបាល។

**ប្រតិភូកម្ម** គឺជាការផ្ទេរមុខងារការទទួលខុសត្រូវសិទ្ធអំណាច និងឆន្ទានុសិទ្ធដើម្បីគ្រប់គ្រងអនុវត្តក្នុងនាមអាជ្ញាធរធ្វើប្រតិភូកម្ម ដោយអាជ្ញាធររក្សាភាពជាម្ចាស់លើកិច្ចការធ្វើប្រតិភូកម្ម។

**ឆន្ទានុសិទ្ធ** ជាសេរីភាពរបស់មន្ត្រីសាធារណៈក្នុងការជ្រើសរើសផ្លូវដែលត្រូវប្រកាន់យកក្នុងរង្វង់ព្រំដែនអំណាចរបស់ខ្លួន។

**ប្រតិភូកម្មអំណាច** ជាលិខិតបទដ្ឋានគតិយុត្តរបស់ម្ចាស់អំណាចឲ្យសិទ្ធអំណាចទៅថ្នាក់ក្រោម ក្លាយជាម្ចាស់អំណាចពេញសិទ្ធ។

**ប្រតិភូកម្មហត្ថលេខា** ជាលិខិតបទដ្ឋាន សាមញ្ញធ្វើដោយម្ចាស់អំណាច ប្រគល់សិទ្ធឲ្យទៅសហការី ដែលមានឋានៈបន្ទាប់ចុះសេខាជំនួសខ្លួន។

➢ **គុណសម្បត្តិ**

- កាត់បន្ថយការងាររបស់រដ្ឋបាលកណ្តាល
- អំណាចរដ្ឋបាលកណ្តាល ខិតជិតជាមួយថ្នាក់មូលដ្ឋាននិងប្រជាពលរដ្ឋ
- ដោះស្រាយបញ្ហាទៅតាមសភាពជាក់ស្តែងនៃកន្លែងមួយ
- ផ្តល់សេវាសាធារណៈកាន់តែប្រសើរដល់ប្រជាពលរដ្ឋ(ការរំលែកអំណាចធ្វើឲ្យអំណាចកណ្តាលមិនលំបាកដោះស្រាយ កិច្ចការមូលដ្ឋាននិងធ្វើឲ្យការគ្រប់គ្រងបានល្អប្រសើរ)។

➢ **គុណវិបត្តិ**

- ថ្នាក់មូលដ្ឋានអាចមិនស្តាប់យោបល់ថ្នាក់កណ្តាល ឬមិនធ្វើតាម
- អាចយកសិទ្ធអំណាចទៅប្រើខុសទិសដៅដើម្បីផលប្រយោជន៍ខ្លួន
- អំណាចរដ្ឋអាចចុះខ្សោយ
- មានការរំលោភអំណាចនៅមូលដ្ឋាន។

### ១.២.៤. មូលហេតុនៃការអនុវត្តកំណែទម្រង់[3]

រាជរដ្ឋាភិបាលចាត់ទុកកិច្ចដំណើរការកំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការគឺជាមធ្យោបាយដ៏មានប្រសិទ្ធភាពក្នុងការបង្កិតសេវាសាធារណៈឱ្យកាន់តែទៅជិតប្រជាពលរដ្ឋ ហើយរំពឹងថានឹងទទួលបាននូវផលប្រយោជន៍ធំៗគឺ

ទី១ ÷ ប្រជាពលរដ្ឋអាចមានលទ្ធភាពចូលរួមយ៉ាងសកម្ម នៅក្នុងការធ្វើសេចក្តីសម្រេចចិត្តនៅមូលដ្ឋានដែលនេះគឺជាការពង្រឹង និងពង្រីកនូវការចូលរួមជាសាធារណៈនៅក្នុងការអភិវឌ្ឍប្រទេសជាតិ។ តម្រូវការ អាទិភាពនានារបស់ប្រជាពលរដ្ឋនៅមូលដ្ឋានត្រូវបានគិតគូរយកចិត្តទុកដាក់ និងឆ្លើយតបកាន់តែប្រសើរឡើង។ ដូច្នេះតាមរយៈការអនុវត្តកំណែទម្រង់នេះនឹងនាំឱ្យមានការធ្វើសេចក្តីសម្រេចចិត្តកាន់តែមានភាពល្អប្រសើរ និងការប្រើប្រាស់ធនធានកាន់តែ មានប្រសិទ្ធភាព និងភាពស័ក្តិសិទ្ធិថែមទៀត ។

ទី២ ÷ ការផ្តល់សេវាសាធារណៈរបស់ក្រសួងស្ថាប័ននៅថ្នាក់ជាតិកាន់តែរហ័ស និងមានប្រសិទ្ធភាពព្រោះអ្នកទទួលខុសត្រូវក្នុងការផ្តល់សេវាទាំងនោះត្រូវបានផ្ទេរ ឬបង្កិតឱ្យទៅជិតប្រជាពលរដ្ឋ ។

[3] គេហទំព័រះ https://elibrary.maff.gov.kh/assets/files/books/adf4b8c615e7448b1bc1f49d31d2e3f21594868040.pdf[15,June24]

ទី៣ ÷ ការបង្កើននូវលទ្ធភាពនៃការកៀរគរប្រភពធនធាននៅមូលដ្ឋានសម្រាប់ផ្តល់សេវា និងការអភិវឌ្ឍបន្ថែមទៀត ដោយផ្អែកលើឆន្ទៈនៃការចូលរួមរបស់ប្រជាពលរដ្ឋ សង្គមស៊ីវិល ក៏ដូចជាការកៀរគរធនធានរបស់វិស័យឯកជននានាឱ្យចូលរួមជាមួយធនធានរបស់អាជ្ញាធរមូលដ្ឋានក្នុងការវិនិយោគលើការអភិវឌ្ឍមូលដ្ឋាន និងការកាត់បន្ថយភាពក្រីក្រ ។

### ១.២.៥. គោលដៅនៃកំណែទម្រង់[4]

ទិសដៅនៃកំណែទម្រង់មជ្ឈការ វិមជ្ឈការ និងវិសហមជ្ឈការគឺដើម្បីបង្កើត និងលើកកម្ពស់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ។ ទម្រង់វិមជ្ឈការ និងវិសហមជ្ឈការមានគោលដៅជាយុទ្ធសាស្ត្របី គឺ៖

- ពង្រឹងពង្រីកលទ្ធិប្រជាធិបតេយ្យសេរីពហុបក្សនៅមូលដ្ឋាន
- លើកកម្ពស់ការអភិវឌ្ឍសេដ្ឋកិច្ច និងសង្គម
- ជំរុញកិច្ចអភិវឌ្ឍមូលដ្ឋាន និងការកាត់បន្ថយភាពក្រីក្រតាមរយៈការបង្កលក្ខណៈឱ្យប្រជាពលរដ្ឋចូលរួមក្នុងការធ្វើសេចក្តីសម្រេចចិត្តទាក់ទងនឹងតម្រូវការចាំបាច់នានានៅមូលដ្ឋាន សំដៅលើកកម្ពស់ភាពជាម្ចាស់របស់សហគមន៍មូលដ្ឋាន ។

ដូច្នេះដើម្បីឆ្លើយតបទៅនឹងគោលដៅជាយុទ្ធសាស្ត្រកំណែទម្រង់ ចាំបាច់ត្រូវរៀបចំរចនាសម្ព័ន្ធក្នុងគោលបំណង ដើម្បីប្រព័ន្ធអភិបាលកិច្ចនៅថ្នាក់ក្រោមជាតិធានាឱ្យមានការអភិវឌ្ឍប្រកបដោយនិរន្តរភាពទូលំទូលាយសំដៅពង្រឹងមូលដ្ឋានគ្រឹះសម្រាប់ខឿនសេដ្ឋកិច្ចនៅមូលដ្ឋាន។

- ធានាឱ្យប្រជាពលរដ្ឋគ្រប់រូបមានឱកាសស្មើគ្នាក្នុងការចូលរួមរៀបចំ និងអនុវត្តផែនការអភិវឌ្ឍមូលដ្ឋាន
- បង្កើតនូវបរិយាកាសប្រកបដោយប្រសិទ្ធភាពសម្រាប់គ្រប់គ្រង ធនធានធម្មជាតិ និងសម្រាប់ការផ្តល់សេវាសាធារណៈប្រកបដោយគុណភាព ដើម្បីឆ្លើយតបទៅនឹងសេចក្តីត្រូវការរបស់ប្រជាពលរដ្ឋ និងកាត់បន្ថយភាពក្រីក្រដោយផ្តោតការយកចិត្តទុកដាក់ទៅលើជនក្រីក្រ ក្រុមជនងាយរងគ្រោះ ជនជាតិដើម ជនជាតិភាគតិច ស្ត្រី កុមារ យុវជន និងយុវនារី ។

### ១.២.៦. ក្របខ័ណ្ឌគោលនយោបាយ និងច្បាប់គាំទ្រកំណែទម្រង់

#### ១.២.៦.១. ក្របខ័ណ្ឌគោលនយោបាយ[5]

កំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការនៅកម្ពុជាត្រូវបានផ្តួចផ្តើម និងយកចិត្តទុកដាក់តាំងពីក្រោយការបោះឆ្នោតសកលឆ្នាំ១៩៩៣ ហើយនឹងត្រូវបានយកចិត្តទុកដាក់កាន់តែខ្លាំងឡើងៗ នៅក្នុងអាណត្តិទី២នៃ

[4](ក្រសួងមហាផ្ទៃ,ឆ្នាំ២០១១,សៀវភៅណែនាំស្តីពីតួនាទី ភារកិច្ច និងរបៀបរបបការងាររបស់រដ្ឋបាលរាជធានី,ទំព័រ២)

[5](ក្រសួងមហាផ្ទៃ,ខែកក្កដា ឆ្នាំ២០១១,សៀវភៅតួនាទី ភារកិច្ចនិងរបៀបរបបការងាររបស់រាជធានី,ទំព័រ៣)

រាជរដ្ឋាភិបាលកម្ពុជា។ តាមរយៈសមិទ្ធផលដ៏ជោគជ័យនៃការយកចិត្តទុកដាក់និងអនុវត្តកំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការក្នុងអាណត្តិទី២នៃរាជរដ្ឋាភិបាល រាជរដ្ឋាភិបាល កម្ពុជាបានបន្តពង្រឹង ពង្រីកការអនុវត្ត កំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការឱ្យកាន់តែស៊ីជម្រៅថែមទៀត។ រាជរដ្ឋាភិបាលបានរៀបចំអនុម័ត ក្របខ័ណ្ឌគោលនយោបាយមួយចំនួន ដើម្បីត្រួសត្រាយផ្លូវសម្រាប់កំណែទម្រង់នេះរួមមាន ៖

- យុទ្ធសាស្ត្រចតុកោណ
- ក្របខ័ណ្ឌយុទ្ធសាស្ត្រស្តីពីកំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការ។

**ក). យុទ្ធសាស្ត្រចតុកោណ**

អភិបាលកិច្ចល្អ គឺជាស្នូលនៃយុទ្ធសាស្ត្រចតុកោណដំណាក់កាលទី១ និងដំណាក់កាលទី២ ដែលត្រូវបានទទួលស្គាល់ជាបុរេលក្ខខណ្ឌសំខាន់បំផុតសម្រាប់ការអភិវឌ្ឍប្រកបដោយសមធម៌ និងយុត្តិធម៌។ ដើម្បីសម្រេចនូវអភិបាលកិច្ចល្អ រាជរដ្ឋាភិបាលផ្តោតការយកចិត្តទុកដាក់កំណែទម្រង់លើវិស័យចំនួនបួនរួមមាន ៖

- ការប្រយុទ្ធប្រឆាំងនឹងអំពើពុករលួយ
- កំណែទម្រង់ច្បាប់ និងប្រព័ន្ធយុត្តិធម៌
- កំណែទម្រង់រដ្ឋបាលសាធារណៈ
- កំណែទម្រង់កងកម្លាំងប្រដាប់អាវុធ។

កំណែទម្រង់រដ្ឋបាលសាធារណៈរាជរដ្ឋាភិបាលចាត់ទុកថាកំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការ មានសារៈសំខាន់ចំពោះការកែលម្អគុណភាពនៃសេវាសាធារណៈ និងការអភិវឌ្ឍមូលដ្ឋានដោយមានការចូលរួម ។

**ខ). ក្របខ័ណ្ឌយុទ្ធសាស្ត្រកំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការ**[6]

ក្របខ័ណ្ឌយុទ្ធសាស្ត្រស្តីពីកំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការគឺជាឯកសារគោលនយោបាយរបស់រាជរដ្ឋាភិបាលកម្ពុជាដែលត្រូវបានអនុម័តដោយរាជរដ្ឋាភិបាលកម្ពុជាក្នុងសម័យប្រជុំពេញអង្គគណៈរដ្ឋមន្ត្រី នាថ្ងៃទី១៧ ខែមិថុនា ឆ្នាំ២០០៥ ។

ក្របខ័ណ្ឌយុទ្ធសាស្ត្រស្តីពីកំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការបានកំណត់អំពី ៖

- ចក្ខុវិស័យរបស់រដ្ឋាភិបាលអំពីកំណែទម្រង់អភិបាលកិច្ចនៅថ្នាក់ក្រោមជាតិ
- គោលដៅនៃយុទ្ធសាស្ត្រជាតិក្នុងកំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការ
- វិសាលភាពនៃការអនុវត្តកំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការ
- របៀបរៀបចំរចនាសម្ព័ន្ធគ្រប់គ្រងនៅតាមរដ្ឋបាលថ្នាក់ក្រោមជាតិនីមួយៗ

[6](ក្រសួងមហាផ្ទៃ,ខែកក្កដា ឆ្នាំ២០១១,សៀវភៅតួនាទី ភារកិច្ចនិងរបៀបរបបការងាររបស់រាជធានី,ទំព័រ៥)

- ការណែនាំដល់ការងារកំណែទម្រង់ទាំងអស់ដែលមានផលប៉ះពាល់ដល់ប្រព័ន្ធគ្រប់គ្រងនៅតាមរដ្ឋបាលថ្នាក់ក្រោមជាតិនីមួយៗ ។

**១.២.៦.២. ក្របខ័ណ្ឌច្បាប់**[7]

ដោយផ្អែកតាមក្របខ័ណ្ឌគោលនយោបាយខាងលើរាជរដ្ឋាភិបាលបានរៀបចំឱ្យមានច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់ និងច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ដែលច្បាប់ទាំងពីរនេះត្រូវបានកំណត់ថាជា "ច្បាប់រៀបចំអង្គការ" ។

**ក). ច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់**

ច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់ គឺជាមូលដ្ឋានគ្រឹះសម្រាប់រាជរដ្ឋាភិបាលចាប់ផ្តើមអនុវត្តកំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការរបស់ខ្លួននៅថ្នាក់ឃុំ សង្កាត់ ដែលត្រូវបានអនុម័តក្នុងឆ្នាំ២០០១។

❖ ច្បាប់នេះកំណត់ឱ្យក្រុមប្រឹក្សាឃុំ សង្កាត់មានមុខងារពីរគឺ ៖

- មុខងារផ្ទាល់ដែលជាមុខងារបម្រើកិច្ចការមូលដ្ឋាន គឺការបម្រើផលប្រយោជន៍ជូនប្រជាពលរដ្ឋក្នុងឃុំ សង្កាត់របស់ខ្លួន
- មុខងារជាភ្នាក់ងារតំណាងរដ្ឋក្រោមការចាត់តាំង ឬប្រគល់អំណាច របស់អាជ្ញាធររដ្ឋ។

**ខ). ច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ**

ដើម្បីអនុវត្តយុទ្ធសាស្ត្រកំណែទម្រង់វិមជ្ឈការនិងវិសហមជ្ឈការ រាជរដ្ឋាភិបាលបានរៀបចំចងក្រងច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ដែលច្បាប់នេះត្រូវបានប្រកាសឱ្យប្រើប្រាស់ដោយព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៧ ចុះថ្ងៃទី២៤ ខែឧសភា ឆ្នាំ២០០៨។

ច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ គឺជាមូលដ្ឋានគ្រឹះសម្រាប់រាជរដ្ឋាភិបាល បន្តពង្រីកវិសាលភាពនៃការអនុវត្តកំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការនៅថ្នាក់រាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ។ ដើម្បីអនុវត្តក្របខ័ណ្ឌច្បាប់ទាំងនេះរាជរដ្ឋាភិបាលចាំបាច់ត្រូវរៀបចំលិខិតបទដ្ឋាននានាជាច្រើនទៀត ហើយទាមទារឱ្យមានការពិនិត្យ និងកែសម្រួលលិខិតបទដ្ឋានទាំងនោះជាបន្តបន្ទាប់ផងដែរ ។

➢ **គោលបំណង**

ច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ នេះមានគោលបំណងកំណត់ការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ តាមគោលការណ៍នៃរដ្ឋបាលឯកភាពដើម្បីបង្កើតជំរុញ

[7] https://elibrary.maff.gov.kh/assets/files/books/869f67423bc4ace84d3c6adb12e26fe41594868011.pdf [16, June 24]

និងធ្វើអោយមានចីរភាព ដល់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យ តាមរយៈនយោបាយវិមជ្ឈការ និងវិសហមជ្ឈការ ។

➢ **ការរៀបចំដែនដី**

- រាជធានីចែកជាខណ្ឌ
- ខណ្ឌចែកជាសង្កាត់
- ខេត្តចែកជាក្រុង និងស្រុក
- ក្រុងចែកជាសង្កាត់
- ស្រុកចែកជាឃុំ និងសង្កាត់ ។

➢ **នីតិបុគ្គលនៃនីតិសាធារណៈ**

រាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ជានីតិបុគ្គលនៃនីតិសាធារណៈ នីតិបុគ្គល សាធារណៈ គឺជាក្រុមមនុស្ស ដែលច្បាប់បានអនុញ្ញាតឱ្យធ្វើសកម្មភាពដូចជាបុគ្គលដើម្បីជាប្រយោជន៍សាធារណៈ ។

➢ **ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យរួមមាន ៖**

- ភាពជាតំណាងសាធារណៈ
- ស្វ័យភាពរបស់មូលដ្ឋាន
- ការពិគ្រោះយោបល់ និងការចូលរួម
- ការឆ្លើយតប និងគណនេយ្យភាព
- ការលើកកម្ពស់គុណភាពជីវិតរបស់ប្រជាជននៅក្នុងមូលដ្ឋាន
- ការលើកស្ទួយសមធម៌
- តម្លាភាព និងសុចរិតភាព
- វិធានការប្រឆាំងអំពើពុករលួយ និងការរំលោភអំណាច ។

## ១.៣.លិខិតរដ្ឋបាល

### ១.៣.១. និយមន័យ

លិខិតរដ្ឋបាល គឺជាលិខិតដែលរៀបចំតាក់តែងឡើងជាលាយលក្ខណ៍អក្សរសម្រាប់ជាមធ្យោបាយ ទំនាក់ទំនងផ្លូវការរបស់រដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ជាមួយស្ថាប័ន អង្គភាព និងបុគ្គលនានាក្នុង គោលបំណងជូនព័ត៌មានណែនាំ អញ្ជើញ រាយការណ៍ ផ្សព្វផ្សាយ ឆ្លើយតប ឬចាត់តាំងបុគ្គលណាមួយឱ្យទៅ បំពេញបេសកកម្ម។

### ១.៣.២. ប្រភេទនៃលិខិតរដ្ឋបាល[8]

❖ **លិខិតស្នើ**

លិខិតស្នើ គឺជាលិខិតរដ្ឋបាលមួយប្រភេទសម្រាប់បង្ហាញអំពីគោលបំណង និងមូលហេតុនៃតម្រូវការជាក់លាក់ណាមួយ ដើម្បីថ្លែងទៅកាន់បុគ្គល ឬអង្គភាពដែលមានសិទ្ធិអំណាចសម្រេច ឬដោះស្រាយចំពោះការស្នើសុំនោះ។

❖ **សេចក្តីជូនដំណឹង**

សេចក្តីជូនដំណឹង គឺជាលិខិតរដ្ឋបាលមួយប្រភេទ សម្រាប់ឆ្លើយបំភ្លឺ ឬឆ្លើយតប ឬបញ្ជាក់ ឬណែនាំ ឬផ្តល់យោបល់ចំពោះបញ្ហាអ្វីមួយ ឬជូនដំណឹងឱ្យសាធារណជនបានដឹងនូវព័ត៌មាននានា ឬអំពាវនាវឱ្យសាធារណជនទូទៅ និងអ្នកពាក់ព័ន្ធនានាចូលរួមអនុវត្តសកម្មភាពជាក់លាក់ណាមួយ ឬចូលរួមបរិច្ចាគអ្វីមួយដើម្បីជាប្រយោជន៍សាធារណៈ។

សេចក្តីជូនដំណឹង មាន០២ប្រភេទ ៖

- សេចក្តីជូនដំណឹងដែលមានចំណងជើង
- សេចក្តីជូនដំណឹងដែលពុំមានចំណងជើង

❖ **លិខិតអញ្ជើញ**

លិខិតអញ្ជើញ គឺជាលិខិតរដ្ឋបាលមួយប្រភេទសម្រាប់ធ្វើការអញ្ជើញបុគ្គល ឬតំណាងអង្គភាពនានាឱ្យមកចូលរួមព្រឹត្តិការណ៍ ឬសកម្មភាពនានា ដែលពាក់ព័ន្ធនឹងបុគ្គល ឬអង្គភាពទាំងនោះដោយមានបញ្ជាក់ច្បាស់លាស់អំពីឈ្មោះ តួនាទី និងអង្គភាពរបស់អ្នកដែលត្រូវអញ្ជើញ ទីកន្លែងប្រារព្ធពិធី កាលបរិច្ឆេទ

ពេលវេលាព្រមទាំងអាចមានភ្ជាប់មកជាមួយនូវកម្មវិធី ឬរបៀបវារៈ និងឯកសារពាក់ព័ន្ធនានា។

❖ **លិខិតបង្គាប់ការ**

លិខិតបង្គាប់ការ គឺជាលិខិតរដ្ឋបាលមួយប្រភេទសម្រាប់ចាត់តាំងបុគ្គលណាម្នាក់ឱ្យទៅចូលរួមជាសមាជិកគណៈកម្មាធិការ អនុគណៈកម្មាធិការ ក្រុមការងារ ឬឱ្យទៅបំពេញតួនាទីដែលនៅទំនេរនៅក្នុងអង្គភាពក្នុងលក្ខណៈបណ្តោះអាសន្ន។

❖ **លិខិតបញ្ជាបេសកកម្ម**

លិខិតបញ្ជាបេសកកម្ម គឺជាលិខិតរដ្ឋបាលមួយប្រភេទ សម្រាប់ចាត់តាំងបុគ្គលណាម្នាក់ឱ្យទៅចូលរួម

[8] (សាលាជាតិរដ្ឋបាលមូលដ្ឋាន,ឆ្នាំ២០២២,ការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់២០២២,ទំព័រ៧៥)

ព្រឹត្តិការណ៍នានា ដូចជាសិក្ខាសាលា វគ្គបណ្តុះបណ្តាល កិច្ចប្រជុំ ទិវាវេទិកា ឬឱ្យទៅបំពេញបេសកកម្មនៅក្រៅអង្គភាពរបស់ខ្លួន។

❖ **លិខិតចុះទិដ្ឋាការធ្វើដំណើរ**

លិខិតចុះទិដ្ឋាការធ្វើដំណើរ គឺជាលិខិតរដ្ឋបាលមួយប្រភេទសម្រាប់ឱ្យអ្នកដែលមានភារកិច្ចទៅ បំពេញបេសកកម្មយកទៅចុះទិដ្ឋាការនូវទីកន្លែង កាលបរិច្ឆេទ មធ្យោបាយធ្វើដំណើរ និងហត្ថលេខារបស់អង្គភាពដែលបានអនុញ្ញាត និងអង្គភាពដែលបានទទួល ដើម្បីជាការដឹងឮអំពីការចេញដំណើរ និងការមកដល់របស់អ្នកបំពេញបេសកកម្ម ពីទីកន្លែងមួយ ទៅទីកន្លែងមួយទៀត។ លិខិតចុះទិដ្ឋាការធ្វើដំណើរនេះក៏មានសារៈសំខាន់ផងដែរសម្រាប់ធ្វើការទូទាត់ចំណាយប្រាក់បេសកកម្ម។

❖ **លិខិតផ្ទេរសិទ្ធិ**

លិខិតផ្ទេរសិទ្ធិ គឺជាលិខិតរដ្ឋបាលមួយប្រភេទសម្រាប់ប្រធានអង្គភាពប្រើប្រាស់ក្នុងការប្រគល់សិទ្ធិជាលាយលក្ខណ៍អក្សរទៅឱ្យបុគ្គលណាម្នាក់ដែលស្ថិតក្នុងមុខតំណែងគ្រប់គ្រងបន្ទាប់ ដើម្បីធ្វើជាប្រធានស្តីទីក្នុងអំឡុងពេលដែលខ្លួនអវត្តមាន។

❖ **លិខិតប្រគល់សិទ្ធិចុះហត្ថលេខា**

លិខិតប្រគល់សិទ្ធិចុះហត្ថលេខា គឺជាលិខិតរដ្ឋបាលមួយប្រភេទសម្រាប់ប្រធានអង្គភាពប្រើប្រាស់ក្នុងការប្រគល់សិទ្ធិចុះហត្ថលេខាជាលាយលក្ខណ៍អក្សរទៅឱ្យបុគ្គលណាម្នាក់ដែលស្ថិតក្នុងមុខតំណែងគ្រប់គ្រងក្នុងការចុះហត្ថលេខាលើការងារជាក់លាក់ណាមួយក្នុងនាមខ្លួន។

❖ **ដីការអម**

ដីកាអម គឺជាលិខិតរដ្ឋបាលមួយប្រភេទ សម្រាប់អមភ្ជាប់ជាមួយសំណុំលិខិត ឬឯកសារដែលត្រូវផ្ញើជូនអង្គភាពនានា ដោយបញ្ជាក់អំពីឈ្មោះលិខិត ឬឯកសារ និងចំនួនច្បាប់និងសន្លឹកនៃលិខិត ឬឯកសារនីមួយៗដែលត្រូវផ្ញើចេញ។

❖ **លិខិតបង្គាប់ការ**

លិខិតបង្គាប់ការ គឺជាលិខិតរដ្ឋបាលមួយប្រភេទសម្រាប់ចាត់តាំងបុគ្គលណាម្នាក់ឱ្យទៅចូលរួមជាសមាជិកគណៈកម្មាធិការ អនុគណៈកម្មាធិការ ក្រុមការងារ ឬឱ្យទៅបំពេញតួនាទីដែលនៅទំនេរនៅក្នុងអង្គភាពក្នុងលក្ខណៈបណ្តោះអាសន្ន។

❖ **លិខិតបញ្ជាបេសកកម្ម**

លិខិតបញ្ជាបេសកកម្ម គឺជាលិខិតរដ្ឋបាលមួយប្រភេទសម្រាប់ចាត់តាំងបុគ្គលណាម្នាក់ឱ្យទៅចូលរួម

ព្រឹត្តិការណ៍នានា ដូចជាសិក្ខាសាលា វគ្គបណ្ដុះបណ្ដាល កិច្ចប្រជុំ ទិវា វេទិកា ឬឱ្យទៅបំពេញបេសកកម្មនៅក្រៅអង្គភាពរបស់ខ្លួន។ លិខិតបញ្ជាបេសកកម្មត្រូវភ្ជាប់ជាមួយនូវលិខិតចុះទិដ្ឋាការធ្វើដំណើរ។

❖ **លិខិតចុះទិដ្ឋាការធ្វើដំណើរ**

លិខិតចុះទិដ្ឋាការធ្វើដំណើរ គឺជាលិខិតរដ្ឋបាលមួយប្រភេទសម្រាប់ឱ្យអ្នកដែលមានភារកិច្ចទៅបំពេញបេសកកម្មយកទៅចុះទិដ្ឋាការនូវទីកន្លែង កាលបរិច្ឆេទ មធ្យោបាយធ្វើដំណើរ និងហត្ថលេខារបស់អង្គភាពដែលបានអនុញ្ញាត អង្គភាពដែលបានទទួលដើម្បីជាការដឹងឮអំពីការចេញដំណើរ និងការមកដល់របស់អ្នកបំពេញបេសកកម្ម ពីទីកន្លែងមួយ ទៅទីកន្លែងមួយទៀត។ លិខិតចុះទិដ្ឋាការធ្វើដំណើរនេះក៏មានសារៈសំខាន់ផងដែរសម្រាប់ធ្វើការទូទាត់ចំណាយប្រាក់បេសកកម្ម។

❖ **លិខិតផ្ទេរសិទ្ធិ**

លិខិតផ្ទេរសិទ្ធិ គឺជាលិខិតរដ្ឋបាលមួយប្រភេទសម្រាប់ប្រធានអង្គភាពប្រើប្រាស់ក្នុងការប្រគល់សិទ្ធិជាលាយលក្ខណ៍អក្សរទៅឱ្យបុគ្គលណាម្នាក់ដែលស្ថិតក្នុងមុខតំណែងគ្រប់គ្រងបន្ទាប់ ដើម្បីធ្វើជាប្រធានស្ដីទីក្នុងអំឡុងពេលដែលខ្លួនអវត្តមាន។

❖ **លិខិតប្រគល់សិទ្ធិចុះហត្ថលេខា**

លិខិតប្រគល់សិទ្ធិចុះហត្ថលេខា គឺជាលិខិតរដ្ឋបាលមួយប្រភេទសម្រាប់ប្រធានអង្គភាពប្រើប្រាស់ក្នុងការប្រគល់សិទ្ធិចុះហត្ថលេខាជាលាយលក្ខណ៍អក្សរទៅឱ្យបុគ្គលណាម្នាក់ដែលស្ថិតក្នុងមុខតំណែងគ្រប់គ្រងក្នុងការចុះហត្ថលេខាលើការងារជាក់លាក់ណាមួយក្នុងនាមខ្លួន។

❖ **លិខិតអនុញ្ញាតច្បាប់ឈប់សម្រាក**

លិខិតអនុញ្ញាតច្បាប់ឈប់សម្រាក គឺជាលិខិតរដ្ឋបាលមួយប្រភេទ សម្រាប់អនុញ្ញាតឱ្យបុគ្គលិកឈប់សម្រាកក្នុងរយៈពេលសមស្របណាមួយ ស្របតាមការកំណត់របស់លិខិតបទដ្ឋានគតិយុត្តជាធរមាន។

❖ **កំណត់បង្ហាញរឿង**

កំណត់បង្ហាញរឿង គឺជាលិខិតរដ្ឋបាលមួយប្រភេទសម្រាប់លើកយោបល់អំពីបញ្ហាជាក់លាក់ណាមួយសម្រាប់ជាជំនួយស្មារតីដល់ថ្នាក់ដឹកនាំក្នុងការពិចារណា និងសម្រេច។

❖ **របាយការណ៍**

របាយការណ៍ គឺជាលិខិតរដ្ឋបាលមួយប្រភេទសម្រាប់ធ្វើសេចក្ដីរាយការណ៍ជាលាយលក្ខណ៍អក្សរអំពីសកម្មភាព ដំណើរការ និងលទ្ធផលការងាររបស់អង្គភាពដែលបានបំពេញ ឬរបស់បុគ្គលិកដែលបានចាត់តាំងឱ្យទៅបំពេញកិច្ចការអ្វីមួយ ក្នុងគោលបំណងរាយការណ៍ជូនថ្នាក់ដឹកនាំនិងអង្គភាពពាក់ព័ន្ធ។

➢ **ទម្រង់របាយការណ៍មាន០២ប្រភេទ ៖**

- ទម្រង់របាយការណ៍ដែលមានចំណងជើងត្រូវបានប្រើប្រាស់សម្រាប់រៀបចំរបាយការណ៍តាមរបប កំណត់ ឬរបាយការណ៍នានាដែលពុំបានកំណត់ច្បាស់លាស់អំពីបុគ្គល ឬអង្គភាពដែលត្រូវរាយការណ៍ជូនថ្នាក់ដឹកនាំ ជារបាយការណ៍សិក្សាស្រាវជ្រាវ របាយការណ៍អភិវឌ្ឍសមត្ថភាព និង របាយការណ៍សម្រាប់ភ្ជាប់ ជាមួយសំណុំឯកសារនានាជាដើម។
- ចំណែកទម្រង់របាយការណ៍ដែលពុំមានចំណងជើងត្រូវបានប្រើប្រាស់សម្រាប់រៀបចំរបាយការណ៍ នានាដែលបានកំណត់ច្បាស់អំពីបុគ្គល ឬអង្គភាពដែលត្រូវរាយការណ៍ជូន។

❖ **កំណត់ហេតុ**

កំណត់ហេតុ គឺជាលិខិតរដ្ឋបាលមួយប្រភេទសម្រាប់កត់ត្រានូវមតិយោបល់របស់សមាជិកអង្គប្រជុំ និង ការសម្រេចរបស់អង្គប្រជុំ ឬសម្រាប់កត់ត្រាព្រឹត្តិការណ៍ណាមួយដែលបានកើតឡើងជាក់ស្តែង ដើម្បីប្រើប្រាស់ និងរក្សាទុកជាសក្ខីភាពនៅពេលមានតម្រូវការ។

❖ **លិខិតបញ្ជាក់**

លិខិតបញ្ជាក់ គឺជាលិខិតរដ្ឋបាលមួយប្រភេទសម្រាប់បញ្ជាក់អំពីព័ត៌មានចាំបាច់នានាពាក់ព័ន្ធនឹង បុគ្គល ឬអង្គភាពទៅតាមសំណូមពររបស់សាមីជន ឬអង្គភាពដើម្បីយកទៅប្រើប្រាស់ជាផ្លូវការតាមតម្រូវការ ឬ តាមការដែលអាចប្រើបាន។

### ១.៣.២. ទម្រង់នៃលិខិតរដ្ឋបាល

លិខិតរដ្ឋបាលនេះគេធ្វើឡើងសម្រាប់ទាក់ទងគ្នាជាផ្លូវការពីស្ថាប័នមួយទៅស្ថាប័នមួយ ពីស្ថាប័នខ្ពស់ មកស្ថាប័នទាប ឬពីស្ថាប័នទាបទៅស្ថាប័នខ្ពស់ ឬស្ថាប័នដែលមានឋានៈស្មើ និងប្រហាក់ប្រហែលគ្នា។

**ទម្រង់លិខិតរដ្ឋបាលនីមួយៗ ចែកចេញជា ៣ផ្នែកគឺ៖**

- ផ្នែកក្បាល (ដើម)
- ផ្នែកអត្ថបទ (កណ្តាល)
- ផ្នែកបញ្ចប់ (បញ្ចប់)

**ក. ផ្នែកក្បាល**

1. របបនយោបាយ (ព្រះរាជាណាចក្រកម្ពុជា)
2. បាវចនា (ជាតិ សាសនា ព្រះមហាក្សត្រ)
3. សញ្ញាសម្គាល់ក្រសួង ស្ថាប័ន ឬអង្គភាព

4. ប្រភពលិខិត (ឈ្មោះក្រសួង ស្ថាប័ន ឬអង្គភាព)

5. លេខលិខិត និងអក្សរសម្គាល់លិខិត

6. ទីកន្លែងធ្វើ និងកាលបរិច្ឆេទលិខិត (ករណីស្ថាប័នខ្ពស់សរសេរទៅកាន់ស្ថាប័នទាប)។

**ខ. ផ្នែកអត្ថបទ**

7. បេសកៈ (មុខងារម្ចាស់អ្នកចេញលិខិត)

8. ស្វាគមន៍ (សូមក្រាបបង្គំទូលថ្វាយ សូមគោរពជូន គោរពជូន ជម្រាបប្រគេនថ្វាយ.......

9. គម្យជន (គោរម្យងារ និងឋានៈអ្នកទទួលលិខិត)

10. តាមរយៈ (ករណីលិខិតឆ្លងកាត់ថ្នាក់លើ)

11. កម្មវត្ថុ (សង្ខេបខ្លឹមសារឱ្យខ្លីមានអត្ថន័យគ្រប់គ្រាន់)

12. យោង (ករណីលិខិតពាក់ព័ន្ធនឹងគម្យជន)

13. លិខិតភ្ជាប់ (ករណីមានឯកសារពាក់ព័ន្ធជាសម្អាង ឬភស្តុតាង)

14. អធិប្បាយខ្លឹមសារ

15. ការបញ្ជាក់ (សំណូមពរ)

16. សម្តែងការគួរសម។

**គ. ផ្នែកបញ្ចប់**

17. មុខងារម្ចាស់លិខិត (បេសកៈ)

18. ហត្ថលេខា ឈ្មោះ និងត្រា

19. ចម្លងជូន ឬកន្លែងទទួល។

## ១.៤.ការបង្កើតរដ្ឋ និងលិខិតបទដ្ឋាន[9]

### ១.៤.១.ការបង្កើតរដ្ឋ

រដ្ឋ ឬប្រទេសនីមួយៗ ដែលកើតឡើងវាអាស្រ័យទៅលើ ការរួមរស់នៃមនុស្សដែលមានភាសា

[9] https://gdia.mef.gov.kh/wp-content/uploads/2017/01/9A.pdf [18, June 24]

ទំនៀមទំលាប់ វប្បធម៌ សុជីវធម៌ និងរបបសេដ្ឋកិច្ចពលរដ្ឋដូចគ្នា។ ការរួមរស់នៅផ្តុំគ្នាច្រើននេះយើងចែកចេញជាបីក្រុមធំទៀតគឺ:

- ក្រុមមនុស្សចំនួនតូចរស់នៅបង្កើតបានជាក្រុម
- ក្រុមមនុស្សចំនួនមធ្យមរស់នៅបង្កើតបានជាសង្គម ឬកុលសម្ព័ន្ធ
- ក្រុមមនុស្សចំនួនច្រើនរស់នៅបង្កើតបានជារដ្ឋ ឬប្រទេស។

ដូច្នេះមានន័យថាមនុស្សបង្កើតបានជា ភូមិ ឃុំ ស្រុក ខេត្ត និងរដ្ឋ។ រដ្ឋមានលក្ខណៈពីរយ៉ាងគឺ៖

❖ **រដ្ឋមិនទាន់មានរបបនយោបាយណាមួយត្រូវមានលក្ខណៈដូចតទៅ:**
- មានប្រជាពលរដ្ឋរស់នៅ
- មានទឹកដី
- មានរដ្ឋាភិបាលដឹកនាំ

❖ **រដ្ឋមានប្រើរបបនយោបាយត្រូវមានលក្ខណៈដូចតទៅ:**
- មានព្រំដែនសីមានៃទឹកដី
- មានពលរដ្ឋរស់នៅជាអចិន្ត្រៃយ៍
  - បែងចែកសញ្ជាតិទុកជាប្រជាជាតិ
  - ប្រជាពលរដ្ឋបង់ពន្ធជូនរដ្ឋ
- មានរចនាសម្ព័ន្ធគ្រប់គ្រងរដ្ឋ
  - មានរដ្ឋធម្មនុញ្ញ ច្បាប់ និងបទប្បញ្ញត្តិផ្សេងៗ
  - មានប្រើទង់ជាតិ សញ្ញាជាតិ និងភ្លេងជាតិ
  - មានអត្តសញ្ញាណជាតិ
  - រដ្ឋាភិបាលដឹកនាំ
- មានអធិបតេយ្យភាពពេញលេញ
  - ការទទួលស្គាល់ជាអន្តរជាតិ

## ក. អំណាចកំពូលរបស់រដ្ឋ

គ្រប់រដ្ឋទាំងអស់ត្រូវមានស្ថាប័នជាតិជាន់ខ្ពស់បីសម្រាប់ចាត់ចែងមុខការទូទៅទាំងមូលក្នុងរដ្ឋដោយមិនអាចអវត្តមានអំណាចណាមួយឡើយដូចជា:

- អំណាចនីតិបញ្ញត្តិ (ចេញពីរដ្ឋសភា និងព្រឹទ្ធសភា)
- អំណាចនីតិប្រតិបត្តិ (ចេញពីរដ្ឋាភិបាល)
- អំណាចតុលាការ (ចេញពីតុលាការឯករាជ្យគ្រប់ជាន់ថ្នាក់)

ស្ថាប័នជាតិទាំងបីនេះវាធ្វើការទំនាក់ទំនងគ្នាតាមរយៈលិខិតបទដ្ឋានទៅវិញទៅមក គឺពីស្ថាប័នមួយទៅស្ថាប័នមួយ ពីក្រសួងមួយទៅក្រសួងមួយ ពីអង្គភាពមួយទៅអង្គភាពមួយ។ ប្រព័ន្ធអំណាចកំពូលទាំងបីជាគ្រឹះសំខាន់បំផុត ឬជាក្បាលម៉ាស៊ីនរបស់រដ្ឋ។

**ខ. ប្រភេទនៃអំណាចបែងចែក**

គ្រប់រដ្ឋដើម្បីឲ្យមានការងាយស្រួលក្នុងការអនុវត្តន៍ការងារគ្រប់គ្រងឲ្យមានប្រសិទ្ធភាព គេត្រូវចែកអំណាចជាបីប្រភេទគឺ៖

- ➢ អំណាចកណ្តាល
- ➢ អំណាចបែងចែក
- ➢ អំណាចផ្តាច់មុខ

- **អំណាចកណ្តាល**: អំណាចនេះរាជរដ្ឋាភិបាលបានប្រគល់ឲ្យក្រសួងមហាផ្ទៃ ដើម្បីគ្រប់គ្រងលើប្រជាពលរដ្ឋ និងមន្ត្រីរាជការទាំងអស់ដែលរស់នៅក្នុងរដ្ឋទាំងមូល។
- **អំណាចបែងចែក**: រាជរដ្ឋាភិបាលបានប្រគល់ឲ្យគ្រប់ក្រសួងទាំងអស់ក្នុងប្រទេសគ្រប់គ្រងតាមក្រសួងនីមួយៗមិនអាចទៅគ្រប់គ្រងក្រសួងនានា ឬគ្រប់គ្រងលើប្រជាពលរដ្ឋបានឡើយ លើកលែងតែក្រសួងមហាផ្ទៃចេញ។
- **អំណាចផ្តាច់មុខ**: អំណាចនេះប្រទេសយើងមិនបានអនុវត្តទេ(គេអនុវត្តនៅសហរដ្ឋអាមេរិកសព្វថ្ងៃ)។

### ១.៤.២.លិខិតបទដ្ឋាន

#### ១.៤.២.១.និយមន័យ

លិខិតបទដ្ឋាន ជាអត្ថបទច្បាប់ បទបញ្ជា លិខិតស្នាម ដែលបានចេញដោយស្ថាប័នរដ្ឋ ឬក្រសួងមានសមត្ថកិច្ចក្នុងការគ្រប់គ្រង និងទំនាក់ទំនងគ្នាក្នុងផលប្រយោជន៍សាធារណៈឲ្យមានសន្តិសុខ សុខមាលភាពពលរដ្ឋ ទំនាក់ទំនងការទូត និងការពារជាតិ។

#### ១.៤.២.២.ប្រភេទលិខិតបទដ្ឋាន

លិខិតបទដ្ឋានចែកចេញជា៣ប្រភេទគឺ លិខិតគតិយុត្តិ លិខិតរដ្ឋបាល និងលិខិតឯកជន។

❖ **លិខិតគតិយុត្តិ**

លិខិតគតិយុត្តិ ជាលិខិតដែលកំណត់ជាក្បួនច្បាប់ មានអនុភាពគតិយុត្តិចាប់បង្ខំឲ្យអនុវត្តក្នុងការគ្រប់គ្រងសង្គម គ្រប់គ្រងរដ្ឋលើគ្រប់វិស័យមាន នយោបាយ សេដ្ឋកិច្ច វប្បធម៌ សង្គម....។

**ប្រភេទលិខិតគតិយុត្តិ**: លិខិតគតិយុត្តិមាន ច្បាប់ ព្រះរាជក្រម ព្រះរាជក្រឹត្យ អនុក្រឹត្យ ប្រកាសសេចក្តីសម្រេច សារាចរ ដីកាអាជ្ញាធរដែនដី...។

❖ **លិខិតរដ្ឋបាល**

រដ្ឋនីមួយៗ រដ្ឋាភិបាលនីមួយៗ ក្រសួងនីមួយៗ អង្គភាពនីមួយៗ គេធ្វើការទាក់ទងគ្នាតាមរយៈលិខិតស្នាមទាំងអស់ ដើម្បីជៀសវាងក្នុងការភាន់ច្រឡំ ឬភ្លេចចោលនូវសំណុំរឿងអ្វីមួយ ឬក៏ការកែលុបប្រការណាមួយ។

**ប្រភេទលិខិតរដ្ឋបាលៈ** លិខិតរដ្ឋបាលវាមានទម្រង់ និងសណ្ឋានខុសប្លែកគ្នាដូចតទៅៈ លិខិតប្រើផ្លូវការធម្មតា ដីកាបញ្ជូន ដីកាត្រូវឆ្លើយតម លិខិតអញ្ជើញ របាយការណ៍ កិច្ចសន្យា លិខិតបញ្ជាបេសកកម្ម កំណត់ហេតុ លិខិតបង្គាប់ការ សេចក្តីជូនដំណឹង ។ល។

❖ **លិខិតឯកជន**

លិខិតឯកជន ជាលិខិតស្នាមដែលគេប្រើប្រាស់សម្រាប់កិច្ចការផ្ទាល់ខ្លួនរួចសរសេរទៅកាន់បុគ្គល ឬស្ថាប័នដែលមានទំនាក់ទំនងនឹងខ្លួន។

**ប្រភេទលិខិតឯកជនៈ** លិខិតឯកជនវាមានទម្រង់ និងសណ្ឋានខុសប្លែកគ្នាដូចតទៅៈ ពាក្យសុំបម្រើ ការងារ ពាក្យសុំច្បាប់ឈប់សំរាក ពាក្យបណ្តឹងទូទៅ លិខិតសួរសុខទុក្ខ លិខិតជូនពរ លិខិតចូលរួម មរណៈទុក្ខ លិខិតសរសើរ លិខិតអបអរសាទរ លិខិតឆ្លើយតបវិញ លិខិតជូនពរ បុណ្យខួបកំណើត ។ល។

## ១.៥.ប្រព័ន្ធគ្រប់គ្រងរដ្ឋបាលថ្នាក់ជាតិនិងថ្នាក់ក្រោមជាតិ

### ១.៥.១.រដ្ឋបាលថ្នាក់ជាតិ

រដ្ឋបាលថ្នាក់ជាតិ ជាអង្គរដ្ឋបាលដែលប្រមូលផ្តុំនូវអាជ្ញាធររួមចូលគ្នានៃអំណាចនីតិប្រតិបត្តិ ដែលទទួលបន្ទុករៀបចំ និងដឹកនាំប្រទេស។ វាត្រូវបានកំណត់ឲ្យមានអង្គរដ្ឋបាល ពីរលំដាប់ដូចជាៈ

- ព្រះមហាក្សត្រ
- រាជរដ្ឋាភិបាល។

**+ព្រះមហាក្សត្រ**

- ➢ ព្រះមហាក្សត្រជាអាជ្ញាធររដ្ឋបាលមួយខ្ពស់បំផុត ក្នុងឋានៈជាព្រះប្រមុខរដ្ឋ
- ➢ តាមមាត្រា៧នៃរដ្ឋធម្មនុញ្ញឆ្នាំ១៩៩៣ ចែងថាព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជាទ្រង់គ្រងរាជសម្បត្តិ ប៉ុន្តែទ្រង់មិនកាន់អំណាចឡើយ
- ➢ បញ្ញត្តិមាត្រា៧ បានហាមឃាត់ចំពោះព្រះមហាក្សត្រក្នុងការអនុវត្តអំណាចផ្នែកនយោបាយ
- ➢ ទន្ទឹមនឹងនេះរដ្ឋធម្មនុញ្ញក៏បានផ្តល់ឲ្យទ្រង់នូវអំណាចផ្នែករដ្ឋបាលលើកិច្ចការមួយចំនួនដូចខាងក្រោមៈ

- ព្រះមហាក្សត្រទ្រង់តែងតាំងនាយករដ្ឋមន្ត្រី និងទ្រង់តែងតាំងគណៈរដ្ឋមន្ត្រីទាំងមូល

- តាមសេចក្តីស្នើរបស់គណៈរដ្ឋមន្ត្រី ព្រះមហាក្សត្រទ្រង់ឡាយព្រះហស្តលេខាលើព្រះរាជក្រឹត្យ តែងតាំង ផ្លាស់ប្តូរ ឬបញ្ចប់ភារកិច្ចមន្ត្រីជាន់ខ្ពស់ស៊ីវិល យោធា ឯកអគ្គរាជទូត ប្រេសិតវិសាមញ្ញ និងពេញសមត្ថភាព។
- តាមសេចក្តីស្នើរបស់ឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម ព្រះមហាក្សត្រទ្រង់ឡាយព្រះហស្តលេខាលើព្រះរាជក្រឹត្យ តែងតាំង ផ្លាស់ប្តូរ ឬដកហូតចៅក្រមផ្នែកយុត្តាធិការ។
- ទ្រង់ជាមេបញ្ជាការកំពូលនៃកងយោធពលខេមរភូមិន្ទ
- ទ្រង់គង់ជាព្រះអធិបតីនៃឧត្តមក្រុមប្រឹក្សាការពារជាតិ
- ទ្រង់មានព្រះរាជសិទ្ធិបន្ធូរបន្ថយទោស និងលើកលែងទោស
- ឧត្តមប្រឹក្សានៃអង្គចៅក្រម ស្ថិតក្រោមព្រះរាជាធិបតីភាពនៃព្រះមហាក្សត្រ
- ទ្រង់ទទួលសារតាំងឯកអគ្គរាជទូត ឬឯកអគ្គរដ្ឋទូត និងប្រេសិតវិសាមញ្ញនិងពេញសមត្ថភាពនៃប្រទេសក្រៅមកប្រចាំព្រះរាជាណាចក្រកម្ពុជា
- ទ្រង់ឡាយព្រះហស្តលេខាលើសន្ធិសញ្ញា និងអនុសញ្ញាអន្តរជាតិហើយទ្រង់ប្រទានសច្ចាប័នលើសន្ធិសញ្ញា និងអនុសញ្ញាក្រោយពីបានទទួលការអនុម័តយល់ព្រមពីរដ្ឋសភា និងព្រឹទ្ធសភា
- ព្រះមហាក្សត្រទ្រង់ឡាយព្រះហស្តលេខាលើព្រះរាជក្រមប្រកាសឱ្យប្រើរដ្ឋធម្មនុញ្ញច្បាប់ ដែលរដ្ឋសភាបានអនុម័ត និងព្រឹទ្ធសភាបានពិនិត្យចប់សព្វគ្រប់រួចហើយ
- ព្រះមហាក្សត្រត្រូវរំលាយរដ្ឋសភា ក្រោយពីព្រះអង្គទ្រង់បានទទួលការស្នើពីនាយករដ្ឋមន្ត្រី និងបន្ទាប់ពីទ្រង់បានការយល់ព្រមពីប្រធានរដ្ឋសភា
- សមាជិកព្រឹទ្ធសភាចំនួន២រូប ត្រូវបានចាត់តាំងដោយព្រះមហាក្សត្រ
- ទ្រង់បង្កើត និងប្រទានគ្រឿងឥស្សរិយយសជាតិ
- ទ្រង់ប្រកាសសង្គ្រាមក្រោយការអនុម័តរបស់រដ្ឋសភា និងព្រឹទ្ធសភា
- សមាជិកក្រុមប្រឹក្សាធម្មនុញ្ញចំនួន៣រូបត្រូវតែងតាំងដោយព្រះមហាក្សត្រ។

**+រាជរដ្ឋាភិបាល**

- ➢ រាជរដ្ឋាភិបាល ជាអង្គការនីតិប្រតិបត្តិមានសមត្ថកិច្ចកំណត់ និងអនុវត្តនយោបាយរបស់រដ្ឋស្របតាមគោលការណ៍ដែលចែងក្នុងរដ្ឋធម្មនុញ្ញ
- ➢ រាជរដ្ឋាភិបាល ដឹកនាំកិច្ចការទូទៅរបស់រដ្ឋស្របតាមកម្មវិធីនយោបាយរបស់ខ្លួន
- ➢ រាជរដ្ឋាភិបាល ត្រូវបានកំណត់នូវលំដាប់រដ្ឋបាលដូចជាៈ
- គណៈរដ្ឋមន្ត្រី
- ទីស្តីការគណៈរដ្ឋមន្ត្រី
- ក្រសួង និងរដ្ឋលេខាធិការដ្ឋាន។

+ **គណៈរដ្ឋមន្ត្រី**

➢ តាមមាត្រា១១៨ថ្មីមួយនៃរដ្ឋធម្មនុញ្ញចែងថា គណៈរដ្ឋមន្ត្រីជារាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា។

- គណៈរដ្ឋមន្ត្រីត្រូវបានដឹកនាំដោយ នាយករដ្ឋមន្ត្រី១រូប អមដោយឧបនាយករដ្ឋមន្ត្រី ព្រមទាំងទេសរដ្ឋមន្ត្រី និងរដ្ឋមន្ត្រីជាសមាជិក
- អង្គប្រជុំរបស់គណៈរដ្ឋមន្ត្រី មានអង្គប្រជុំធំ និងអង្គប្រជុំពិនិត្យស្រាវជ្រាវ
- អង្គប្រជុំធំគឺជាកិច្ចប្រជុំពេញអង្គគណៈរដ្ឋមន្ត្រី ដើម្បីពិនិត្យនិងសម្រេចដោះស្រាយរាល់កិច្ចការទូទៅរបស់រាជរដ្ឋាភិបាល
- អង្គប្រជុំធំត្រូវដឹកនាំដោយនាយករដ្ឋមន្ត្រី នាយករដ្ឋមន្ត្រីអាចប្រគល់ភារកិច្ចជូនឧបនាយករដ្ឋមន្ត្រីដឹកនាំអង្គប្រជុំពិនិត្យស្រាវជ្រាវបាន។

➢ **គណៈរដ្ឋមន្ត្រី មានមុខងារដូចខាងក្រោម៖**

- ចូលរួមរាយការណ៍ទូលថ្វាយព្រះមហាក្សត្រ ទ្រង់ជ្រាបអំពីសភាពការណ៍របស់ប្រទេសជាតិពីរដងក្នុង១ខែជាមួយនាយករដ្ឋមន្ត្រី
- លើកសំណើទៅព្រះមហាក្សត្រឲ្យទ្រង់តែងតាំង ផ្លាស់ប្តូរ និងបញ្ចប់តួនាទីមន្ត្រីជាន់ខ្ពស់ស៊ីវិល និងយោធា ទេសាភិបាល ទេសាភិបាលរងធនាគារជាតិនៃកម្ពុជាឯកអគ្គរាជទូត ប្រេសិតវិសាមញ្ញ និងពេញសមត្ថភាព
- លើកសំណើទៅព្រះមហាក្សត្រឲ្យទ្រង់ឡាយព្រះហស្តលេខាលើព្រះរាជក្រម ដែលប្រកាសឱ្យប្រើច្បាប់
- លើកសំណើទៅព្រះមហាក្សត្រឲ្យទ្រង់បង្កើត និងប្រទានគ្រឿងឥស្សរិយយសជាតិ
- ពិនិត្យ និងសម្រេចដោះស្រាយរាល់កិច្ចការទូទៅរបស់រាជរដ្ឋាភិបាល។

➢ **នាយករដ្ឋមន្ត្រី ដែលជាប្រមុខរាជរដ្ឋាភិបាល មានសមត្ថកិច្ចដូចខាងក្រោម៖**

- ដឹកនាំ បញ្ជារាល់សកម្មភាពការងាររបស់រាជរដ្ឋាភិបាល
- ដឹកនាំការងាររបស់គណៈរដ្ឋមន្ត្រី កោះប្រជុំ និងធ្វើជាអធិបតីនៃកិច្ចប្រជុំពេញអង្គរបស់គណៈរដ្ឋមន្ត្រី។ រដ្ឋធម្មនុញ្ញបានអនុញ្ញាតឱ្យនាយករដ្ឋមន្ត្រីរំលែកអំណាច របស់ខ្លួនឱ្យទៅសមាជិកនៃរាជរដ្ឋាភិបាលណាម្នាក់ក៏បាន(មាត្រា១២៤)។
- អំណាចចេញបទបញ្ជា ដើម្បីណែនាំដល់មន្ត្រីក្រោមឱវាទ, សាធារណជន និងដើម្បីរក្សាសណ្តាប់ធ្នាប់សាធារណៈ ក្នុងករណី ឬស្ថានភាពជាក់ស្តែងណាមួយដែលគ្មានច្បាប់អនុក្រឹត្យប្រកាស និងលិខិតបទដ្ឋានគតិយុត្តណាមួយបានចែង។
- ដឹកនាំការចរចា និងចុះហត្ថលេខាលើកិច្ចព្រមព្រៀងនានា

- លើកសំណើថ្វាយព្រះមហាក្សត្រ ឲ្យទ្រង់តែងតាំង ផ្លាស់ប្តូរ និងបញ្ចប់ភារកិច្ចដោយព្រះរាជក្រឹត្យនូវមុខតំណែងមន្ត្រីជាន់ខ្ពស់ស៊ីវិល យោធិននៃកងយោធពលខេមរភូមិន្ទ និងមន្ត្រីនគរបាលជាតិដូចខាងក្រោមៈ
  - ទេសាភិបាល ទេសាភិបាលរងធនាគារជាតិនៃកម្ពុជា
  - អគ្គលេខាធិការក្រសួង អគ្គនាយកក្រសួង ឬមុខតំណែងប្រហាក់ប្រហែល
  - អភិបាលនៃគណៈអភិបាលរាជធានី-ខេត្ត
  - ឯកអគ្គរាជទូត ឬមុខតំណែងប្រហាក់ប្រហែល
  - ប្រេសិតវិសាមញ្ញនិងពេញសមត្ថភាព
  - អគ្គមេបញ្ជាការ អគ្គមេបញ្ជាការរង និងនាយសេនាធិការចម្រុះនៃកងយោធពលខេមរភូមិន្ទ
  - អគ្គស្នងការនគរបាលជាតិ ។
- អំណាចតែងតាំង ផ្លាស់ប្តូរ បញ្ចប់ភារកិច្ច ដោយអនុក្រឹត្យនូវមន្ត្រីជាន់ខ្ពស់ស៊ីវិល យោធិន នគរបាលជាតិ ដូចជាៈ អគ្គនាយករង អភិបាលរងរាជធានីខេត្ត អភិបាលក្រុងស្រុកខណ្ឌ ប្រធាននាយកដ្ឋានវរៈសេនីយ៍ឯក និងថ្នាក់ប្រហាក់ប្រហែល
- មានសិទ្ធិស្នើសុំឲ្យមានការពិនិត្យធម្មនុញ្ញភាព និងធ្វើវិសោធន៍កម្មរដ្ឋធម្មនុញ្ញ
- ស្នើសុំទៅព្រះមហាក្សត្រឱ្យទ្រង់រំលាយរដ្ឋសភា បន្ទាប់ពីមានការទម្លាក់រាជរដ្ឋាភិបាលពីរដងក្នុងរយៈពេល១២ខែ
- អាចស្នើសុំឲ្យរដ្ឋសភាប្រជុំជាវិសាមញ្ញ
- មានសិទ្ធិផ្តួចផ្តើមគំនិតធ្វើច្បាប់
- មានអំណាចក្នុងការចូលរួមជ្រើសរើសព្រះមហាក្សត្រ
- នាយករដ្ឋមន្ត្រីមានអង្គភាពជំនួយការមួយ គឺ៉ខុទ្ទកាល័យសម្តេចតេជោ នាយករដ្ឋមន្ត្រី៉។

**+ទីស្តីការគណៈរដ្ឋមន្ត្រី**

- ទីស្តីការគណៈរដ្ឋមន្ត្រីត្រូវបានបង្កើតឡើងដើម្បីធ្វើជាសេនាធិការជូនរាជរដ្ឋាភិបាល សម្រាប់សម្របសម្រួលការងារប្រចាំថ្ងៃរបស់គណៈរដ្ឋមន្ត្រី ក្រោមការដឹកនាំរបស់នាយករដ្ឋមន្ត្រី
- រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី មានតួនាទីគ្រប់គ្រង និងចាត់ចែងការងារទីស្តីការគណៈរដ្ឋមន្ត្រី
- ទីស្តីការគណៈរដ្ឋមន្ត្រីមានរដ្ឋលេខាធិការ និងអនុរដ្ឋលេខាធិការមួយចំនួនតាមការចាំបាច់
- ទីស្តីការគណៈរដ្ឋមន្ត្រីមានរដ្ឋលេខាធិការប្រចាំការ១រូប ដែលចាត់តាំងដោយនាយករដ្ឋមន្ត្រីតាមសំណើរបស់រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី ដើម្បីជួយការងារទូទៅប្រចាំថ្ងៃរបស់ទីស្តីការគណៈរដ្ឋមន្ត្រី។

➢ តាមអនុក្រឹត្យលេខ ១១៦ អនក្រ.បក ចុះថ្ងៃទី៦ ខែកញ្ញា ឆ្នាំ២០១៨ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃទីស្តីការគណៈរដ្ឋមន្ត្រី បានកំណត់ឲ្យទីស្តីការគណៈរដ្ឋមន្ត្រីមានរចនាសម្ព័ន្ធចំណុះដូចជា៖
- ខុទ្ទកាល័យ
- អគ្គនាយកដ្ឋាន
  - អគ្គនាយកដ្ឋានរដ្ឋបាលនិងហិរញ្ញវត្ថុ
  - អគ្គនាយកដ្ឋានសម្របសម្រួលកិច្ចការទូទៅ
  - អគ្គនាយកដ្ឋានសហប្រតិបត្តិការអន្តរជាតិ
  - អគ្គនាយកដ្ឋានសម្របសម្រួលកិច្ចការផ្ទៃក្នុង
  - អគ្គនាយកដ្ឋានសេដ្ឋកិច្ចនិងទេសចរណ៍
  - អគ្គនាយកដ្ឋានកិច្ចការសង្គម
  - អគ្គនាយកដ្ឋានផលិតកម្ម រៀបចំដែនដី នគរូបនីយកម្ម និងសំណង់
  - អគ្គនាយកដ្ឋានរាជកិច្ចនិងតម្កល់ឯកសារជាតិ។
- នាយកដ្ឋានសវនកម្មផ្ទៃក្នុង
- រដ្ឋលេខាធិការដ្ឋានអាកាសចរណ៍ស៊ីវិល និងអង្គភាពចំណុះទីស្តីការគណៈរដ្ឋមន្ត្រី។

**+ក្រសួង និងរដ្ឋលេខាធិការដ្ឋាន**

➢ ការបង្កើតក្រសួងត្រូវកំណត់ដោយច្បាប់។ គោលការណ៍ក្រសួងជាស្ថាប័នរបស់រាជរដ្ឋាភិបាលដែលត្រូវបង្កើតឡើង ដើម្បីទទួលបន្ទុកការងារតាមវិស័យ។

➢ ចំពោះរដ្ឋលេខាធិការដ្ឋានអាកាសចរណ៍ស៊ីវិល ត្រូវបានកំណត់ឲ្យស្ថិតនៅក្រោមចំណុះទីស្តីការគណៈរដ្ឋមន្ត្រីក្រោមការគ្រប់គ្រងរបស់នាយករដ្ឋមន្ត្រី។

- ក្រសួងត្រូវដឹកនាំដោយរដ្ឋមន្ត្រី១រូប មានរដ្ឋលេខាធិការ និងអនុរដ្ឋលេខាធិការមួយតាមការចាំបាច់ដែលត្រូវបំពេញភារកិច្ចតាមការប្រគល់ពីរដ្ឋមន្ត្រីសាមី។
- ក្រសួងនីមួយៗមានរដ្ឋលេខាធិការប្រចាំការ១រូប ដែលចាត់តាំងដោយនាយករដ្ឋមន្ត្រីតាមសំណើរបស់រដ្ឋមន្ត្រីនៃក្រសួងសាមី ដើម្បីជួយការងារទូទៅប្រចាំថ្ងៃរបស់ក្រសួង។

➢ **រដ្ឋមន្ត្រី មានសមត្ថកិច្ចមួយចំនួន ដូចជា៖**

- ចេញប្រកាស សេចក្តីសម្រេច សារាចរ និងសេចក្តីណែនាំ។
- ដឹកនាំការងារក្នុងក្រសួង និងគ្រប់គ្រងមន្ត្រីរាជការ បុគ្គលិក ដែលជាភ្នាក់ងាររដ្ឋបាលនៅក្រោមឱវាទរបស់ខ្លួន។
- លើកសំណើតែងតាំង ផ្លាស់ប្តូរ និងបញ្ចប់ភារកិច្ចមន្ត្រីរាជការក្រោមឱវាទចាប់ពីថ្នាក់ប្រធាននាយកដ្ឋានថ្នាក់ប្រហាក់ប្រហែលឡើងទៅថ្នាក់វរសេនីយ៍ឯកនៃកងយោធពលខេមរភូមិន្ទ និងនគរបាលជាតិ។

- តែងតាំង ផ្លាស់ប្តូរ និងបញ្ចប់ភារកិច្ចមន្ត្រីរាជការក្រោមឱវាទចាប់ពីថ្នាក់ក្រោមប្រធាននាយកដ្ឋាន ថ្នាក់ប្រហាក់ប្រហែល និងថ្នាក់ក្រោមវរសេនីយ៍ឯកនៃកង យោធពលខេមរភូមិន្ទនិងនគរបាលជាតិ។

➢ **បច្ចុប្បន្ន មានក្រសួងចំនួន២៧ ដូចជា៖**

១-ក្រសួងមហាផ្ទៃ

២-ក្រសួងការពារជាតិ

៣-ក្រសួងទំនាក់ទំនងរដ្ឋសភា ព្រឹទ្ធសភា និងអធិការកិច្ច

៤-ក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ

៥-ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

៦-ក្រសួងព័ត៌មាន

៧-ក្រសួងសុខាភិបាល

៨-ក្រសួងឧស្សាហកម្ម និងសិប្បកម្ម

៩-ក្រសួងផែនការ

១០-ក្រសួងពាណិជ្ជកម្ម

១១-ក្រសួងអប់រំ យុវជន និងកីឡា

១២-ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ

១៣-ក្រសួងបរិស្ថាន

១៤-ក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ

១៥-ក្រសួងអភិវឌ្ឍន៍ជនបទ

១៦-ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ

១៧-ក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍

១៨-ក្រសួងធម្មការ និងសាសនា

១៩-ក្រសួងកិច្ចការនារី

២០-ក្រសួងសាធារណការ និងដឹកជញ្ជូន

២១-ក្រសួងយុត្តិធម៌

២២-ក្រសួងទេសចរណ៍

២៣-ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់

២៤-ក្រសួងធនធានទឹក និងឧតុនិយម

២៥-ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា

២៦-ក្រសួងមុខងារសាធារណៈ

២៧-ក្រសួងរ៉ែនិងថាមពល

## ១.៥.២.រដ្ឋបាលថ្នាក់ក្រោមជាតិ[10]

### ១.៥.២.១. គោលការណ៍

យោងមាត្រា២ នៃច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ រដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ត្រូវគ្រប់គ្រងតាមគោលការណ៍នៃរដ្ឋបាលឯកភាព ដើម្បីបង្កើតជំរុញ និងធ្វើឱ្យមានចីរភាពដល់ការអភិវឌ្ឍ តាមបែបប្រជាធិបតេយ្យតាមរយៈនយោបាយវិមជ្ឈការ និងវិសហមជ្ឈការ។

- **រដ្ឋបាលឯកភាព** គឺជាការរៀបចំឲ្យមានក្រុមប្រឹក្សានៅរដ្ឋបាលថ្នាក់ក្រោមជាតិ ដែលអាចម្ចាស់ការក្នុងការគ្រប់គ្រង ចាត់ចែងមុខងារ និងធនធាន ហើយក្រុមប្រឹក្សានីមួយៗមានសមត្ថភាពសម្របសម្រួលប្រកបដោយប្រសិទ្ធភាពនូវសកម្មភាពនៃការផ្តល់សេវាកម្ម និងការអភិវឌ្ឍដែលធ្វើឡើងដោយក្រសួងស្ថាប័ន នៅក្នុងដែនសមត្ថកិច្ចរបស់ក្រុមប្រឹក្សា សំដៅឆ្លើយតបសេចក្តីត្រូវការរបស់ប្រជាពលរដ្ឋនៅក្នុងមូលដ្ឋាន។

- **ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យរួមមានសមាសភាពដូចខាងក្រោម៖**
  - ភាពជាតំណាងសាធារណៈ
  - ស្វ័យភាពរបស់មូលដ្ឋាន
  - ការពិគ្រោះយោបល់ និងការចូលរួម
  - ការឆ្លើយតប និងគណនេយ្យភាព
  - ការលើកកម្ពស់គុណភាពជីវិតរបស់ប្រជាជននៅមូលដ្ឋាន
  - ការលើកស្ទួយសមធម៌
  - តម្លាភាព និងសុចរិតភាព

[10] (សៀវភៅការគ្រប់គ្រងរដ្ឋបាល,ឆ្នាំ២០២០,ទស្សនទាននៃកំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការ,ទំព័រ៤) ក្រុង_សៀវភៅគ្រប់គ្រងរដ្ឋបាលក្រុង.pdf (ncdd.gov.kh)

- វិធានការប្រឆាំងអំពើពុករលួយ និងការរំលោភអំណាច។

គោលការណ៍ទាំង៨ខាងលើ គឺជាការកំណត់អំពីមូលដ្ឋានគ្រឹះដែលត្រូវដាក់បញ្ចូលទៅក្នុងកិច្ចដំណើរការនៃប្រព័ន្ធអភិបាលកិច្ចនៅថ្នាក់ក្រោមជាតិ តាមរយៈការរៀបចំរចនាសម្ព័ន្ធប្រព័ន្ធបែបបទនីតិវិធីបំពេញការងាររបស់រដ្ឋបាលថ្នាក់ក្រោមជាតិក៏ដូចជាការរៀបចំច្បាប់ និងលិខិតបទដ្ឋាននានា។ ខ្លឹមសារសំខាន់ៗនៃគោលការណ៍ទាំង៨ មានដូចខាងក្រោម៖

**ទី១៖ ភាពជាតំណាងសាធារណៈ**

ការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាគ្រប់ថ្នាក់នៅថ្នាក់ក្រោមជាតិ តាមគោលការណ៍នៃការបោះឆ្នោតតាមបែបប្រជាធិបតេយ្យ សេរីពហុបក្ស គឺជាការផ្តល់ភាពជាតំណាងសាធារណៈដល់ក្រុមប្រឹក្សាជាប់ឆ្នោតគ្រប់លំដាប់ថ្នាក់នៃរដ្ឋបាលថ្នាក់ក្រោមជាតិ។ ក្រុមប្រឹក្សានីមួយៗត្រូវធ្វើសកម្មភាពនានាក្នុងនាមផលប្រយោជន៍ និងសេចក្តីត្រូវការរបស់ប្រជាពលរដ្ឋទាំងអស់ក្នុងមូលដ្ឋានរបស់ខ្លួន ដោយមិនមានការរើសអើងខាងនយោបាយ ពណ៌សម្បុរ ជំនឿ សាសនា ជនជាតិ និងទ្រព្យធននោះឡើយ។

**ទី២៖ ស្វ័យភាពរបស់មូលដ្ឋាន**

ស្វ័យភាពមូលដ្ឋានមានន័យថារដ្ឋបាលថ្នាក់ក្រោមជាតិមានសិទ្ធិធ្វើសេចក្តីសម្រេច និងអនុវត្តសេចក្តីសម្រេចរបស់ខ្លួន ដើម្បីបម្រើផលប្រយោជន៍ និងសេចក្តីត្រូវការរបស់ប្រជាពលរដ្ឋទាំងអស់ក្នុងមូលដ្ឋានរបស់ខ្លួនក្នុងដែនសមត្ថកិច្ចដែលច្បាប់បានកំណត់។

**ទី៣៖ ការពិគ្រោះយោបល់ និងការចូលរួម**

ការពិគ្រោះយោបល់ និងការចូលរួម គឺជាកិច្ចដំណើរការដ៏សំខាន់សម្រាប់រដ្ឋបាលថ្នាក់ក្រោមជាតិ ស្វែងយល់អំពីបំណងប្រាថ្នា និងសេចក្តីត្រូវការរបស់សហគមន៍ផ្សេងៗគ្នាក្នុងមូលដ្ឋានរបស់ខ្លួន ដើម្បីរដ្ឋបាលថ្នាក់ក្រោមជាតិដាក់បញ្ចូលនូវផលប្រយោជន៍ និងសេចក្តីត្រូវការដែលមានលក្ខណៈផ្សេងៗគ្នាក្នុងមូលដ្ឋាន (ឧទាហរណ៍ តម្រូវការរបស់ស្ត្រី កុមារ យុវជន មនុស្សចាស់ជរា ជនជាតិ ជនក្រីក្រ... ជាដើម) សំដៅធ្វើសេចក្តីសម្រេចឆ្លើយតបបានកាន់តែប្រសើរទៅនឹងផលប្រយោជន៍ និងសេចក្តីត្រូវការរបស់ប្រជាពលរដ្ឋទាំងអស់នៅក្នុងមូលដ្ឋានរបស់ខ្លួន។

**ទី៤៖ ការឆ្លើយតប និងគណនេយ្យភាព**

ក្នុងនាមជាតំណាងប្រជាពលរដ្ឋក្រុមប្រឹក្សាត្រូវឆ្លើយតបចំពោះប្រជាពលរដ្ឋរបស់ខ្លួនក្នុងការធ្វើគោលនយោបាយ សេចក្តីសម្រេចចិត្ត សកម្មភាព និងការបំពេញការងាររបស់ខ្លួនប្រកបដោយការទទួលខុសត្រូវនូវអ្វីដែលខ្លួនបានអនុវត្ត។ ក្រុមប្រឹក្សាក៏ទទួលខុសត្រូវផងដែរ ចំពោះរាជរដ្ឋាភិបាលក្នុងការប្រតិបត្តិតាមរដ្ឋធម្មនុញ្ញ និងច្បាប់នានា។

**ទី៥៖ ការលើកកម្ពស់គុណភាពជីវិតរបស់ប្រជាពលរដ្ឋនៅមូលដ្ឋាន**

ការលើកកម្ពស់គុណភាពជីវិតរបស់ប្រជាពលរដ្ឋនៅមូលដ្ឋាន គឺជាកិច្ចខិតខំប្រឹងប្រែងដើម្បីបង្កើត និងធ្វើឲ្យមាននិរន្តរភាពនូវបរិយាកាសមួយប្រកបដោយសន្តិភាព សុវត្ថិភាព សុខុមាលភាព លើកកម្ពស់ការអភិវឌ្ឍសង្គម សេដ្ឋកិច្ច លើកកម្ពស់ផាសុកភាព និងគុណភាពជីវិតនៃប្រជាពលរដ្ឋក្នុងមូលដ្ឋាន។ តម្រូវការរបស់ប្រជាពលរដ្ឋមានលក្ខណៈផ្សេងៗគ្នាទៅតាមសហគមន៍ និងក្រុមប្រជាពលរដ្ឋដែលមានដូចជា យុវជន ស្ត្រី កុមារ ជនពិការ ចាស់ជរា ជនជាតិដើម ភាគតិច ក្រុមជនក្រីក្រ ជាដើមហេតុនេះក្រុមប្រឹក្សាត្រូវខិតខំស្វែងយល់ឲ្យបានគ្រប់ជ្រុងជ្រោយពីតម្រូវការផ្សេងៗគ្នារបស់អ្នកទាំងនោះ តាមរយៈការលើកកម្ពស់ការពិគ្រោះយោបល់ និងការចូលរួម។ ទន្ទឹមនឹងនេះក្រុមប្រឹក្សាត្រូវខិតខំប្រើប្រាស់ធនធានដ៏មានកម្រិតរបស់ខ្លួនឲ្យមានប្រសិទ្ធភាព ដើម្បីឆ្លើយតបទៅនឹងតម្រូវការទាំងនោះ។

**ទី៦៖ ការលើកស្ទួយសមធម៌**

ការលើកស្ទួយសមធម៌ជាគោលការណ៍ ទន្ទឹមនឹងការលើកកម្ពស់ការឆ្លើយតប គណនេយ្យភាព និងការលើកកម្ពស់គុណភាព ជីវិតរបស់ប្រជាជន រដ្ឋបាលថ្នាក់ក្រោមជាតិនីមួយៗត្រូវលើកស្ទួយសមធម៌សង្គមក្នុងមូលដ្ឋានរបស់ខ្លួនផងដែរ។ ការលើកស្ទួយសមធម៌សង្គម គឺជាកិច្ចដំណើរការដែលតម្រូវឲ្យរដ្ឋបាលថ្នាក់ក្រោមជាតិប្រឹងប្រែង ធានាឲ្យមានការពិគ្រោះយោបល់ ការចូលរួមកាន់តែស៊ីជម្រៅជាមួយស្ត្រី កុមារ ក្រុមជនងាយរងគ្រោះ សហគមន៍ក្រីក្រ ជនជាតិភាគតិច។ល។ សំដៅធ្វើការផ្តល់សេវា និងការអភិវឌ្ឍឲ្យបានសមស្របបំផុតចំពោះក្រុមជនទាំងនោះ។ ក្នុងន័យនេះការផ្តល់សេវា និងការអភិវឌ្ឍត្រូវតែផ្តោតការយកចិត្តទុកដាក់ជាចម្បងដល់ក្រុមជនខាងលើនេះ ដើម្បីឲ្យក្រុមជនទាំងនេះទទួលបាននូវឱកាសកាន់តែច្រើន អត្ថប្រយោជន៍កាន់តែច្រើនពីការផ្តល់សេវា និងការអភិវឌ្ឍក្នុងមូលដ្ឋានរបស់ខ្លួន។

**ទី៧៖ តម្លាភាព និងសុចរិតភាព**

តម្លាភាព និងសុចរិតភាព គឺជាគោលការណ៍ស្នូលនៃអភិបាលកិច្ចល្អ។ កំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការតាមគោលការណ៍នៃការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ ត្រូវធានារៀបចំស្ថាប័នរដ្ឋបាលថ្នាក់ក្រោមជាតិគ្រប់ថ្នាក់ជាស្ថាប័នប្រកបដោយតម្លាភាព និងមានសុចរិតភាព។ តម្លាភាព និងសុចរិតភាពទាមទារត្រូវរៀបចំឲ្យមានរចនាសម្ព័ន្ធ ប្រព័ន្ធ និងនីតិវិធីច្បាស់លាស់សម្រាប់ស្ថាប័ននីមួយៗ ហើយថ្នាក់ដឹកនាំនៃស្ថាប័ននោះ ត្រូវមានការប្តេជ្ញាចិត្តក្នុងការកសាងស្ថាប័នរបស់ខ្លួនប្រកបដោយតម្លាភាព និងមានសុចរិតភាព។ ក្រុមប្រឹក្សាគណៈអភិបាលត្រូវមានការប្តេជ្ញាចិត្តកសាងរដ្ឋបាលរបស់ខ្លួនឲ្យក្លាយជារដ្ឋបាល ដែលមានលក្ខណៈបើកចំហមានតម្លាភាពដោយធានាឲ្យបានថាសមាជិកក្រុមប្រឹក្សាគ្រប់ៗរូប អភិបាល អភិបាលរងមន្ត្រី បុគ្គលិកទាំងអស់ត្រូវបំពេញការងារប្រកបដោយតម្លាភាព និងត្រូវប្រកាន់យកគោលការណ៍សុចរិតភាពក្នុងការបំពេញការងារ ការផ្តល់សេវា និងការអភិវឌ្ឍក្នុងមូលដ្ឋានរបស់ខ្លួន។ កិច្ចប្រជុំជាសាធារណៈរបស់ក្រុមប្រឹក្សាការប្រជុំគណៈអភិបាល ការកសាងរបៀបធ្វើការជាក្រុមក្នុងក្រុមប្រឹក្សា គណៈអភិបាល និងមន្ត្រីនៃរដ្ឋបាលរបស់

ខ្លួន ការរៀបចំ និងដាក់ឲ្យអនុវត្តប្រព័ន្ធត្រួតពិនិត្យការងារផ្ទៃក្នុង សម្រាប់រដ្ឋបាលថ្នាក់ក្រោមជាតិនីមួយៗ ការរៀបចំដាក់ឲ្យអនុវត្តនូវប្រព័ន្ធសវនកម្មផ្ទៃក្នុង ផ្ទៃក្រៅ និងប្រព័ន្ធនីតិវិធីនានាជាច្រើនដែលបានដាក់ឲ្យប្រើប្រាស់កន្លងមកនេះ គឺមានគោលបំណងគាំទ្រដល់ការលើកកម្ពស់តម្លាភាព និងសុចរិតភាពរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ។

**ទី៨៖ វិធានការប្រឆាំងអំពើពុករលួយ និងការរំលោភអំណាច**

ការប្រយុទ្ធប្រឆាំងអំពើពុករលួយ និងការរំលោភអំណាច គឺជាកាតព្វកិច្ចរបស់ស្ថាប័នសាធារណៈគ្រប់ថ្នាក់ ផ្នែកឯកជន សង្គមស៊ីវិល និងប្រជាពលរដ្ឋគ្រប់ៗរូប សំដៅកសាងសង្គមមួយប្រកបដោយភាពស្អាតស្អំ យុត្តិធម៌ ដើម្បីជានាឲ្យមានការអភិវឌ្ឍសង្គមប្រកបដោយចីរភាព និងសមធម៌។

### ១.៥.២.២. ការរៀបចំប្រព័ន្ធអភិបាលកិច្ចនៅថ្នាក់ក្រោមជាតិ[11]

**ក.ឋានៈផ្លូវច្បាប់**

មាត្រា ៩ នៃច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ និងមាត្រា ២ នៃច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់ បានកំណត់ឱ្យរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ និងឃុំ សង្កាត់ គឺជានីតិបុគ្គលនៃនីតិសាធារណៈ។ នីតិបុគ្គលនីមួយៗរួមមានដែនដី ប្រជាពលរដ្ឋនៅក្នុងដែនដី និងមានក្រុមប្រឹក្សាមួយជាតំណាងដែលកើតឡើងពីការបោះឆ្នោតជ្រើសរើសស្របតាមច្បាប់ស្តីពីការបោះឆ្នោត ជ្រើសរើសក្រុមប្រឹក្សារាជធានី ក្រុមប្រឹក្សាខេត្ត ក្រុមប្រឹក្សាក្រុង ក្រុមប្រឹក្សាស្រុក ក្រុមប្រឹក្សាខណ្ឌ និងច្បាប់ស្តីពីការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់។

ការផ្តល់ភាពជានីតិបុគ្គល ចំពោះរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ និងឃុំ សង្កាត់ គឺក្នុងគោលបំណងផ្តល់សិទ្ធិអំណាច មុខងារ ធនធាន និងទ្រព្យសម្បត្តិឱ្យដល់ក្រុមប្រឹក្សា ដើម្បីក្រុមប្រឹក្សាអាចគ្រប់គ្រងចាត់ចែងកិច្ចការនានានៅមូលដ្ឋាន សំដៅឆ្លើយតបទៅនឹងតម្រូវការរបស់ប្រជាពលរដ្ឋដែលជាម្ចាស់ឆ្នោត និងអភិវឌ្ឍមូលដ្ឋានប្រកបដោយចីរភាព ប្រសិទ្ធភាព និងសមធម៌។

**ខ. ក្រុមប្រឹក្សា**

ក្រុមប្រឹក្សានៅថ្នាក់ក្រោមជាតិរួមមាន ក្រុមប្រឹក្សារាជធានី ក្រុមប្រឹក្សាខេត្ត ក្រុមប្រឹក្សាក្រុង ក្រុមប្រឹក្សាស្រុក ក្រុមប្រឹក្សាខណ្ឌ ក្រុមប្រឹក្សាឃុំ សង្កាត់។ ក្រុមប្រឹក្សាឃុំ សង្កាត់ ត្រូវបានជ្រើសរើសឡើងតាមរយៈការបោះឆ្នោតជាសកល និងក្រុមប្រឹក្សារាជធានី ក្រុមប្រឹក្សាខេត្ត ក្រុមប្រឹក្សាក្រុង ក្រុមប្រឹក្សាស្រុក ក្រុមប្រឹក្សា ខណ្ឌ ត្រូវបានជ្រើសរើសឡើងតាមរយៈការបោះឆ្នោតជាអសកល។ ក្រុមប្រឹក្សានៃរដ្ឋបាលថ្នាក់ក្រោមជាតិមានអាណត្តិ ៥ឆ្នាំ និងត្រូវផុតកំណត់នៅពេលក្រុមប្រឹក្សាថ្មីចូលកាន់តំណែង។

[11] (សៀវភៅការគ្រប់គ្រងរដ្ឋបាល,ឆ្នាំ២០២០,ទស្សនទាននៃកំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការ,ទំព័រ៧)

ក្រុមប្រឹក្សាមានសិទ្ធិអំណាចធ្វើសេចក្តីសម្រេចខាងបញ្ញត្តិ និងសេចក្តីសម្រេចខាងប្រតិបត្តិ។ ក្រុមប្រឹក្សាប្រើប្រាស់សិទ្ធិអំណាចខាងបញ្ញត្តិតាមរយៈការចេញដីកា និងសិទ្ធិអំណាចខាងប្រតិបត្តិតាមរយៈការធ្វើសេចក្តីសម្រេចចិត្តនៅក្នុងកិច្ចប្រជុំក្រុមប្រឹក្សា។

**គ.បុគ្គលិក**

ក្រុមប្រឹក្សានីមួយៗមានបុគ្គលិករបស់ខ្លួន ដែលរួមមានបីប្រភេទដូចខាងក្រោម៖

- បុគ្គលិកដែលបានតែងតាំងដោយក្រុមប្រឹក្សា
- បុគ្គលិកដែលបានតែងតាំងឱ្យទៅបំពេញការងារជាមួយក្រុមប្រឹក្សា
- បុគ្គលិកដែលបានរៀបចំឡើងវិញឱ្យទៅបំពេញការងារជាមួយក្រុមប្រឹក្សា។

ក្រុមប្រឹក្សាត្រូវសម្រេចអំពីការតែងតាំង ការបណ្តេញចោល ការកម្រឹតប្រាក់បៀវត្ស និងអត្ថប្រយោជន៍ផ្សេងៗទៀតសម្រាប់មុខតំណែងបុគ្គលិករបស់ខ្លួន ស្របតាម ព្រះរាជក្រឹត្យលេខ នស/រកត/០៤១៦/៣៧៣ ចុះថ្ងៃទី០៤ ខែមេសា ឆ្នាំ២០១៦ ស្តីពីលក្ខន្តិកៈដោយឡែកសម្រាប់បុគ្គលិករដ្ឋបាលថ្នាក់ក្រោមជាតិ។

បុគ្គលិករបស់ក្រុមប្រឹក្សាត្រូវស្ថិតនៅក្រោមការគ្រប់គ្រង និងការត្រួតពិនិត្យដោយផ្ទាល់របស់គណៈអភិបាលក្នុងនាមក្រុមប្រឹក្សារបស់ខ្លួន។

**ឃ. មុខងារ**

ច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ បានកំណត់មុខងាររបស់ក្រុមប្រឹក្សាមានមុខងារពីរប្រភេទគឺមុខងារជាកាតព្វកិច្ច និងមុខងារជាជម្រើស។

- **មុខងារជាកាតព្វកិច្ច** គឺជាមុខងារដែលកំណត់ដោយច្បាប់ ឬព្រះរាជក្រឹត្យ ឬអនុក្រឹត្យ ឬប្រកាសតាមសំណើរបស់គណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ ក្រសួងស្ថាប័នរបស់រាជរដ្ឋាភិបាល។

- **មុខងារជាជម្រើស** គឺជាមុខងារដែលមិនមានលក្ខណៈជាកាតព្វកិច្ច។ មុខងារជាជម្រើសមានពីរប្រភេទគឺមុខងារជាជម្រើសដែលក្រសួងស្ថាប័នផ្ទេរទៅឱ្យរដ្ឋបាលថ្នាក់ក្រោមជាតិ និងមុខងារជាជម្រើសដែលមាន លក្ខណៈជាអាណត្តិទូទៅ។ មុខងារជាជម្រើសដែលមានលក្ខណៈជាអាណត្តិទូទៅត្រូវបានប្រគល់ទៅឱ្យក្រុមប្រឹក្សាគ្រប់លំដាប់ថ្នាក់មុនការធ្វើប្រតិភូកម្ម ឬការប្រគល់មុខងារជាក់លាក់ណាមួយ ដើម្បីជាមូលដ្ឋានក្នុងការលើកកម្ពស់សមត្ថភាពដល់រដ្ឋបាលថ្នាក់ក្រោមជាតិក្នុងការអនុវត្តមុខងារផ្សេងៗគ្នាជាច្រើន ដែលបានជ្រើសរើសយកជា អាទិភាពតាមមូលដ្ឋាននីមួយៗ។ បច្ចុប្បន្ន រដ្ឋបាលថ្នាក់ក្រោមជាតិកំពុងបំពេញការងារប្រចាំថ្ងៃ ដោយផ្អែកលើអាណត្តិទូទៅទាំងនេះ។

### ង.ហិរញ្ញវត្ថុ

ច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ បានកំណត់ឲ្យរដ្ឋបាលថ្នាក់ក្រោមជាតិមានធនធានហិរញ្ញវត្ថុសមស្រប ដើម្បីបំពេញតួនាទី ភារកិច្ចរបស់ខ្លួន និងត្រូវគ្រប់គ្រងហិរញ្ញវត្ថុរបស់ខ្លួនក្នុងលក្ខណៈប្រកបដោយប្រសិទ្ធភាព មានតម្លាភាព និងមានគណនេយ្យភាព។ មាត្រា ២៤៤ នៃច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ បានកំណត់អំពីប្រភេទចំណូលរបស់រដ្ឋបាលថ្នាក់ក្រោមជាតិដូចខាងក្រោម៖

- ប្រភពនៅមូលដ្ឋាន
- ប្រភពពីថ្នាក់ជាតិ
- ប្រភពផ្សេងៗទៀត។

➢ **ចំណូលពីប្រភពនៅមូលដ្ឋាន រួមមាន៖**

- ពន្ធនៅមូលដ្ឋាន
- ឈ្នួល កម្រៃ និងចំណូលមិនមែនសារពើពន្ធផ្សេងទៀត
- ចំណូលរបស់ក្រុមប្រឹក្សាបានមកពីពន្ធ ឈ្នួល និងកម្រៃដែលត្រូវចែករំលែករវាងក្រុមប្រឹក្សាជាមួយក្រុមប្រឹក្សាឃុំ និងក្រុមប្រឹក្សាសង្កាត់ក្នុងស្រុក
- អំណោយស្ម័គ្រចិត្ត
- ប្រភពផ្សេងទៀតដែលកំណត់ដោយច្បាប់ ឬអនុក្រឹត្យ។

➢ **ចំណូលពីថ្នាក់ជាតិ រួមមាន៖**

- ចំណូលចែករំលែក
- មូលនិធិផ្ទេរពីថវិការដ្ឋ
- និងថ្លៃសេវាបានមកពីមុខងារជាភ្នាក់ងារដែលអនុវត្តដោយក្រុមប្រឹក្សាក្នុងនាមក្រសួងស្ថាប័ន។

➢ **ប្រភពផ្សេងៗទៀត**

- អង្គការក្រៅរដ្ឋាភិបាល
- សប្បុរសជន
- អង្គការពាក់ព័ន្ធ។

### ច. ទ្រព្យសម្បត្តិ

ទ្រព្យសម្បត្តិរបស់រដ្ឋបាលថ្នាក់ក្រោមជាតិរួមមានទ្រព្យសម្បត្តិដែលរដ្ឋផ្ទេរទៅឱ្យ និងទ្រព្យសម្បត្តិដែលរកបានដោយខ្លួនឯង។

ទ្រព្យសម្បត្តិដែលរដ្ឋផ្ទេរឱ្យរដ្ឋបាលថ្នាក់ក្រោមជាតិអាចគ្រប់គ្រងប្រើប្រាស់ និងអាចទាញយកផលចំណូលពីទ្រព្យសម្បត្តិទាំងនោះហើយរដ្ឋបាលថ្នាក់ក្រោមជាតិត្រូវថែរក្សា ការពារឱ្យបានគង់វង្ស និងគ្មានសិទ្ធិ

លក់ដូរ ជួល ផ្ទេរកម្មសិទ្ធិ ឬផ្ទេរការប្រើប្រាស់ ដោយគ្មានការយល់ព្រមពីរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ បន្ទាប់ពីមានការឯកភាពពីរដ្ឋមន្ត្រីក្រសួងមហាផ្ទៃឡើយ។

ទ្រព្យសម្បត្តិដែលរដ្ឋបាលថ្នាក់ក្រោមជាតិរកបានដោយខ្លួនឯងជាកម្មសិទ្ធិ ដែលរដ្ឋបាលថ្នាក់ក្រោមជាតិមានសិទ្ធិស្វ័យសម្រេចក្នុងការគ្រប់គ្រង និងការប្រើប្រាស់ដើម្បីទាញយកផលចំណូលពីទ្រព្យសម្បត្តិទាំងនោះក្រោមក្របខ័ណ្ឌដែលកំណត់ដោយច្បាប់ ឬលិខិតបទដ្ឋានគតិយុត្តដទៃទៀត។

រដ្ឋបាលថ្នាក់ក្រោមជាតិត្រូវធ្វើបញ្ជីសារពើភណ្ឌទ្រព្យសម្បត្តិទាំងអស់របស់រដ្ឋបាលថ្នាក់ក្រោមជាតិ និងត្រូវធ្វើបច្ចុប្បន្នភាពជារៀងរាល់ឆ្នាំហើយត្រូវបញ្ជូនទៅក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុដើម្បីបញ្ចូលទៅក្នុងបញ្ជីសារពើភណ្ឌរួមនៃទ្រព្យសម្បត្តិរដ្ឋស្របតាមនីតិវិធីកំណត់ជាធរមាន។

## ១.៦.ការដោះស្រាយវិវាទ[12]

### ១.៦.១.ការដោះស្រាយវិវាទតាមរយៈតុលាការ

តុលាការ គឺជាអង្គជំនុំជម្រះក្តីដែលមានអំណាចក្នុងការដោះស្រាយជម្លោះទាក់ទងនឹងច្បាប់ ដោយធ្វើការពិនិត្យ ភាពត្រឹមត្រូវនៃការអនុវត្ត និងបកស្រាយច្បាប់។ អំណាចតុលាការ គឺមិនត្រូវបានផ្តល់ទៅឲ្យអំណាចនីតិបញ្ញត្តិ ឬនីតិប្រតិបត្តិដែលនេះមានន័យថាអំណាចតុលាការជាអំណាចដោយឡែកពីអំណាចទាំងពីរនោះ។ អង្គការតុលាការនៅក្នុងប្រទេសកម្ពុជាមានបីថ្នាក់គឺ

- តុលាការខេត្តក្រុង (សាលាដំបូងរាជធានី-ខេត្ត)
- សាលាឧទ្ធរណ៍ (ជាតុលាការលំដាប់ទីពីរបន្ទាប់ពីសាលាដំបូង)
- និងតុលាការកំពូល (ជាតុលាការដែលជាថ្នាក់ ខ្ពស់បំផុត)

តុលាការទាំងបីថ្នាក់មានយុត្តាធិការក្នុងការសម្រេចនូវសំណុំរឿងគ្រប់ប្រភេទ រួមទាំងរឿងនីតិរដ្ឋបាលផងដែរ។ ប៉ុន្តែមានតែសាលាដំបូងទេដែលអាចមានលក្ខណៈជំនាញទៅតាមរឿងក្តីដែលអាចមានជាតុលាការពាណិជ្ជកម្ម តុលាការការងារ និងតុលាការព្រហ្មទណ្ឌ។ យោងទៅតាមរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា ប្រជាពលរដ្ឋកម្ពុជាមានសិទ្ធិប្តឹងបរិហារ ប្តឹងតវ៉ា ឬប្តឹងទារសំណងផ្សេងៗដែលបណ្តឹងទាំងនេះ ស្ថិតនៅក្រោមសមត្ថកិច្ចរបស់តុលាការ។ នៅក្នុងប្រទេសកម្ពុជាក្នុងឆ្នាំ២០០៣ តុលាការទទួលបានសំណុំរឿងចំនួន១២.០០០ រួមទាំងរឿងរដ្ឋប្បវេណី និងរឿងព្រហ្មទណ្ឌ។

[12] https://pcasia.org/pic/wp-content/uploads/simple-file-list/20160825-Dispute-Resolution-Outside-the-Judicial-System-at-the-National-and-Sub-national-_KH_Final.pdf [20, June 24]

### ១.៦.២.ការដោះស្រាយវិវាទក្រៅប្រព័ន្ធតុលាការ

ក្រៅពីការដោះស្រាយជម្លោះតាមរយៈតុលាការ ការដោះស្រាយជម្លោះក្រៅប្រព័ន្ធតុលាការ គឺជាវិធីសាស្ត្រមួយផ្សេងទៀត។ ការដោះស្រាយជម្លោះប្រភេទនេះ គឺជាយន្តការដែលប្រជាជនប្រើប្រាស់ជាជម្រើសដើម្បីដោះស្រាយជម្លោះនៅក្រៅប្រព័ន្ធយុត្តាធិការរបស់តុលាការ។ ការដោះស្រាយជម្លោះក្រៅប្រព័ន្ធតុលាការ ត្រូវបានចាប់ផ្តើមក្នុងអំឡុងទសវត្សរ៍ឆ្នាំ១៩៧០ និង១៩៨០ ទទួលបាននូវប្រជាប្រិយភាពចាប់ពីពេលនោះមក។ ការដោះស្រាយជម្លោះក្រៅប្រព័ន្ធតុលាការ គឺត្រូវបានប្រើប្រាស់សម្រាប់ដោះស្រាយរឿងគ្រួសារ ជម្លោះជាមួយអ្នកជិតខាង ក៏ដូចជាជម្លោះពាក់ព័ន្ធនឹងបរិស្ថាន ពាណិជ្ជកម្ម និងការងារ។ ការដោះស្រាយជម្លោះក្រៅប្រព័ន្ធតុលាការមានជាច្រើនទម្រង់ ហើយទម្រង់ដែលត្រូវបានគេស្គាល់ជាទូទៅ គឺតាមរយៈមជ្ឈត្តកម្ម ការចរចា ការផ្សះផ្សា និងសន្ទានកម្ម។ មូលហេតុដែលនាំឲ្យមានការកើនឡើងនូវការប្រើប្រាស់ប្រព័ន្ធនេះគឺទាក់ទងនឹងការចំណាយខ្ពស់ទាំងថវិកា និងពេលវេលាសម្រាប់រឿងក្តីនៅតុលាការ។ ពេលដែលសំណុំរឿងនៅតុលាការត្រូវចំណាយពេលយូរ ការចំណាយសម្រាប់មេធាវី និងសេវាតុលាការក៏កាន់តែខ្ពស់ដែរ។ ការចំណាយ ការកកស្ទះសំណុំរឿងនៅតុលាការក៏ជាកត្តាដែលជម្រុញឲ្យមានការប្រើប្រាស់នូវយន្តការដោះស្រាយជម្លោះក្រៅប្រព័ន្ធតុលាការដែរ។ បច្ចុប្បន្នដោយសារតែបាតុភូតសកលភាវូបនីយកម្ម និងកំណើននៃការប្រើប្រាស់ប្រព័ន្ធបច្ចេកវិទ្យា ទម្រង់ថ្មីមួយនៃការដោះស្រាយជម្លោះក្រៅប្រព័ន្ធតុលាការ ត្រូវបានបង្កើតឡើងដែលហៅថាការដោះស្រាយជម្លោះក្រៅប្រព័ន្ធតុលាការផ្ទាល់តាមប្រព័ន្ធអេឡិចត្រូនិច(OADR)។ ការបង្កើតនេះមានគោលបំណងជម្រុញឲ្យភាគីវិវាទទំនាក់ទំនងគ្នាតាមរយៈប្រព័ន្ធអេឡិចត្រូនិច ដើម្បីទទួលបាននូវកិច្ចព្រមព្រៀង។ យោងទៅតាមលោក "Jordan Goldberg" ទម្រង់នៃការដោះស្រាយជម្លោះក្រៅប្រព័ន្ធតុលាការតាមប្រព័ន្ធអេឡិចត្រូនិច គឺមានលក្ខណៈដូចគ្នាទៅនឹងទម្រង់នៃការដោះស្រាយវិវាទក្រៅប្រព័ន្ធតុលាការធម្មតា ប៉ុន្តែគ្រាន់តែប្រើប្រាស់ប្រព័ន្ធអ៊ិនធឺណេតជាមធ្យោបាយដើម្បីដោះស្រាយជម្លោះ។ ចំណុចដែលគួរឲ្យកត់សម្គាល់នៃការវិវឌ្ឍរបស់ការដោះស្រាយជម្លោះក្រៅប្រព័ន្ធតុលាការ គឺជាការបញ្ចូលនូវវិធីដោះស្រាយនេះនៅក្នុងបរិបទនៃរឿងព្រហ្មទណ្ឌ។ ការប្រើប្រាស់នូវវិធីសាស្ត្រនេះនៅក្នុងរឿងព្រហ្មទណ្ឌ ហាក់បីដូចជាបាតុភូតថ្មីសម្រាប់ប្រទេសអឺរ៉ុប និងប្រទេសអូស្ត្រាលី។ មូលហេតុនៃការប្រើប្រាស់ប្រព័ន្ធនេះ ដើម្បីដោះស្រាយវិវាទព្រហ្មទណ្ឌហាក់បីដូចជាទាក់ទងទៅនឹងការស្តារឡើងវិញនូវយុត្តិធម៌ ដែលផ្តោតសំខាន់ទៅលើជនរងគ្រោះដោយធ្វើការណែនាំដល់ជនល្មើសនូវគំនិតក្នុងការទទួលខុសត្រូវចំពោះជនរងគ្រោះ និងសហគមន៍។

- ❖ **ទម្រង់នៃការដោះស្រាយវិវាទក្រៅប្រព័ន្ធតុលាការ**
- ➢ **ការចរចា**

ការចរចាគឺជាវិធីដែលមនុស្សពីរនាក់ ឬក៏មួយក្រុមប្រើប្រាស់ដើម្បីទទួលបាននូវអ្វីដែលពួកគេចង់បានពីភាគីម្ខាងទៀត។ ទម្រង់នេះមានលក្ខណៈសាមញ្ញក្នុងការដោះស្រាយជម្លោះរវាងមនុស្ស និងត្រូវបានប្រើប្រាស់សម្រាប់ជីវភាពប្រចាំថ្ងៃនៅក្នុងទំនាក់ទំនងគ្រប់ប្រភេទ។ ការទំនាក់ទំនងអាចជារឿងផ្ទាល់ខ្លួន សង្គម វិជ្ជាជីវៈ ឬក៏ជាការជួបធម្មតា។ ពេលខ្លះអ្នកចរចាមិនបានដឹងថាខ្លួនកំពុងតែធ្វើការចរចានោះទេ។ ជាទូទៅការចរចាអាចធ្វើ

បានតាមវិធីសាស្ត្រជាច្រើន ដូចជាលក្ខណៈផ្លូវការ (តាមរយៈការប្រជុំ ឬក៏កិច្ចព្រមព្រៀងជាលាយលក្ខអក្សរ) ឬជាលក្ខណៈមិនផ្លូវការ (តាមរយៈទូរស័ព្ទ សារអេឡិចត្រូនិច និងសំបុត្រ)។

- **សន្ទានកម្ម**

សន្ទានកម្មគឺជាវិធីដែលអាចដោះស្រាយជម្លោះក្រៅពីតុលាការ។ សន្ទានការីធ្វើការកោះហៅភាគីទាំងពីរ និងព្យាយាមធ្វើការដោះស្រាយនូវជម្លោះ ឬការទទួលបាននូវកិច្ចព្រមព្រៀងដែលភាគីទាំងពីរមានសិទ្ធិ ក្នុងការទទួលយក ឬបដិសេធ។

- **ការផ្សះផ្សា**

ការផ្សះផ្សា គឺជាវិធីដែលភាគីទីបីដែលជាអ្នកផ្សះផ្សា ជួបជាមួយនឹងភាគីជម្លោះដាច់ដោយឡែកពីគ្នា (ការជួបដាច់ ដោយឡែកនេះគឺខុសគ្នាពីការធ្វើសន្ទានកម្ម) ដើម្បីព្យាយាមរកនូវការព្រមព្រៀងពីភាគីក្នុងការដោះស្រាយជម្លោះ។

- **មជ្ឈត្តកម្ម**

មជ្ឈត្តកម្ម គឺជាវិធីដែលមានភាគីអព្យាក្រឹត្យ ឬជាក្រុមមជ្ឈត្តករ ដែលធ្វើសវនាការលើភស្តុតាងរបស់ភាគីវិវាទទាំងពីរ ហើយចេញនូវសេចក្តីសម្រេចរបស់ខ្លួនដែលហៅថា សេចក្តី បង្គាប់អាជ្ញាកណ្តាល។ មជ្ឈត្តកម្មមានលក្ខណៈស្រដៀងគ្នាទៅនឹងតុលាការ ពីព្រោះមជ្ឈត្តករគឺត្រូវពិចារណា នូវភស្តុតាងដែលភាគីវិវាទដាក់មក។ ទោះបីជាយ៉ាងណា នីតិវិធីនេះមានលក្ខណៈខុសពីតុលាការត្រង់ថា ភាគីមានសិទ្ធិក្នុងការមិនចងកាតព្វកិច្ចទៅនឹងសេចក្តីបង្គាប់អាជ្ញាកណ្តាលក៏ដូចជា ការជ្រើសរើសនូវមជ្ឈត្តករ ទីកន្លែង និងពេលវេលាសម្រាប់ធ្វើមជ្ឈត្តកម្ម។ ភាពបត់បែននេះមិនមាននៅក្នុងតុលាការទេ។

# ជំពូក ២
# ស្ថានភាពនៃការគ្រប់គ្រងរដ្ឋបាលស្រុកកៀនស្វាយ

# ជំពូក ២

# ស្ថានភាពនៃការគ្រប់គ្រងរដ្ឋបាលស្រុកកៀនស្វាយ

## ២.១. ស្ថានភាពទីតាំងភូមិសាស្ត្រនិងប្រជាសាស្ត្រ

### ២.១.១ ទីតាំងភូមិសាស្ត្រ

ខេត្តកណ្ដាល គឺជាខេត្តនៃប្រទេសកម្ពុជាដែលមានទីតាំងនៅប៉ែកអាគ្នេយ៍នៃប្រទេសនេះ។ ខេត្តកណ្ដាលមានសក្ដានុពលជាច្រើនដូចជា វិស័យកសិកម្ម ឧស្សាហកម្ម និង ទេសចរណ៍ ជាវិស័យគោលចម្បងក្នុងការអភិវឌ្ឍសេដ្ឋកិច្ចខេត្តទទួលបានការរីកចម្រើន។ ប្រព័ន្ធហេដ្ឋារចនាសម្ព័ន្ធនៅខេត្តកណ្ដាលគឺជា ខេត្តមានផ្លូវជាតិធំសំខាន់ៗជាច្រើនទៀតសម្រាប់តភ្ជាប់ទៅកាន់បណ្ដាខេត្តនានា។ ខេត្តកណ្ដាលក៏មានស្ពានធំៗឆ្លងទន្លេនឹងមានព្រលានយន្តហោះកម្រិតអន្តរជាតិមួយ១កន្លែងផងដែរ។ កសិកម្ម និងការនេសាទ គឺជាឧស្សាហកម្មសំខាន់ពីរនៃខេត្តនេះ។

➢ **ខេត្តដែលមានព្រំដែនជាប់និងខេត្តកណ្ដាលមាន**

- ខាកើតជាប់ខេត្តព្រៃវែង
- ខាងត្បូងជាប់ ខេត្តតាកែវ
- ខាងកើតឈៀងខាងជើងជាប់ ខេត្តកំពង់ចាម
- ខាងកើតឈៀងខាងត្បូងជាប់នឹង វៀតណាម។

ទីរួមខេត្ត គឺក្រុងតាខ្មៅ ដែលមានចំងាយ ១១ គីឡូម៉ែត្រ ខាងត្បូងនៃភ្នំពេញ។ កណ្ដាលគឺជាខេត្តមួយក្នុងចំណោមខេត្តដែលស្កុកស្គម្ភជាងគេក្នុងប្រទេស។ ខេត្តកណ្ដាលមានស្រុកចំនួន១១ ក្រុង១ ឃុំ១៤៧ ភូមិចំនួន ១០៨៧ និង ១៤៧សង្កាត់ មានប្រជាជនចំនួន ១០៧៥១២៥នាក់ ហើយខេត្តនេះផងដែរមានផ្ទៃដី ៣៥៦៨ គីឡូម៉ែត្រការ៉េ។ ខេត្តនេះមានផ្ទៃដី ៣៥៦៨ សហាតិមាត្រការ៉េ ប្រជាជនខេត្តកណ្ដាលភាគច្រើនប្រកបរបរកសិកម្ម ដាំដំណាំ ក្រៅពីនេះរដូវធ្វើស្រែ ពួកគាត់មានរបរមួយទៀតគឺរបរឡើងត្នោត និងធ្វើស្រូវប្រាំងព្រមទាំងដាំដំណាំផ្សេងៗ ដើម្បីផ្គត់ផ្គង់ជីវភាពគ្រួសាររបស់ខ្លួន។

ស្រុកកៀនស្វាយស្ថិតក្នុងចំណោមក្រុងស្រុកទាំង១៣ របស់ខេត្តកណ្ដាលមាន ទីតាំងជាប់នឹងរាជធានីភ្នំពេញ ដែលជាបេះដូងនៃព្រះរាជាណាចក្រកម្ពុជាដែលមានភូមិសាស្ត្រ ខណ្ឌដោយទន្លេមេគង្គក្រោម និងទន្លេបាសាក់។ ស្រុកកៀនស្វាយមានព្រំប្រទល់ខាងជើងជាប់នឹងស្រុកល្វាឯម ខណ្ឌដោយទន្លេមេគង្គក្រោម ខាងត្បូងជាប់នឹងស្រុកស្អាងនិងក្រុងតាខ្មៅ ខណ្ឌដោយទន្លេបាសាក់ ខាងកើតជាប់នឹងស្រុកលើកដែក ខាងលិចជាប់នឹងខណ្ឌច្បារអំពៅ រាជធានីភ្នំពេញ។

ស្រុកកៀនស្វាយមានផ្ទៃដីសរុប ៣០ ៩៦៤ គីឡូម៉ែត្រការ៉េរួមមានដីសេដ្ឋកិច្ចគ្រួសាររលំនៅដ្ឋានបម្រើអោយវិស័យកសិកម្ម វិស័យឧស្សាហកម្ម បឹងធម្មជាតិ និងព្រៃលិចទឹក ចែកចេញជា ៨ ឃុំរួមមាន ឃុំភូមិធំ ឃុំគគីរ ឃុំដីឥដ្ឋ ឃុំឈើទាល ឃុំកំពង់ស្វាយ ឃុំបន្ទាយដែក ឃុំសំរោងធំ និង ឃុំគគីរធំ។[13]



រូបភាពទី១៖ ផែនទីស្រុកកៀនស្វាយខេត្តកណ្ដាល

### ២.១.២.ស្ថានភាពប្រជាសាស្ត្រ

នៅក្នុងស្រុកកៀនស្វាយ មានប្រជាពលរដ្ឋរស់នៅសរុបចំនួន ១៣១ ៤១១នាក់ ក្នុងនោះស្រី ៦៦៧៦៤នាក់ ប្រុសមានចំនួន៦៤ ៦៤៧នាក់ គិតជាដង់ស៊ីតេប្រជាពលរដ្ឋមានប្រមាណ៤៣៤នាក់ ក្នុងមួយគីឡូម៉ែត្រការ៉េ។

## ២.២.ស្ថានភាពសេដ្ឋកិច្ច

ស្រុកកៀនស្វាយប្រជាជនមានមុខរបរជាចំបងបីប្រភេទ ប្រជាពលរដ្ឋដែលពេញកម្លាំងពលកម្មពីអាយុ១៨ ដល់៦០ឆ្នាំ គឺមុខរបរកសិកម្ម ឧស្សាហកម្មធុនតូច សិប្បកម្ម និងសេវាកម្ម សរុបប្រមាណ៥៥ ៦០៤នាក់ ស្មើនឹង

[13]https://km.wikipedia.org/wiki/%E1%9E%81%E1%9F%81%E1%9E%8F%E1%9F%92%E1%9E%8F%E1%9E%80%E1%9E%8E%E1%9F%92%E1%9E%8A%E1%9E%B6%E1%9E%9B [22, June 24 ]

៧៥ ភាគរយនៃពលកម្មសរុបរបស់ស្រុក ក្នុងនោះមានមុខរបរចម្បងសំខាន់២ ដែលអាចស្រូបយកសមាមាត្រខ្ពស់ប្រហាក់ប្រហែលគ្នាគឺះ

១- ប្រជាពលរដ្ឋដែលមានមុខរបរផ្នែកសិកម្ម មាន២៨ ៤២៨ នាក់ ស្មើនឹង៥១,១០ ភាគរយ ក្នុងនោះស្រ្តីមាន ២០,៣០ភាគរយប៉ុណ្ណោះ។

២- ប្រជាពលរដ្ឋដែលមានមុខរបរចំបងក្នុងផ្នែកសេវាកម្មនានាមានប្រមាណ ២៧០៤៥ នាក់ ស្មើនឹង៤៨,៦០% ក្នុងនោះសមាមាត្ររបស់ស្ត្រីស្រូបអស់ពាក់កណ្តាលនៃពលកម្មសរុបគឺ ២៤,៨%  នៅលើទីតាំងផលិតកម្ម និងសេវាកម្មសុរប១៨៤៦ ទីតាំង។ បណ្តាស្រ្តីទាំងនោះគឺអ្នកបម្រើក្នុងសេវាកម្មលក់ដូរ ៦,៤% ជួសជុល ០,៨% ដឹកជញ្ជូន ២,១% កម្មករក្នុងវិស័យកសិកម្មនិងសំណង់ ១០,៣% កម្មកររោងចក្រ ២៥,៣% ជាមន្ត្រីរាជការ ៣,៨% ។ ដូច្នេះស្ត្រីនៅតែជាតួលេខដែលស្រូបនូវសមាមាត្រខ្ពស់ក្នុងការចូលរួមផលិតនូវផលិតផល សង្គមរបស់ជាតិ។

៣- ដោយឡែកនៅក្នុងវិស័យឧស្សាហកម្មធុនតូច សិប្បកម្មអត្រានៃអ្នកមានមុខរបរចំបងក្នុងវិស័យនេះមានតិចតួចបំផុតគឺប្រមាណ១៣នាក់ ស្មើនឹង០,២ នៃពលកម្មសរុបរបស់ស្រុក ក្នុងនោះស្ត្រីមាន០,១% កត្តានេះវាអាស្រ័យដោយតម្រូវការរបស់ទីផ្សារក្នុងផ្នែកនេះមានកម្រិតទាបបំផុតបើប្រៀបធៀប ទៅនឹងវិស័យ កសិកម្ម និងសេវាកម្មនានា ដែលមានតម្រូវការរបស់ទីផ្សារខ្ពស់នៅក្នុងស្រុក។ ចំណែកប្រជាពលរដ្ឋអ្នកស្វែងរកការងារធ្វើនៅក្នុងប្រទេសមានប្រមាណ៤%  និងក្រៅប្រទេសមាន ប្រមាណ១,២% ប៉ុណ្ណោះ។

## ២.៣.ស្ថានភាពសង្គមកិច្ច

### ២.៣.១.វិស័យអប់រំ

វិស័យអប់រំជាវិស័យចម្បងមួយក្នុងបណ្តាចិស័យចម្បងៗជាច្រើនទៀត ដែលមានសង្គតិភាពជាមួយគោលនយោបាយរបស់ជាតិ ពិសេសយុទ្ធសាស្ត្រចតុកោណជំណាក់កាលទី៣របស់រដ្ឋាភិបាល។ វិស័យនេះមានវិសាលភាពគ្របដណ្តប់ទូទាំងស្រុក នៅគ្រប់មូលដ្ឋានឃុំ ភូមិ និងនៅគ្រប់គ្រួសារដែលមានកុមារដល់វ័យសិក្សាគ្រប់កម្រិត។

| បរិយាយ | ចំនួនសាលា | ចំនួនបន្ទប់ | ចំនួនថ្នាក់ | ចំនួនសិស្ស | ចំនួនគ្រូបង្រៀន | ផលធៀបសិស្សនិងគ្រូបង្រៀន |
|---|---|---|---|---|---|---|
| បឋមសិក្សា | 34 | 390 | 400 | 15946 | 298 | 53.5 |
| អនុវិទ្យាល័យរដ្ឋ | 5 | 62 | 64 | 2618 | 174 | 15 |
| វិទ្យាល័យរដ្ឋ | 3 | 95 | 97 | 4023 | 277 | 14.5 |
| សរុប | 42 | 547 | 561 | 22587 | 749 | |

### ២.៣.២.វិស័យសុខាភិបាល

វិស័យនេះមានវិសាលភាពគ្របដណ្តប់នៅគ្រប់ឃុំទូទាំងស្រុក វិស័យសុខាភិបាលជាវិស័យមួយដែលសំខាន់ចាំបាច់មិនអាចខ្វះបាន ចំពោះជីវភាពរស់នៅប្រចាំថ្ងៃរបស់ប្រជាពលរដ្ឋ។ ស្រុកបានបែងចែកជាមណ្ឌលសុខភាព ចំនួន៧កន្លែង និងមានគ្រែសម្រាកព្យាបាលនៅមណ្ឌលសុខភាពចំនួន៤៤ រាយនៅតាមបណ្តាឃុំក្នុងស្រុក មានមន្ទីរពេទ្យបង្អែក១ដែលមានទីតាំងនៅទីរួមស្រុក និងមានគ្រែសម្រាកចំនួន៥៨ ទន្ទឹមនិងនោះស្រុកក៏បានអនុញ្ញាតអោយមានគ្លីនិកឯកជនជាច្រើនកន្លែងព្រមទាំងមានគ្រែសម្រាកព្យាបាលចំនួន១៣០បន្ថែមទៀត។

ដើម្បីធានាបាននូវនិរន្តភាពស្រុកបានបែងចែករៀបចំបុគ្គលិកជំនាញបច្ចេកទេសសុខាភិបាលនៅតាមបណ្តាលមណ្ឌលសុខភាព និងមន្ទីរពេទ្យបង្អែករបស់ស្រុករួមមាន វេជ្ជបណ្ឌិតឯកទេស វេជ្ជបណ្ឌិតរួមជាមួយគ្រូពេទ្យធ្មប ពេទ្យបឋម មធ្យម បុគ្គលិកផ្សេងៗទៀតនិងបុគ្គលិកជាប់កិច្ចសន្យា។

- មកដល់ឆ្នាំ២០១៩នេះ លទ្ធផលដែលស្រុកសម្រេចបានគឺ៖
  - អត្រាស្ត្រីសម្រាលកូនដោយពេទ្យឆ្មបមានចំនួន៩៨,៧%
  - ចំនួនស្ត្រីដែលបានសម្រាលកូនក្នុងឆ្នាំមាន១.៨៥៤នាក់ ហើយពុំមានស្ត្រីណាម្នាក់ស្លាប់ក្រោយសម្រាលពី 0-១ ខែនោះទេ ក្នុង១.000 កំណើត ។
  - ចំនួនទារកកើតក្នុងឆ្នាំក៏មានចំនួន១.៨៥៤ នាក់ ហើយអត្រាស្លាប់របស់ទារកពី0-១ខែ ក្នុង ១.000 កំណើត មាន0,៥% គឺទារកស្លាប់តែម្នាក់គត់ គឺនៅឃុំគគីរ ។
  - ចំនួនកុមារចន្លោះពី៩-១២ខែ មាន១.២០៣នាក់ ក្នុងនោះបានចាក់ថ្នាំការពារគ្រប់ចំនួនមាន ១.១៨៧នាក់ គិតជាភាគរយ៩៨,៧% ។
  - ចំនួនគ្រួសារមានសមាជិកកើតជំងឺអេដស៍មាន១៤៧នាក់ ក្នុងនោះចំនួនអ្នកស្លាប់ដោយជំងឺមាន ៣នាក់ ប៉ុណ្ណោះ។

### ២.៣.៣.ស្ថានភាពយេនឌ័រ

បញ្ហាស្ត្រីគ្រប់អាយុជាបញ្ហាចម្បងដែលគណៈកម្មាធិការពិគ្រោះយោបល់កិច្ចការស្ត្រី និងកុមារស្រុក (ហៅកាត់គ.ក.ស.ក) បានផ្តោតការយកចិត្តទុកដាក់ខ្ពស់បំផុត ស្ត្រីភាគច្រើនគឺជាជនងាយរងគ្រោះព្រោះ

- ស្ត្រីមានសមាមាត្រខ្ពស់ជាបុរស គឺច្រើនជាង50% នៃប្រជាជនសរុប
- ស្ត្រីមានភេទទន់ខ្សោយ និងមានការងារច្រើនជាងបុរស
- ស្ត្រីទទួលការប្រមាថមើលងាយពីអ្នកមានកម្លាំងខ្លាំង ។ល។

- **ស្ត្រីក្នុងផលិតកម្ម សេវាកម្ម**

ផ្នែកនេះចំនួនស្ត្រីនៅតែរក្សាបាននូវសមាមាត្រធំជាងបុរស ដូចជា ៖

- ចំនួនស្រ្តីមានមុខរបរចម្បងក្រៅពីវិស័យកសិកម្ម មាន 13.843 នាក់ គិតជាភាគរយ 51%
- ស្រ្តីមានមុខរបរចម្បងបន្ទាប់បន្សំពីវិស័យកសិកម្ម មាន 2.534 នាក់ គិតជាភាគរយ 48,40%
- សរុបស្រ្តីធ្វើការងារតាមទីតាំងផលិតកម្ម និងសេវាកម្មមាន 3.976 នាក់ គិតជាភាគរយ 65,3%។

➢ **ស្រ្តីចំណាកស្រុក**

- សរុបស្រ្តីអាយុ 18 ឆ្នាំ ឡើងមាន 44.627 នាក់
- ចំណាកស្រុកក្នុងប្រទេសប្រមាណ 3,40%
- ចំណាកស្រុកក្រៅប្រទេសប្រមាណ 1,1 %។

➢ **ស្រ្តីមានវិជ្ជាជីវៈ**

- ស្រ្តីរៀននៅសាលាបណ្តុះបណ្តាលវិជ្ជាជីវៈ 18-35 ឆ្នាំ មាន 415 នាក់
- ស្រ្តីជាបុគ្គលិកមានក្របខណ្ឌនៅការិយាល័យនៅរដ្ឋបាលស្រុកមាន ៨ នាក់
- ស្រ្តីជាបុគ្គលិកការិយាល័យនានាចំណុះសាលាស្រុក មាន ២០ នាក់។

➢ **ស្រ្តីអប់រំ**

- សរុបសិស្សស្រីនៅវិទ្យាល័យ3.683 នាក់
- សរុបសិស្សស្រីនៅសកលវិទ្យាល័យ 1.051 នាក់
- ចំនួនស្រ្តីជាគ្រូបង្រៀននៅបឋមសិក្សា មាន 177 នាក់ គិតជាភាគរយ59,4%
- ចំនួនស្រ្តីជាគ្រូបង្រៀននៅអនុវិទ្យាល័យ 81 នាក់ គិតជាភាគរយ46,6%។

➢ **ស្រ្តីរងគ្រោះ**

- ចំនួនស្រ្តីជាជនពិកា មាន 301 នាក់ គិតជាភាគរយ 37,4%។

➢ **ស្រ្តីធ្វើការសម្រេចចិត្ត**

- មេភូមិ ស្មើ 19,4%
- ការិយាល័យជុំវិញស្រុក ស្មើ 27,3%
- ក្រុមប្រឹក្សាឃុំ ស្មើ 21,3%
- ប្រធាន ស្មើ 10%
- ក្រុមប្រឹក្សាស្រុក ស្មើ 15,8%
- អនុប្រធាន ស្មើ 42,9%។

### ២.៣.៤.ភាពក្រីក្រ

| លទ្ធផលនៃការធ្វើសញ្ញាណកម្ម ឆ្នាំ២០១៩ របស់ស្រុកកៀនស្វាយ | | | | | | | | | | |
|---|---|---|---|---|---|---|---|---|---|---|
| ល.រ | ឃុំ | ចំនួនគ្រួសារ | ប្រភេទក្រ១ | | ប្រភេទក្រ២ | | ប្រភេទក្រ១ + ក្រ២ | | ការប្រៀបធៀប | |
| | | | ចំនួនគ្រួសារ | % | ចំនួនគ្រួសារ | % | ចំនួនគ្រួសារ | % | ២០១៦ | ២០១៩ |
| ១ | ភូមិធំ | 3040 | 108 | 3.55% | 108 | 3.55% | 216 | 7.11% | 12.1 | (5.00) |
| 2 | គគីរ | 3742 | 58 | 1.55% | 119 | 3.18% | 177 | 4.73% | 4.73 | - |
| 3 | ដីឥដ្ឋ | 4327 | 430 | 9.94% | 280 | 6.47% | 710 | 16.41% | 19.84 | (3.44) |
| 4 | បន្ទាយដែក | 3620 | 187 | 5.17% | 245 | 6.77% | 432 | 11.93% | 11.14 | 0.73 |
| 5 | សំរោងធំ | 5390 | 283 | 5.25% | 1085 | 20.13% | 1368 | 25.38% | 28.5 | (3.12) |
| 6 | គគីរធំ | 3037 | 111 | 3.65% | 356 | 11.72% | 467 | 15.38% | 16.1 | (0.73) |
| 7 | ឈើទាល | 2391 | 134 | 5.60% | 188 | 7.86% | 322 | 13.47% | 14.28 | (0.82) |
| 8 | កំពុងស្វាយ | 2639 | 91 | 3.45% | 122 | 4.64% | 213 | 8.07% | 9.45 | (1.38) |
| សរុប | | 28186 | 1402 | 4.97% | 2503 | 8.88% | 3905 | 13.85% | 15.53 | (1.68) |

### ២.៣.៥. សាសនា

នៅក្នុងស្រុកកៀនស្វាយមានប្រជាពលរដ្ឋ ៩៥% កាន់សាសនាព្រះពុទ្ធ និង ៥% កាន់សាសនាផ្សេងៗ មានយេស៊ូគ្រីស្ត និងឥស្លាមសាសនា។ ក្នុងនោះទូទាំងស្រុកមាន ៣២ វត្ត ព្រះសង្ឃ ៤៥៤ អង្គ (ភិក្ខុ ១៤៤ អង្គ សាមណេរ ៣១០ អង្គ) អាចារ្យមាន ១៤២ នាក់ អមដោយគណៈកម្មការវត្ត ៣៩២ នាក់។ ក្នុងផ្នែកសិក្សាមានពុទ្ធិកបឋមសិក្សា ១០ កន្លែង និងពុទ្ធិកអនុវិទ្យាល័យ ១ កន្លែង។ ជាមួយនឹងការរីកចម្រើនលើវិស័យធម្មការ និងសាសនាក៏នៅមានបញ្ហាមួយចំនួន ដែលស្តែងចេញពីការមិនប្រតិបត្តិតាមវិន័យបញ្ញត្តិឲ្យបានហ្មត់ចត់ហើយជះឥទ្ធិពលមិនល្អដល់សាសនាផងដែរ។

### ២.៣.៦. វិស័យអនាម័យនិងទឹកស្អាត

ក្នុងស្រុកបច្ចុប្បន្នមានប្រភពទឹកសំខាន់ៗ ៣ គឺទន្លេមេគងក្រោមទន្លេបាសាក់ និងទឹកបឹង។ គ្រួសារដែលប្រើប្រាស់ទឹកស្អាតមាន ១៧.៥៨៣ គ្រួសារ ស្មើនឹង៦៧,៨០%។ ចំណែក ៨.៥១០ គ្រួសារទៀតប្រើប្រាស់ទឹកទន្លេ ស្ទឹង អូរ។ ខាងអនាម័យវិញគ្រួសារដែលមានបង្គន់ប្រើប្រាស់មាន ១៧.២៦៩ គ្រួសារស្មើនឹង ៦៦,២០%។ គ្រួសារដែលមានបង្គន់បច្ចេកទេសមាន ១៤.៣៤០ គ្រួសារ ស្មើនឹង ៥៥,០០%។

### ២.៣.៧. ការរៀបចំដែនដី នគរូបនីយកម្ម សំណង់ និងភូមិបាល

ការិយាល័យរៀបចំដែនដី នគរូបនីកម្ម សំណង់ និងភូមិបាល ត្រូវបំពេញតួនាទីជាសេនាធិការអោយរដ្ឋបាលក្រុងលើការងាររៀបចំដែនដី នគរូបនីយកម្ម សំណង់ និងភូមិបាល មានភារកិច្ចចាត់ចែងលើមុខងារមួយចំនួនដូចជា៖

- ការងាររៀបចំដែនដី និងនគរូបនីកម្ម
- ការងារភូមិបាល
- ការងារលំនៅឋាន
- ការងារផ្សេងៗទៀតតាមការប្រគល់ភារកិច្ចរបស់អភិបាលក្រុង។[14]

## ២.៤.រចនាសម្ព័ន្ធរបស់សាលាស្រុកកៀនស្វាយ

### ២.៤.១. តួនាទី ភារកិច្ចនិងអ្នកនាំរបស់សាលាស្រុកកៀនស្វាយ

**ក. ក្រុមប្រឹក្សាស្រុកកៀនស្វាយ**

ក្នុងអាណត្តិទី៣នេះ ក្រុមប្រឹក្សាស្រុកកៀនស្វាយដែលបានជ្រើសរើសដោយការបោះឆ្នោតអសកលមានសមាជិកចំនួន ២១រូប ក្នុងនោះលោក **ជា ប៊ុនធឿន** ជាប្រធានក្រុមប្រឹក្សា និងមានគណៈកម្មាធិការសម្របសម្រួលកាតព្វកិច្ចចំនួន៣ គឺគណៈកម្មាការលទ្ធកម្ម គណៈកម្មាការពិគ្រោះយោបល់ស្ត្រីនិងកុមារ និងគណៈកម្មាធិការសម្របសម្រួលបច្ចេកទេស ។

ក្រុមប្រឹក្សាស្រុកកៀនស្វាយមានសិទ្ធិអំណាច២ គឺសិទ្ធិអំណាចខាងបញ្ញត្តិដោយចេញដីកាក្នុងកិច្ចប្រជុំសាមញ្ញ កិច្ចប្រជុំវិសាមញ្ញរបស់ក្រុមប្រឹក្សា និងសិទ្ធិអំណាចប្រតិបត្តិដោយធ្វើសេចក្តីសម្រេចក្នុងកិច្ចប្រជុំក្នុងកិច្ចប្រជុំក្រុមប្រឹក្សា តាមដាន និងវាយតម្លៃដើម្បីធានាថាសេចក្តីសម្រេចនោះត្រូវបានអនុវត្ត ។

ទន្ទឹមនឹងនេះក្រុមប្រឹក្សាត្រូវមានគណនេយ្យភាពដោយផ្ទាល់ចំពោះប្រជាពលរដ្ឋអំពីជម្រើសជាអាទិភាពដើម្បីធ្វើសេចក្តីសម្រេចចិត្តធានាបានការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យ និងមានគណនេយ្យភាពចំពោះរាជរដ្ឋាភិបាលក្នុងការប្រតិបត្តិតាមរដ្ឋធម្មនុញ្ញច្បាប់ និងលិខិតបទដ្ឋានគតិយុត្តិ។

**ខ. គណៈអភិបាលស្រុកកៀនស្វាយ**

គណៈអភិបាលស្រុកកៀនស្វាយដឹកនាំដោយ លោក **ឡូវ សុខសាន** ជាអភិបាលស្រុក និងអភិបាលរងចំនួន៦រូប រួមមាន លោក **ពៅ គីមលី** លោក **សុខ ពិសិដ្ឋ** លោកស្រី **ហង្ស ចន្ថា** លោក **សន ហុងសេង** លោក **លីវ វណ្ណថេង** និង លោក **ស៊ុម ធន**។

[14] (ផែនការអភិវឌ្ឍន៍រយៈពេលប្រាំឆ្នាំ២០២០-២០២៤ ស្រុកកៀនស្វាយ ខេត្តកណ្តាល, ទំព័រ១៣)

គណៈអភិបាលស្រុកជាអ្នកជួយ និងគាំទ្រក្រុមប្រឹក្សាអនុវត្តសេចក្ដីសម្រេចរបស់ក្រុមប្រឹក្សាដោយលោកអភិបាលស្រុក ជាអ្នកទទួលបន្ទុកដឹកនាំការងាររួមនឹងដឹកនាំផ្ទាល់លើការងាររដ្ឋបាលទូទៅ ការងារសន្តិសុខសណ្ដាប់ធ្នាប់សាធារណៈ កិច្ចការប្រយុទ្ធប្រឆាំងគ្រឿងញៀន កិច្ចការប្រយុទ្ធប្រឆាំង ការជួញដូរមនុស្ស កិច្ចការគ្រប់គ្រងគ្រោះមហន្តរាយ និងជាអាណាប័នក្នុងនាមក្រុមប្រឹក្សារបស់ខ្លួន។

## គ. នាយករដ្ឋបាលស្រុកកៀនស្វាយ

នៅរដ្ឋបាលស្រុកកៀនស្វាយ លោកស្រី **ង៉ាម វាសនា** ជានាយករដ្ឋបាល លោក **អ៊ឹម ណារ័ត្ន** លោក **គង់ សុវណ្ណឌី** និងលោក**ស្រី អ៊ុន ម៉េយ៉ា** ជានាយករងរដ្ឋបាល។ នាយករដ្ឋបាលជាជំនួយការរបស់ក្រុមប្រឹក្សា និងគណៈអភិបាលស្រុកក្នុងការចាត់ចែងកិច្ចការរដ្ឋបាលធានានិរន្តភាពកិច្ចការប្រចាំថ្ងៃ និងត្រួតពិនិត្យការិយាល័យអង្គភាពរបស់ស្រុក។ រីឯនាយករងរដ្ឋបាលគឺជាជំនួយការលោកស្រីនាយករដ្ឋបាលលើកិច្ចការដែលបែងចែកក្នុងកំណត់បែងចែកភារកិច្ចទទួលខុសត្រូវរបស់គណៈនាយករដ្ឋបាលសាលាស្រុកកៀនស្វាយ។

## ឃ.ការិយាល័យ និងអង្គភាពជំនាញ ចំណុះរដ្ឋបាលស្រុកកៀនស្វាយ

តាមរយៈមាត្រា៩ នៃអនុក្រឹតលេខ១៨៤ អនក្រ.បក ខាងលើដើម្បីធានាការផ្ដល់សេវាជូនប្រជាពលរដ្ឋឱ្យមានភាពងាយស្រួល រហ័ស ប្រកបដោយប្រសិទ្ធិភាព និងតម្លាភាពរាជរដ្ឋាភិបាលបានធ្វើសមាហរណកម្មការិយាល័យជំនាញដែលចំណុះឱ្យក្រសួងស្ថាប័នកន្លងមកដាក់បញ្ចូលក្នុងរចនាសម្ព័ន្ធរបស់រដ្ឋបាលស្រុកវិញ។

ការិយាល័យចំណុះសាលាស្រុកមានៈការិយាល័យរដ្ឋបាលនិងហិរញ្ញវត្ថុ អង្គភាពលទ្ធកម្ម ការិយាល័យគ្រប់គ្រងធនធានមនុស្ស ការិយាល័យផែនការ និងគាំទ្រឃុំ ការិយាល័យត្រួតពិនិត្យផ្ទៃក្នុង ការិយាល័យលេខាធិការក្រុមប្រឹក្សា ការិយាល័យអប់រំយុវជន និងកីឡា ការិយាល័យរៀបចំដែនដី នគរូបនីយកម្ម សំណង់ និងភូមិបាល ការិយាល័យនីតិកម្ម និងសម្រុះសម្រួលវិវាទមូលដ្ឋាន ការិយាល័យ កសិកម្មធនធានធម្មជាតិ និងបរិស្ថាន ការិយាល័យសេដ្ឋកិច្ច និងអភិវឌ្ឍសហគមន៍ ការិយាល័យ សង្គមកិច្ច និងសុខុមាលភាពសង្គម ការិយាល័យច្រកចេញចូលតែមួយ។

ការិយាល័យ និងអង្គភាព ចំណុះស្រុក មានបុគ្គលិកសរុប១០២នាក់ ក្នុងនោះស្រី២០នាក់។

❖ **តួនាទីភារកិច្ច**

➢ ភារកិច្ចរបស់គណៈធម្មាធិការលទ្ធកម្មស្រុកកៀនស្វាយរួមមានៈ

- ពិនិត្យ ផ្ដល់យោបល់លើសេចក្ដីព្រាងផែនការលទ្ធកម្មប្រចាំឆ្នាំ ដែលរៀបចំដោយអង្គភាពលទ្ធកម្ម ដើម្បីផ្ដល់ជូនក្រុមប្រឹក្សាពិនិត្យ ឯកភាពមុននឹងផ្ញើរជូនក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុដើម្បីពិនិត្យអនុម័ត
- ណែនាំទៅអោយអង្គភាពលទ្ធកម្មអនុវត្តអោយត្រឹមត្រូវតាមផែនការ
- ប្រជុំវាយតម្លៃកំណត់បុរេលក្ខណៈសម្បត្តិចំពោះកិច្ចការលទ្ធកម្មដែលមានលក្ខណៈស្មុគស្មាញ
- ត្រួតពិនិត្យឡើងវិញលើទំហំទឹកប្រាក់នៃកញ្ចប់លទ្ធកម្មនីមួយៗ មុននឹងចាប់ផ្ដើមដំណើរការលទ្ធកម្ម

- ត្រួតពិនិត្យ និងផ្តល់ទិដ្ឋការលើឯកសារដេញថ្លៃដែលស្ថិតក្នុងសិទ្ធសម្រេចរបស់ខ្លួន
- ប្រជុំបើកដំណើរការដេញថ្លៃ ពិគ្រោះថ្លៃ ស្ទង់តម្លៃ ឬចរចារថ្លៃ
- ប្រជុំវាយតម្លៃកិច្ចសន្យា
- ត្រួតពិនិត្យ និងវាយតម្លៃឡើងវិញលក្ខណៈសម្បត្តិរបស់អ្នកដេញថ្លៃនាំមុខ មុនការសម្រេចប្រគល់កិច្ចសន្យា
- ជូនដំណឹងការប្រគល់កិច្ចសន្យាអោយអ្នកដេញថ្លៃដែលឈ្នះ និងចម្លងជូនទៅគ្រប់អ្នកដេញថ្លៃ
- ផ្សព្វផ្សាយពីលទ្ធផលនៃការដេញថ្លៃជាសាធារណៈ
- រាយការណ៍ជូនក្រុមប្រឹក្សារបស់ខ្លួន អំពីដំណើរការលទ្ធកម្មក្នុងកិច្ចប្រជុំសាមញ្ញ ឬវិសាមញ្ញតាមការចាំបាច់និងកំណត់របស់ក្រុមប្រឹក្សា
- ផ្ញើរបាយការណ៍ស្តីអំពីការអនុវត្តកិច្ចលទ្ធកម្មប្រចាំខែ ប្រចាំត្រីមាស ប្រចាំឆមាស ប្រចាំឆ្នាំ ជូនក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ បន្ទាប់ពីរបាយការណ៍ត្រូវអនុម័តដោយក្រុមប្រឹក្សាខ្លួន
- ដោះស្រាយបណ្តឹងតវ៉ាលទ្ធកម្មតាមសមត្ថភាពរបស់ខ្លួន។

ក្រៅពីគណៈធម្មាធិការខាងលើនេះ ក្រុមប្រឹក្សាស្រុកអាចបង្កើតគណៈធម្មាធិការបន្ថែមទៀត ទៅតាមតម្រូវការមូលដ្ឋាន ក៏ប៉ុន្តែមិនត្រូវមានតួនាទី ភារកិច្ចត្រួតគ្នាទៅនឹងគណៈធម្មាធិការទាំងបីខាងលើនឹងតួនាទីភារកិច្ច គណៈអភិបាលស្រុកឡើយ។

### ២.៤.២.អ្នកដឹកនាំរបស់សាលាស្រុកកៀនស្វាយ

- លោក **ឡូវ សុខសាន** អភិបាលស្រុកកៀនស្វាយ ទទួលបន្ទុកដឹកនាំការងាររួមនិងដឹកនាំផ្ទាល់លើការងាររដ្ឋបាលទូទៅ ការងារសន្តិសុខ សណ្តាប់ធ្នាប់សាធារណៈ កិច្ចការប្រយុទ្ធប្រឆាំងគ្រឿងញៀន កិច្ចការប្រយុទ្ធប្រឆាំងការជួញដូរមនុស្ស កិច្ចការគ្រប់គ្រងគ្រោះមហន្តរាយ និងជាអាណាប័ណ្ណក្នុងនាមក្រុមប្រឹក្សារបស់ខ្លួន។
- លោក **សន ហុងសេង** អភិបាលរងស្រុកកៀនស្វាយ ទទួលជួយអភិបាលស្រុក លើការងាររដ្ឋបាល ការងារគ្រប់គ្រង និងអភិវឌ្ឍធនធានមនុស្ស ការងារផ្តល់ សេវារដ្ឋបាល ការងារលេខាធិការក្រុមប្រឹក្សា និងការងារទំនាក់ទំនងសាធារណៈ។
- លោក **ស៊ុម ធន** អភិបាលរងស្រុកកៀនស្វាយទទួលជួយអភិបាលស្រុកលើការងារ ហិរញ្ញវត្ថុ ការងារថវិកា ការងារលទ្ធកម្មសាធារណៈ ការងារគ្រប់គ្រង់ទ្រព្យសម្បត្តិរដ្ឋ ការងារផែនការនិងគាំទ្រឃុំ សង្កាត់ ការងារស្ថិតិប្រជាជន ការងារអភិវឌ្ឍសហគមន៍។
- លោកស្រី **ហង្ស ចន្ថា** អភិបាលរងស្រុកកៀនស្វាយ ទទួលជួយអភិបាលស្រុកលើការងារអគ្រានុកូលដ្ឋាន ការងារសង្គមកិច្ច អតីតយុទ្ធជន យុវនីតិសម្បទា ការងារសុខាភិបាល កិច្ចការនារី ការងារធម្មការ និងសាសនា ការងារបណ្តុះបណ្តាលវិជ្ជាជីវៈ ការងារវប្បធម៌ និងវិចិត្រសិល្បៈ។

- លោក **សុខ ពិសិទ្ធ** អភិបាលរងស្រុកកៀនស្វាយ ទទួលជួយអភិបាលស្រុកលើការងាររៀបចំដែនដី នគរូបនីយកម្ម សំណង់ និងភូមិបាល ការងារគ្រប់គ្រង តំបន់ការពារធម្មជាតិ ការងារនីតិកម្ម និងសម្រុះសម្រួលវិវាទនៅមូលដ្ឋាន។
- លោក **ពៅ គីមលី** អភិបាលរងស្រុកកៀនស្វាយទទួលជួយអភិបាលស្រុកលើការងារសាធារណការ និងដឹកជញ្ជូន ការងារពាណិជ្ជកម្ម ឧស្សាហកម្ម សិប្បកម្ម ការងាររ៉ែ និងថាមពលការងារទេសចរណ៍ ការងារប្រៃសណីយ៍និងទូរគមនាគមន៍ ការងារអភិវឌ្ឍជនបទ ការងារគ្រប់គ្រងសំរាម សំណល់រឹងទីប្រជុំជន ការគ្រប់គ្រងប្រព័ន្ធលូ ការងារបំភ្លឺសាធារណៈ ការងារដាំដើមឈើ និងសួនច្បារសាធារណៈ។
- លោក **លីវ វណ្ណថេង** អភិបាលរងស្រុកកៀនស្វាយ ទទួលជួយអភិបាលស្រុកលើការងារកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ការងារធនធានទឹក ការងារអប់រំ យុវជន និងកីឡា ការងារត្រួតពិនិត្យផ្ទៃក្នុង និងការងារវេទិកាសាធារណៈ។

ក្រៅពីភារកិច្ចដែលបានបែងចែកខាងលើ អភិបាលស្រុកអាចប្រគល់ភារកិច្ចបន្ថែមជូនអភិបាលរងស្រុក ទៅតាមសំណូមពរការងារជាក់ស្តែងរបស់រដ្ឋបាលស្រុកកៀនស្វាយ។[15]

### ២.៤.៣.ការិយាល័យចំណុះរដ្ឋបាលស្រុកកៀនស្វាយ

ការិយាល័យចំណុះសាលាស្រុកមាន ៖

- ការិយាល័យរដ្ឋបាល និងហិរញ្ញវត្ថុ
- អង្គភាពលទ្ធកម្ម
- ការិយាល័យគ្រប់គ្រងធនធានមនុស្ស
- ការិយាល័យផែនការ និងគាំទ្រឃុំ
- ការិយាល័យត្រួតពិនិត្យផ្ទៃក្នុង
- ការិយាល័យលេខាក្រុមប្រឹក្សា
- ការិយាល័យអប់រំយុវជន និងកីឡាការិយាល័យរៀបចំដែនដី នគរូបនីយកម្ម សំណង់ និងភូមិបាល
- ការិយាល័យនីតិកម្ម និងសម្រុះសម្រួលវិវាទមូលដ្ឋាន
- ការិយាល័យកសិកម្ម ធនធានធម្មជាតិ និងបរិស្ថាន
- ការិយាល័យសេដ្ឋកិច្ច និងអភិវឌ្ឍសហគមន៍
- ការិយាល័យសង្គមកិច្ច និងសុខុមាលភាពសង្គម
- ការិយល័យច្រកចេញ ចូលតែមួយ។

[15] (សេចក្តីសម្រេចស្តីពីការបែងចែកតួនាទី ភារកិច្ច និងរបៀបរបបធ្វើការងារជូនគណៈអភិបាលស្រុកកៀនស្វាយ)

- ការិយាល័យជំនាញជុំវិញស្រុក មានបុគ្គលិក ប្រុស៧២ នាក់ ស្រី១៩ នាក់

នៅថ្នាក់ឃុំ ៖ ស្រុកបានរៀបចំបែងចែក ដែនដីរដ្ឋបាលឃុំចំនួន 8 និងចែកជា 67 ភូមិ ដែលគ្រប់គ្រងដោយក្រុមប្រឹក្សា ឃុំចំនួន៨០ នាក់ ស្រី១៨ នាក់ និង ភូមិចំនួន២០១ នាក់ ស្រី៨៨ នាក់ ។

## ២.៤.៤.ការគ្រប់គ្រងហិរញ្ញវត្ថុនិងទ្រព្យសម្បត្តិរបស់សាលាស្រុកកៀនស្វាយ[16]

### ២.៤.៤.១.គោលការណ៍

ក្រុមប្រឹក្សាស្រុកត្រូវគ្រប់គ្រងចាត់ចែងហិរញ្ញវត្ថុ និងទ្រព្យសម្បត្តិរបស់ខ្លួន ដើម្បីជានាដល់ការបង្កើត ការជម្រុញ និងការធ្វើអោយមានចីរភាពដល់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យ ដែលផ្តោតទៅលើតម្រូវការអភិវឌ្ឍសំខាន់ៗបំផុតរួមមាន៖

- តម្រូវការរបស់រដ្ឋបាលស្រុកក្នុងការរៀបចំសម្រាប់ទទួលមុខងារភារកិច្ច និងធនធានថ្មីៗ
- សេវា និងហេដ្ឋារចនាសម្ព័ន្ធសាធារណៈជាមូលដ្ឋានចាំបាច់
- ការកាត់បន្ថយភាពក្រីក្រ
- តម្រូវការផ្សេងៗរបស់ស្ត្រីបុរសយុវវ័យកុមារជនពិការ ជនចាស់ជរា ជនក្រីក្រ និងក្រុមជនងាយរងគ្រោះផ្សេងៗទៀត

### ២.៤.៤.២.ការគ្រប់គ្រងហិរញ្ញវត្ថុ

**ក.ប្រភពប្រាក់ចំណូល**

- **ប្រភពនៅមូលដ្ឋាន**

ចំណូលពីប្រភពនៅមូលដ្ឋានរបស់រដ្ឋបាលស្រុករួមមាន៖

- ចំណូលពីសារពើពន្ធនៅមូលដ្ឋានដែលជាចំណូលពន្ធ និងអាករដើម្បីជាប្រយោជន៍ដំថវិការរបស់សាលាស្រុក
- ចំណូលមិនមែនសារពើពន្ធនៅមូលដ្ឋានរួមមាន៖
  - ការជួលទ្រព្យសម្បត្តិ កម្រៃសេវា និងចំណូលផ្សេងៗរបស់រដ្ឋបាលស្រុក
  - ការបែងចែកចំណូលមិនមែនសារពើពន្ធនៅមូលដ្ឋាន រវាងរដ្ឋាបាលស្រុកជាមួយរដ្ឋបាលថ្នាក់ក្រោមជាតិផ្សេងៗ
  - អំណោយដែលបានមកពីប្រភពខាងក្នុង និងខាងក្រៅដែលសមត្ថកិច្ចរបស់រដ្ឋបាលស្រុក
  - ចំណូលពីប្រភពផ្សេងៗកំណត់ដោយច្បាប់ ឬលិខិតបទដ្ឋានគតិយុត្ត។

[16] (ណែនាំដោយសាស្ត្រាចារ្យ៖ វ័ត្ន សារ៉ុម,ប្រធានបទ៖ ការគ្រប់គ្រងរដ្ឋបាលស្រុកកៀនស្វាយឆ្នាំ២០១៤-២០១៥, ទំព័រ៦៦)

❖ **ប្រភពីថ្នាក់ជាតិ**

ចំណូលពីថ្នាក់ជាតិរបស់រដ្ឋបាលស្រុករួមមាន៖

- មូនិធិស្រុក គឺជាមូលដ្ឋាននិធិផ្ទេរគ្មានភ្ជាប់លក្ខខណ្ឌ រដ្ឋបាលស្រុកប្រើប្រាស់ធនធានដែលបានមកពីប្រភពចំណូលនេះសម្រាប់៖
    - បំពេញភារកិច្ចតាមផ្លូវច្បាប់
    - បំពេញមុខងារភារកិច្ចក្នុងការបង្កើត ការជម្រុញ និងធ្វើអោយមានចីរភាពដល់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យ
    - ចំណាយប្រតិបត្តិការរដ្ឋបាល
    - អនុវត្តមុខងារជាជម្រើស។
- មូលនិធិផ្ទេរមានភ្ជាប់លក្ខខណ្ឌជាមូលនិធិផ្ទេរភ្ជាប់មកជាមួយមុខងារដែលបានផ្ទេរ មូលនិធិវិនិយោគសម្រាប់រដ្ឋបាលថ្នាក់ក្រោមជាតិ និងមូលនិធិផ្សេងៗទៀតដែលបានកំណត់គោលដៅជាក់លាក់។ រដ្ឋបាលស្រុកប្រើប្រាស់ធនធានដែលបានមកពីប្រភពចំណូល សម្រាប់អនុវត្តមុខងារជាក់លាក់ដែលបានផ្ទេរពីក្រសួងស្ថាប័ណ្ឌថ្នាក់ជាតិ និងគម្រោងជាក់លាក់នានាតាមលក្ខខណ្ឌនៃការផ្ទេរមូលនិធិទាំងនោះ។
- ចំណូលបែងចែករំលែក គឺជាចំណូលដែលត្រូវចែករំលែករវាងថ្នាក់ជាតិជាមួយនិងរដ្ឋបាលថ្នាក់ក្រោមជាតិដែលពាក់ព័ន្ធ។
- ថ្លៃសេវាបានមកពីមុខងារជាភ្នាក់ងារ ដែលអនុវត្តក្នុងនាមក្រសួងស្ថាប័ណ្ឌ។ រដ្ឋបាលស្រុកប្រើប្រាស់ធនធានដែលបានមកពីប្រភពចំណូលនេះ សម្រាប់អនុវត្តមុខងារជាភ្នាក់ងារតាមរយៈកិច្ចសន្យា ឬកិច្ចព្រមព្រៀងដែលក្នុងនោះបានកំណត់ច្បាស់លាស់អំពីកិច្ចការដែលត្រូវធ្វើ ពេលវេលាដែលត្រូវអនុវត្ត និងលទ្ធផលដែលត្រូវសម្រេច។

**ខ.ក្របខ័ណ្ឌចំណាយ**

ក្របខ័ណ្ឌចំណាយរយៈពេលមធ្យម គឺជាឯកសារគ្រោងចំណាយរបស់រដ្ឋបាលស្រុកសម្រាប់រយៈពេលមិនតិចជាងបីឆ្នាំ និងមិនលើសពីប្រាំឆ្នាំដោយត្រូវបែងចែកចំណូលទៅតាមខ្ទង់ចំណាយនានារបស់រដ្ឋបាលត្រូវរៀបចំអនុម័ត អនុវត្តក្របខ័ណ្ឌចំណាយរយៈពេលមធ្យមរបស់ខ្លួនទៅតាមទម្រង់បែបបទ និងនិតិវិធីដែលកំណត់ដោយប្រការរបស់មន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ។

### ២.៤.៤.៣.ការគ្រប់គ្រងទ្រព្យសម្បត្តិ

**ក.ទ្រព្យសម្បត្តិដែលរដ្ឋផ្ទេរអោយ**

ទ្រព្យសម្បត្តិដែលរដ្ឋផ្ទេរអោយរដ្ឋបាលស្រុកមានសិទ្ធគ្រប់គ្រង ប្រើប្រាស់ និងទាញយកផលចំណូលពីទ្រព្យសម្បត្តិទាំងនោះ សម្រាប់ការផ្តល់សេវាសាធារណៈ និងធ្វើការអភិវឌ្ឍមូលដ្ឋានដែនសមត្ថកិច្ចរបស់ខ្លួន ហើយត្រូវថែរក្សា ការពារអោយបានគង់វង្ស និងគ្មានសិទ្ធលក់ដូរ ជួល ផ្ទេរកម្មសិទ្ធ ឬផ្ទេរការប្រេដីប្រាស់ដោយគ្មានការយល់ព្រមជាមុនពីរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុបន្ទាប់ពីមានការឯកភាពពីរដ្ឋមន្ត្រីក្រសួងមហាផ្ទៃបានឡើយ។

**ខ.ទ្រព្យសម្បត្តិដែលរកបានដោយខ្លួនឯង**

ទ្រព្យសម្បត្តិដែលរដ្ឋបាលស្រុករកបានដោយខ្លួនឯង គឺជាកម្មសិទ្ធផ្ទាល់របស់រដ្ឋបាលស្រុកមានសិទ្ធស្វ័យសម្រេចក្នុងការគ្រប់គ្រងនិងប្រើប្រាស់ ដើម្បីទាញយកផលចំណូលពីទ្រព្យសម្បត្តិទាំងនោះ សម្រាប់ការផ្តល់សេវាសាធារណៈ និងអភិវឌ្ឍមូលដ្ឋាននៅក្នុងដែនសមត្ថកិច្ចរបស់ខ្លួន។ ករណីចង់លក់ដូរ ឬផ្ទេរសិទ្ធ ឬការប្រើប្រាស់ទ្រព្យសម្បត្តិទាំងនេះ រដ្ឋបាលស្រុកត្រូវអនុវត្តតាមគោលការណ៍ដូចខាងក្រោម៖

- បង្កើតគណៈកម្មការមួយដើម្បីដំណើរការលក់ដូរ ឬផ្ទេរកម្មសិទ្ធ ឬផ្ទេរការប្រើប្រាស់ទ្រព្យសម្បត្តិ
- ដំណើរការនេះត្រូវធានាអោយមានតម្លាភាព និងបើកទូលាយការប្រគួតប្រជែងគ្នាជាសាធរណៈ
- អភិបាលស្រុកត្រូវសម្រេចដោយផ្អែកតាមអនុសាសន៍របស់គណៈកម្មការក្នុងនាមក្រុមប្រឹក្សារបស់ខ្លួន។

### ២.៤.៥.ផែនការអភិវឌ្ឍរយៈពេលប្រាំឆ្នាំ ២០២០ - ២០២៤[17]

#### ២.៤.៥.១.ផ្នែកសេដ្ឋកិច្ច

**ក.វិស័យធនធានទឹក**

- ➢ សាងសង់ និងកែលម្អប្រព័ន្ធធានាសាស្ត្រ
- ជួសជុលសន្ទះលូទឹកជ្រោយព្រីង
- ជួសជុលសន្ទះទ្វារទឹកមុខ៣ជ្រោយព្រីង
- ជួសជុលសន្ទះទ្វារទឹកព្រែកសំ
- ជួសជុលកម្រាលទ្វារគគីរ
- ស្តារកំណាត់ព្រៃដូង
- ជួសជុលទ្វារទឹកអូឈូក
- ស្តារប្រឡាយក្បាលកោះដីឥដ្ឋ

[17] (កិច្ចប្រជុំពិគ្រោះយោបល់លើសេចក្តីផែនការអភិវឌ្ឍស្រុក រយៈពេល៥ឆ្នាំ ២០២០-២០២៤)

- ស្ពានប្រឡាយគគីរ
- ក្លារទ្វារទឹកតាអែម
- ក្លារទ្វារទឹកជ្រោយព្រីង
- សាងសង់លូមុខកាត់មានទ្វារទឹក
- ស្ពានប្រឡាយទួលសេដា។

**ខ.វិស័យកសិកម្ម**

➢ កែលម្អបច្ចេកទេសដាំដុះនិងចិញ្ចឹមសត្វ
  - ជួសជុលពង្រីកអគារការិយាល័យ
  - បណ្តុះបណ្តាលកសិករគំរូដើម្បីប្រឡងប្រណាំង
  - អង្កេតស្ទង់ទិន្នផលស្រូវ
  - អប់រំបច្ចេសទេសដំណាំផ្សេងៗនិងការប្រើប្រាស់ ជី ថ្នាំកសិកម្មដោយសុវត្ថិភាព
  - ជ្រើសរើសបណ្តុះបណ្តាលភ្នាក់ងារសុវត្ថិភាពសត្វនិងភូមិ
  - វ៉ាក់សាំងគោក្របី។

**គ.វិស័យសាធារណៈការ**

➢ សាងសង់ផ្លូវបេតុងជនបទ
  - សាងសង់ផ្លូវបេតុងក្នុងឃុំគគីរ
  - សាងសង់ផ្លូវបេតុងក្នុងឃុំសំរោងធំ
  - សាងសង់ផ្លូវបេតុងក្នុងឃុំបន្ទាយដែក
  - សាងសង់ផ្លូវបេតុងក្នុងឃុំភូមិធំ
  - សាងសង់ផ្លូវបេតុងក្នុងឃុំកំពុងស្វាយ។

**ឃ.វិស័យប្រៃសណីយ៍ និងទូរគមនាគមន៍**

➢ ប្រជាពលរដ្ឋគ្រប់ៗគ្រួសារទទួលបានសេវាប្រៃសនីយ៍
  - ផ្សព្វផ្សាយលិខិតបទដ្ឋានគតិយុត្តក្នុងការប្រើប្រាស់ទូរស័ព្ទចល័ត និងផលប៉ះពាល់។

### ២.៤.៥.២.ផ្នែកសង្គមកិច្ច

**ក.វិស័យអប់រំ**

➢ ពង្រីកគុណភាពប្រព័ន្ធអប់រំ
  - ការអភិវឌ្ឍចំណេះដឹងនៅវិទ្យាល័យជ័យវរ្ម័នទី៧

- ការអភិវឌ្ឍចំណេះដឹងនៅវិទ្យាល័យសាន់នីវូសមរោងធំ
- ការអភិវឌ្ឍចំណេះដឹងនៅវិទ្យាល័យហ៊ុនសែនសិរីដីដុះ
- ការអភិវឌ្ឍចំណេះដឹងនៅអនុវិទ្យាល័យឫស្សីស្រុក
- ការអភិវឌ្ឍចំណេះដឹងនៅអនុវិទ្យាល័យរទាំង
- ការអភិវឌ្ឍចំណេះដឹងនៅមត្តេយ្យទួលត្នោត
- ជួសជុលដំបូលអគារសិក្សាមត្តេយ្យទួលត្នោត
- ជួសជុលសាលាមត្តេយ្យទួលត្នោត
- ដំណើរការការិយាល័យ
- សកម្មភាពចុះតាមសាលា
- ជួសជុលសម្ភារបរិក្ខាអេឡិចត្រូនិច
- គាំទ្រសម្ភាររដ្ឋបាល។

## ខ.វិស័យសុខាភិបាល

➢ លើកកម្ពស់ការថែទាំសុខភាពអនាម័យរបស់ប្រជាពលរដ្ឋ

- ផ្សព្វផ្សាយសុខភាពទូទៅតាមបណ្ឌលសុខភាពទាំង៧
- បណ្ដុះបណ្ដាលស្ដីពីអភិបាលកិច្ចដល់បុគ្គលិក
- បណ្ដុះបណ្ដាលបុគ្គលិកស្ដីពីក្រមសីលធម៌
- សាងសង់មណ្ឌលសុខភាពឃុំគគីរ
- ផ្សព្វផ្សាយសុខភាពមាតានិងទារក
- បណ្ដុះបណ្ដាលជំនាញពង្រឹងសមត្ថភាពមន្ត្រី
- សាងសង់កន្លែងរង់ចាំនៅមណ្ឌលសុខភាព។

## គ.វិស័យកិច្ចការនារី

➢ កាត់បន្ថយវិសមភាពយេនឌ័រ

- រៀបចំវេទិការផ្សព្វផ្សាយទប់ស្កាត់អំពើហិង្សារក្នុងគ្រួសារនិងកិច្ចការពារជនរងគ្រោះ
- រៀបចំបើកវគ្គបណ្ដុះបណ្ដាលស្ដីពីការពង្រឹងសមត្ថភាពអ្នកដឹកនាំជានារីថ្នាក់ឃុំ។

## ឃ.វិស័យសុខាមាលភាព

➢ លើកកម្ពស់ជីវភាពជនពិការ និងសមាគមន៍មនុស្សចាស់

- បណ្ដុះបណ្ដាលស្ដីពីការពង្រឹងការងារជនពិការ
- បណ្ដុះបណ្ដាលស្ដីពីការពង្រឹងសមាគមន៍មនុស្សចាស់។

**ង.វិស័យសុខាមាលភាព**

- លើកកម្ពស់ការថែទាំសុខភាពអនាម័យរស់នៅរបស់ប្រជាពលរដ្ឋ
  - សាងសង់បង្គន់អនាម័យចាក់ទឹក
  - ផ្គត់ផ្គង់ប្រដាប់ចម្រោះទឹក
  - ពិនិត្យគុណភាពទឹកអណ្តូងរកសារធាតុអាសេនិក
  - អប់រំស្តីពីការប្រើប្រាស់ទឹកស្អាតនិងអនាម័យ
  - បើកវគ្គបណ្តុះបណ្តាលជនបង្គោលអនាម័យភូមិ
  - បំផុសអនាម័យនិងត្រួតពិនិត្យតាមដានអនុវត្ត។

**២.៤.៥.៣.ផ្នែកធនធានធម្មជាតិ បរិស្ថាន ការបន្សាំ និងការប្រែប្រួលអាកាសធាតុ**

**ក.វិស័យបរិស្ថាន**

- ការគ្រប់គ្រងធម្មជាតិនិងបរិស្ថានដោយនិរន្តរភាព
  - អប់រំផ្សព្វផ្សាយលើការគ្រប់គ្រងសំណល់ ផង រាវ
  - ធ្វើស្លាកសញ្ញាបរិស្ថានតាមផ្លូវជាតិ ឃុំ និងទីប្រជុំជន
  - ត្រួតពិនិត្យតាមដានការចោលកាកសំណល់ រឹង រាវនិងផលប៉ះពាល់
  - ផ្សព្វផ្សាយដើម្បីទប់ស្កាត់ការជួញដូរសត្វព្រៃ សត្វស្លាបដែលជាសម្បត្តិធម្មជាតិ។

**ខ.វិស័យរៀបចំដែនដីនគរូបនីកម្ម សំណង់ និងភូមិបាល**

- ការផ្តល់ប័ណ្ណកម្មសិទ្ធស្របច្បាស់ជូនប្រជាពលរដ្ឋ
  - ការងារចុះបញ្ជីមានលក្ខណៈជាប្រព័ន្ធ
  - ការចុះបញ្ជីមានលក្ខណៈជាដុំ
  - ការវាស់វែងតាមពាក្យស្នើរសុំ
  - ការងារសំណង់(ច្បាប់សាងសង់)
  - ការងារលំនៅដ្ឋាន(សំណង់អានាធិបតេយ្យ)។

**២.៤.៥.៤.ផ្នែករដ្ឋបាល និងសន្តិសុខសណ្តាប់ធ្នាប់សាធារណៈ**

- ពង្រឹងសន្តិសុខភូមិ ឃុំ
  - អប់រំណែនាំអំពីភារកិច្ចរបស់ប្រជាការពារភូមិ
  - ផ្តល់សម្ភារលើកទឹកចិត្ត
  - ចុះល្បាតតាមភូមិនីមួយៗ។
- ពង្រឹងប្រព័ន្ធច្បាប់សន្តិសុខភូមិ ឃុំ

- ត្រួតពិនិត្យចរាចរណ៍
- សហការជាមួយប្រជាការពារចុះល្បាតតាមភូមិ
- ពង្រឹង និងអនុវត្តច្បាប់
- ដោះស្រាយទំនាស់ក្រៅប្រព័ន្ធតុលាការ។

➢ ពង្រឹងការគ្រប់គ្រងរដ្ឋបាល

- ដោះស្រាយទំនាស់ក្រៅប្រព័ន្ធតុលាការ
- បណ្តុះបណ្តាលជំនាញនានានៅថ្នាក់ស្រុក
- ប្រជុំរដ្ឋបាលស្រុក
- ប្រជុំក្រុមប្រឹក្សាស្រុក
- រៀបចំសន្និបាតនានាប្រចាំឆ្នាំ
- គាំទ្រការចុះបញ្ជីឈ្មោះបោះឆ្នោតក្នុងឆ្នាំ
- គាំទ្រការបោះឆ្នោតឃុំ សង្កាត់
- គាំទ្រការបោះឆ្នោតថ្នាក់ជាតិ
- គាំទ្រការបោះឆ្នោតក្រុមប្រឹក្សាស្រុក។

## ២.៤.៦.រចនាសម្ព័ន្ធរបស់រដ្ឋបាលស្រុកនិងខេត្ត




រូបភាពទី២៖ រចនាសម្ព័ន្ធរបស់រដ្ឋបាលស្រុកកៀនស្វាយ




រូបភាពទី៣៖ រចនាសម្ព័ន្ធរដ្ឋបាលខេត្ត

## ២.៥.ការចុះបញ្ជីកំណើតនិងសណ្តាប់ធ្នាប់សន្តិសុខសាធារណៈ

### ២.៥.១.ការចុះបញ្ជីកំណើត

ចំនួនកុមារដែលបានកើតក្នុងឆ្នាំមានចំនួន 1.854នាក់ ហើយបានមកចុះបញ្ជីកំណើតប្រមាណ 95,60% នៅសល់ 4,40% ទៀតមិនទាន់ចុះបញ្ជីក្នុងនោះមានតែឃុំបន្ទាយដែក និងគគីរធំប៉ុណ្ណោះដែលអនុវត្តសម្រេចបាន100% ក្រៅពីនេះសុទ្ធតែមានចន្លោះពី 80-100% ឃុំកំពង់ស្វាយមានអត្រាកម្រិតទាប ។

ចំនួនកុមារពី 0-5ឆ្នាំ មានចំនួន13.522នាក់ ប៉ុន្តែភាគរយនៃកុមារក្នុងកម្រិតអាយុនេះមានសំបុត្រកំណើតតែ 8.90%ប៉ុណ្ណោះ។

### ២.៥.២.សណ្តាប់ធ្នាប់សន្តិសុខសាធារណៈ

រដ្ឋបាលស្រុកបានរៀបចំអោយមានប៉ុស្តិ៍នគរបាលរដ្ឋបាលឃុំទាំង៨ និងមានមន្ត្រីប្រចាំការសម្រាប់ធានាសន្តិសុខ សណ្តាប់ធ្នាប់ ជូនប្រជាពលរដ្ឋនៅក្នុងស្រុក ។ គោលនយោបាយភូមិ-ឃុំ មានសុវត្ថិភាព គឺជាការងារអាទិភាពចម្បងដែលគណៈបញ្ជាការឯកភាពស្រុកបាននឹងកំពុងយកចិត្តទុកដាក់ជាប្រចាំគោលនយោបាយនេះ ត្រូវបានប្រជាពលរដ្ឋគ្រប់រូប គ្រប់និន្នាការនយោបាយនៅទូទាំងស្រុកអបអរសាទរ ចូលរួមសហការ និងផ្តល់ទំនុកចិត្តយ៉ាងស្អិតរមួតជាមួយអាជ្ញាធរ ។

- លក្ខណៈសម្បត្តិគោលនយោបាយភូមិ ឃុំ ទាំង៩យ៉ាងមាន ៖
    - គ្មានសកម្មភាពឆក់ប្លន់គ្រប់ប្រភេទ
    - គ្មានការដាំដុះការផលិត ការចរាចរ ការជួញដូរ ការចែកចាយ និងការប្រើប្រាស់គ្រឿងញៀនខុសច្បាប់
    - គ្មានអំពើអាណាចារ្យ ការជួញដូរស្ត្រី កុមារ និងអំពើហិង្សាក្នុងគ្រួសារ
    - គ្មានក្មេងទំនើង
    - គ្មានការលេងល្បែងស៊ីសងគ្រប់ប្រភេទ ការប្រើប្រាស់អាវុធខុសច្បាប់ និងបទល្មើសគ្រប់ប្រភេទ
    - គ្មានគ្រោះថ្នាក់ចរាចរណ៍
    - គ្មានគ្រោះថ្នាក់ដោយយុទ្ធភណ្ឌមិនទាន់ផ្ទុះ
    - មានវិធានការទប់ស្កាត់គ្រប់គ្រង និងឆ្លើយតបចំពោះគ្រោះមហន្តរាយប្រកបដោយប្រសិទ្ធភាព
    - គ្មានការត្រួពិនិត្យខុសច្បាប់។

ដើម្បីសម្រេចបានគោលនយោបាយខាងលើគ្រប់ប៉ុស្តិ៍រដ្ឋបាលប្រចាំឃុំនីមួយៗ ធ្វើការផ្សព្វផ្សាយជាប្រចាំផ្តល់លេខទូរស័ព្ទនាយប៉ុស្តិ៍ និងនាយរងប៉ុស្តិ៍ជូនប្រជាពលរដ្ឋដើម្បីងាយស្រួលក្នុងការទំនាក់ទំនងផ្តល់ព័ត៌មានពេលមានបាតុភាពអវិជ្ជមាន។ លេខទូរស័ព្ទនេះអាចទំនាក់ទំនងបានគ្រប់២៤ម៉ោង លើ២៤ ម៉ោង។

## ២.៦.ការគ្រប់គ្រងឯកសារ

រដ្ឋបាលក្រុង ស្រុក គឺជាម្ចាស់នូវរាល់លិខិតនិងឯកសារទាំងអស់ដែលរៀបចំឡើងដោយក្រុមប្រឹក្សា ឬក្នុងនាមក្រុមប្រឹក្សា និងដោយគណៈអភិបាលក្នុងនាមរដ្ឋ។

រដ្ឋបាលក្រុង ស្រុក ត្រូវធានាទុកដាក់លិខិត និងឯកសារទាំងអស់របស់ខ្លួនព្រមទាំងលិខិត ឯកសារដែលខ្លួនទទួលបានឱ្យមានរបៀបរៀបរយសណ្តាប់ធ្នាប់ល្អ និងគង់វង្ស។

### ២.៦.១.និយមន័យ

ការគ្រប់គ្រងឯកសារ គឺជាការរៀបចំទុកដាក់និងថែរក្សាឯកសារទាំងអស់របស់រដ្ឋបាលក្រុង ស្រុក ទៅតាមប្រព័ន្ធជាក់លាក់មួយ ដើម្បីធានាថាឯកសារទាំងនោះត្រូវរក្សាទុកដោយមានរបៀបរៀបរយ មានសណ្ដាប់ធ្នាប់ មានសុវត្ថិភាព និងមានលក្ខណៈងាយស្រួលក្នុងការប្រើប្រាស់។

### ២.៦.២.អត្ថប្រយោជន៍

ការគ្រប់គ្រងឯកសារបានល្អនឹងផ្ដល់នូវអត្ថប្រយោជន៍ដូចខាងក្រោម៖

- ផ្ដល់ភាពងាយស្រួលក្នុងការស្វែងរកព័ត៌មានឬទិន្នន័យដែលត្រូវការ
- ជួយបន្តនិរន្តរភាពព័ត៌មាន នៅពេលមានអ្នកមកទទួលការងារថ្មី និងឬផ្លាស់ចេញ
- ផ្ដល់នូវភស្តុតាងជាក់លាក់អំពីកិច្ចការឬព្រឹត្តិការណ៍ដែលបានកើតឡើងរួចហើយ
- ជួយបង្កើនប្រសិទ្ធភាពការងារជាដើម។

### ២.៦.៣.ប្រភេទឯកសារ

ឯកសាររបស់រដ្ឋបាលក្រុង ស្រុក អាចបែងចែកជាពីរប្រភេទ គឺ៖

- **ឯកសារសាធារណៈ** គឺជាឯកសារទាំងឡាយណាដែលមិនត្រូវបានហាមឃាត់ដោយច្បាប់ លិខិតបទដ្ឋានគតិយុត្តជាធរមានដោយក្រុមប្រឹក្សា និងដោយគណៈអភិបាលក្នុងការផ្សព្វផ្សាយជាសាធារណៈ។ ឯកសារសាធារណៈរបស់រដ្ឋបាលក្រុង ស្រុក អាចត្រូវបានប្រើប្រាស់ដោយសាធារណជន តាមតម្រូវការ។
- **ឯកសារផ្ទៃក្នុង** គឺជាឯកសារទាំងឡាយណាដែលត្រូវបានហាមឃាត់ដោយច្បាប់ លិខិតបទដ្ឋានគតិយុត្តនានាជាធរមានដោយក្រុមប្រឹក្សា និងដោយគណៈអភិបាលក្នុងការផ្សព្វផ្សាយជាសាធារណៈ។ ឯកសារផ្ទៃក្នុងរបស់រដ្ឋបាលក្រុង ស្រុក អាចត្រូវបានអនុញ្ញាតឱ្យប្រើប្រាស់ចំពោះតែបុគ្គលទាំងឡាយណាដែលទទួលបាននូវការអនុញ្ញាតពីច្បាប់ លិខិតបទដ្ឋានគតិយុត្តជាធរមាន ក្រុមប្រឹក្សា និងគណៈអភិបាលប៉ុណ្ណោះ។

### ២.៦.៣.ការរក្សាទុកឯកសារ

ជាទូទៅ អង្គភាពនីមួយៗតែងតែធ្វើការគ្រប់គ្រងឯកសាររបស់ខ្លួនក្នុងទម្រង់ជាឯកសារអេឡិចត្រូនិក និងទម្រង់ជាឯកសារបោះពុម្ព ដោយប្រើប្រាស់បច្ចេកទេសគ្រប់គ្រងឯកសារនានាបញ្ចូលគ្នា ហើយរក្សាទុកឯកសារទាំងនោះនៅច្រើនកន្លែង។

- **ឯកសារអេឡិចត្រូនិក** គឺជាឯកសារដែលអាចរក្សាទុកនៅក្នុងប្រព័ន្ធអេឡិចត្រូនិក ឬប្រព័ន្ធកុំព្យូទ័រ។

- **ឯកសារបោះពុម្ព** គឺជាឯកសារដែលបានបោះពុម្ពនៅលើក្រដាស។

រដ្ឋបាលក្រុង ស្រុក ត្រូវរក្សាទុកដាក់ឯកសាររបស់ខ្លួនក្នុងទម្រង់ជាឯកសារអេឡិចត្រូនិក និងទម្រង់ជាឯកសារបោះពុម្ពទៅតាម៖

- **ឈ្មោះរបស់បុគ្គលិក អក្ខរក្រម និងកាលប្បវត្តិ** ចំពោះឯកសារដែលពាក់ព័ន្ធនឹងការគ្រប់គ្រងបុគ្គលិក។
- **ប្រភេទឯកសារនិងកាលប្បវត្តិ** ចំពោះឯកសារទាំងអស់លើកលែងតែឯកសារដែលពាក់ព័ន្ធ នឹងការគ្រប់គ្រងបុគ្គលិក។[18]

[18] (ក្រសួងមហាផ្ទៃ,២០២៣,សៀវភៅណែនាំស្តីពីការគ្រប់គ្រងកិច្ចការរដ្ឋបាលរបស់រដ្ឋបាលក្រុង ស្រុក,ទំព័រ១៩៨)

# ជំពូក ៣

# បញ្ហាប្រឈម យុទ្ធសាស្ត្រដំណោះស្រាយ ដើម្បីអភិវឌ្ឍរបស់ស្រុកកៀនស្វាយ និង របបគំហើញ

# ជំពូក ៣
# បញ្ហាប្រឈម យុទ្ធសាស្ត្រដំណោះស្រាយដើម្បីអភិវឌ្ឍរបស់ស្រុកកៀនស្វាយ និងគំហើញ

## ៣.១. និយមន័យ

បញ្ហាប្រឈម គឺជាកិច្ចការពិបាក ឬបញ្ហាដែលទាមទារការខិតខំប្រឹងប្រែង ជំនាញ ឬការតាំងចិត្តដើម្បីយកឈ្នះ។ បញ្ហាប្រឈមអាចត្រូវបានរកឃើញនៅក្នុងទិដ្ឋភាពផ្សេងៗនៃជីវិត រួមទាំងការខិតខំប្រឹងប្រែងផ្ទាល់ខ្លួន វិជ្ជាជីវៈ ការសិក្សា និងអត្តពលិក។ ការយកឈ្នះលើបញ្ហាប្រឈមជារឿយៗពាក់ព័ន្ធនឹងការកំណត់គោលដៅ ការអភិវឌ្ឍយុទ្ធសាស្ត្រ ការប្រឈមមុខនឹងឧបសគ្គដោយភាពធន់ និងការសម្របខ្លួន។ បញ្ហាប្រឈមអាចផ្តល់ឱកាសសម្រាប់ការលូតលាស់ ការរៀនសូត្រ និងការកែលម្អខ្លួនឯង។ ការទទួលយកបញ្ហាប្រឈមអាចនាំឱ្យមានការបង្កើនទំនុកចិត្ត ការលើកទឹកចិត្ត និងអារម្មណ៍នៃការសម្រេចបាន។ សមត្ថភាពក្នុងការដោះស្រាយបញ្ហាប្រឈមប្រកបដោយប្រសិទ្ធភាពត្រូវបានចាត់ទុកថាជាជំនាញដ៏មានតម្លៃក្នុងការរុករកភាពមិនច្បាស់លាស់ និងភាពស្មុគស្មាញនៃជីវិត។ ការជួបបញ្ហាប្រឈមមុខអាចជំរុញភាពច្នៃប្រឌិត ការច្នៃប្រឌិត និងការអភិវឌ្ឍផ្ទាល់ខ្លួន។

## ៣.២. បញ្ហាប្រឈម

### ៣.២.១. បញ្ហាប្រឈមវិស័យសេដ្ឋកិច្ច

ស្រុកកៀនស្វាយ ជាស្រុកមួយដែលមានវិសាលភាពគ្របដណ្តប់ដោយដីកសិកម្មជាអំណោយផលរបស់ធម្មជាតិ ជាស្រុកមួយដែលជាប់នឹងមជ្ឈមណ្ឌលសេដ្ឋកិច្ច សង្គមកិច្ច នយោបាយរបស់ប្រទេសហើយជាស្រុកដែលផ្គត់ផ្គង់ ផលិតផលកសិកម្មទៅរាជធានីភ្នំពេញ ។

**តាមទិន្នន័យស្រុកឆ្នាំ២០១៩ ៖**

- ពលកម្មសរុបរបស់ស្រុកពី១៨-៦០ ឆ្នាំ មានចំនួន៧៤.១៧២ គិតជាភាគរយ ៥៦,៤៤% នៃប្រជាជនសរុប ។
- ចែកជាពលកម្មប្រុសចំនួន 36,307 នាក់ គិតជាភាគរយ 49% នៃពលកម្មសរុប
- ចែកជាពលកម្មស្រីចំនួន 37,865 នាក់ គិតជាភាគរយ 51% នៃពលកម្មសរុប ចំណែមុខរបរចម្បងមានចំនួន 55,604 នាក់ នៃពលកម្មសរុប ចែកជា៖
  - ប្រុសមានមុខរបរចម្បង 72,40% នៃពលកម្មសរុប
  - ស្រីមានមុខរបរចម្បង 56,3% នៃពលកម្មសរុប។

ប្រជាកសិករដែលមានមុខរបរដាំដុះ និងចិញ្ចឹមសត្វគ្រប់ប្រភេទជាចម្បងបានស្រូបសមាមាត្រប្រមាណ 51,10% នៃពលកម្មសរុបរបស់ស្រុក ។ ប្រជាពលរដ្ឋដែលមានមុខរបរចម្បងផ្នែកសិប្បកម្ម មានសមាមាត្រប្រមាណ0.20% ប៉ុណ្ណោះនៃពលកម្មសរុបរបស់ស្រុក មានន័យថាផលិតផលរបស់សិប្បកម្ម ឧស្សាហកម្មចាំបាច់មួយចំនួនចំពោះជីវភាពរស់នៅប្រចាំថ្ងៃ ត្រូវនាំចូលពីក្រៅស្រុក ឬពីបរទេសដែលមានតម្លៃខ្ពស់ ។

ដោយឡែកប្រជាពលរដ្ឋមានមុខងារចម្បងផ្នែកសេវាកម្មទូទៅមានសមាមាត្រប្រហាក់ប្រហែលទៅនឹងវិស័យកសិកម្ម គឺប្រមាណ48,60% នៃពលកម្មសរុបរួមមានសេវាសកម្មផ្គត់ផ្គង់គ្រឿងឧបភោគ (ផលិតផលរបស់សិប្បកម្ម ឧស្សាហកម្ម) បរិភោគ (គ្រឿងទេស) សេវាកម្មហូបចុក និងជួសជុលផ្សេងៗ ជាច្រើនទៀតដែលបង្ហាញអោយឃើញថាជីវភាពរស់នៅប្រចាំថ្ងៃរបស់ប្រជាពលរដ្ឋត្រូវបានលើកកម្ពស់ ។

**៣.២.១.១.បញ្ហាប្រឈមវិស័យកសិកម្ម**

អ្នកមានមុខរបរចម្បងផ្នែកនេះមានកម្រិតខ្ពស់ក៏ពិតមែន តែនៅតែមិនអាចផ្គត់ផ្គង់បានតាមតម្រូវការក្នុងស្រុកបានឡើយ គឺអាចផ្គត់ផ្គង់បានត្រឹមតែអ្នកផលិតប៉ុណ្ណោះចំណែក អង្ករ ត្រី សាច់ មួយចំនួនត្រូវនាំចូលពីតំបន់ដ៏ទៃទៀតសម្រាប់ការហូបចុកប្រចាំថ្ងៃ ។

ចំណែកបរិមាណផលិតផលស្រូវមាន 48.847,4 តោនក្នុងឆ្នាំ តែតម្លៃស្រូវលក់បានមានប្រមាណពី 750រៀលក្នុងមួយគីឡូក្រាម ទៅ 928រៀលក្នុងមួយគីឡូក្រាមប៉ុណ្ណោះ។ ទិន្នន័យឆ្នាំ២០១៩ហើយចំណូលជាមធ្យមក្នុងម្នាក់ពីដំណាំស្រូវមាន78$ ក្នុងមួយនាក់ក្នុងមួយឆ្នាំ ចំណូលជាមធ្យមរបស់អ្នកដាំដំណាំរយៈពេលខ្លីមាន ៧,៩$ក្នុងមួយនាក់ក្នុងមួយឆ្នាំ ប៉ុន្តែចំពោះដំណាំរយៈពេលវែងមាន 374$ក្នុងមួយនាក់ក្នុងមួយឆ្នាំ ដោយឡែកចំណូលមធ្យមពីវារីវប្បកម្មមានតែ 33,3$ក្នុងមួយនាក់ក្នុងមួយឆ្នាំ ។

សរុបមកចំណូលទាំងអស់នេះពុំមានតួរលេខនៃការចំណាយក្នុងការផលិតទេ ប៉ុន្តែតាមធម្មតាចំណាយក្នុងផ្នែកនេះស្រូវសមាមាត្រខ្ពស់ណាស់ហើយប្រើរយៈពេលយូរ ព្រោះវិស័យនេះមានលក្ខណៈអោយផលជារដូវកាល ប៉ុន្តែការប្រើប្រាស់គឺពេញមួយឆ្នាំ ។

**៣.២.១.២.ស្ថានភាពដីស្រែចំការរបស់កសិករ**

តាមធម្មតា និងសត្យានុម័ត គឺរាល់ការដាំដុះ ចិញ្ចឹមសត្វផ្សេងៗគឺត្រូវមានដីកម្មសិទ្ធផ្ទាល់ខ្លួន ឬជួលពីអ្នកដទៃ ដែលជាមធ្យោបាយផលិតកម្មមិនអាចខ្វះបានក្នុងវិស័យនេះតាមទិន្នន័យឆ្នាំ២០១៩ ស្ថានភាពដីស្រែចំការរបស់កសិករមាន ៖

- គ្រួសារមានដីស្រែជាង១ហិកតា មាន 111 គ្រួសារគិតជាភាគរយ 25% នៃគ្រួសារសរុប
- គ្រួសារគ្មានដីស្រែផ្ទាល់ខ្លួនមាន 5.761 គិតជាភាគរយ 20,18% នៃគ្រួសារសរុប
- គ្រួសារមានដីដាំដំណាំតិចជាង ១ ហិកតា មាន 9.720 គិតជាភាគរយ 34,05% នៃគ្រួសារសរុប
- គ្រួសារគ្មានដីផ្ទាល់ខ្លួន មាន 5.801 គិតជាភាគរយ 20,32% នៃគ្រួសារសរុប។

- **តាមទិន្នន័យខាងលើនេះអាចសង្កេតឃើញថា ៖**
  - ក្នុងនាមជាកសិករគ្មានដីស្រែផ្ទាល់ខ្លួនមាន 20,18%
  - ក្នុងនាមកសិករគ្មានដីចំការផ្ទាល់ខ្លួនមាន20,32%
  - សរុបក្នុងនាមកសិករគ្មានដីស្រែចំការផ្ទាល់ខ្លួនមានរហូតដល់ទៅ 40,50% នៃគ្រួសារសរុបក្នុងស្រុក ។
- **នៅមានកត្តាមួយចំនួនទៀតដូចជា ៖**
  - គ្រួសារនីមួយៗមានសមាជិកកើនឡើងតែផ្ទៃដីដាំដុះនៅដដែល
  - តម្រូវការច្រើននាំឲ្យកើនបរិមាណផលិតផលដើម្បីបំពេញតម្រូវការ
  - ត្រូវប្រើប្រាស់សារធាតុគីមីច្រើន ដើម្បីបានបរិមាណផលច្រើននាំឲ្យកសិផលផ្ទុកសារធាតុគីមីប៉ះពាល់ សុខភាពអ្នកផលិត និងអ្នកប្រើប្រាស់ ។
  - ខូចគុណភាពដីជាកត្តាធ្វើអោយផលិតផលថយចុះមិនបំពេញតម្រូវការបាន នាំអោយប្រជាពលរដ្ឋស្វែងរកការងារធ្វើនៅកន្លែងផ្សេងៗ ឬក្រៅស្រុក (ទិន្នន័យឆ្នាំ២០១៩) ។

### ៣.២.១.៣.វិស័យសេវាកម្មផ្សេងៗ

អាស្រ័យដោយបញ្ហាប្រឈមផ្សេងៗក្នុងវិស័យកសិកម្មនេះហើយដែលប្រជាកសិករមួយភាគធំត្រូវតែចាប់មុខរបរចម្បងមួយទៀតគឺសេវាកម្មបំរើផ្សេងៗ ដូចជាលក់គ្រឿងបរិភោគមានទំនិញផលិតផលរបស់សិប្បកម្ម និងឧស្សាហកម្មផ្សេងៗលក់គ្រឿងទេសគ្រប់មុខ ឬក៏សេវាកម្មបំរើការហូបចុកតូចធំរាយបណ្តាក់នៅតាមគ្រប់ភូមិក្នុងស្រុក ដែលជាតម្រូវការចាំបាច់មិនអាចខ្វះបានរបស់ប្រជាពលរដ្ឋក្នុងការប្រើប្រាស់ប្រចាំថ្ងៃរបស់ពួកគាត់ ។

ប៉ុន្តែក្នុងនោះក៏មានអាជីវកម្មខ្លះបានបិទទ្វាររព្រោះគ្មានអតិថិជនគាំទ្រ ចំណែកខ្លះទៀតអាចដំណើការរហូតដល់បច្ចុប្បន្ន ។

### ៣.២.១.៤.ការស្វែងរកការងារធ្វើក្រៅស្រុក

បាតុភូតនេះកើតឡើងអាស្រ័យដោយប្រការជាច្រើនដូចជា ៖

- មានកម្លាំងពលកម្មតែគ្មានដីស្រែ ចំការ សម្រាប់ប្រកបអាជីវកម្ម
- កង្វះដើមទុនមានតែកម្លាំងពលកម្ម
- កង្វះជំនាញបច្ចេកទេសផ្សេងៗ
- ខាតបង់ក្នុងការធ្វើអាជីកម្ម
- និងប្រការផ្សេងៗទៀតជាច្រើន

ដូច្នេះកត្តាទាំងនេះហើយដែលតម្រូវ ឬចាប់បង្ខំអោយធ្វើចំណាកស្រុកស្វែងរកការងារធ្វើដើម្បីទ្រទ្រង់ជីវភាពក្នុងគ្រួសារ ។

- ចំនួនអ្នកធ្វើចំណាកស្រុកក្នុងប្រទេសអាយុ 18 ឆ្នាំឡើងទៅមាន 3,442 នាក់គិតជាភាគរយ4% នៃពលកម្មសរុបក្នុងស្រុក
- ចំនួនអ្នកធ្វើចំណាកស្រុកនៅក្រៅប្រទេសអាយុ18 ឆ្នាំឡើងមាន 1.016 នាក់ គិតជាភាគរយ1,2% នៃពលកម្មសរុបក្នុងស្រុក (ទិន្នន័យឆ្នាំ២០១៩) ។

បញ្ហាពលករទាំង២ប្រភេទខាងលើនេះ(ទាំងចំណាកស្រុកក្នុងប្រទេស និងក្រៅប្រទេស) សុទ្ធតែប្រឈមទាំងអស់គ្រាន់តែតិច ឬច្រើនប៉ុណ្ណោះដូចជា ៖

- ការកេងប្រវ័ញ្ចពលកម្ម រំលោភផ្លូវភេទផ្សេងៗ
- ការចាញ់បោកមេខ្យល់ទៅរកការងារដែលអាចមានគ្រោះថ្នាក់ដល់ជីវិត
- គ្រោះថ្នាក់ការងារក្លាយជាពិកា ឬស្លាប់
- និងប្រការផ្សេងៗទៀតជាច្រើន។

### ៣.២.២. បញ្ហាប្រឈមវិស័យសង្គមកិច្ច

ចំពោះវិស័យសង្គម និងវប្បធម៌ សិល្បៈ ស្រុកមានការរីកចម្រើនវិវត្តប្រែប្រួលរាល់ថ្ងៃដែលមានសមាមាត្រស្របគ្នាទៅនឹងការវិវត្តប្រែប្រួលនៃសេដ្ឋកិច្ចរបស់ស្រុកមានន័យថានៅពេលដែលជីវភាពល្អបង្គួរ នោះតម្រូវការអំពីការយល់ដឹងពីសង្គមតាមរយៈការសិក្សាស្រាវជ្រាវ តាមរយៈការទទួលព័ត៌មានពិតទន្ទឹមនឹងនោះតម្រូវការអំពីការធ្វើទេសចរណ៍លំហែកាយនៅតាមមណ្ឌលវប្បធម៌ ឬតាមមណ្ឌលកំសាន្តផ្សេងៗ កើតឡើង ។

### ៣.២.៣. បញ្ហាប្រឈមវិស័យអប់រំ

វិស័យអប់រំ គឺជាវិស័យមូលដ្ឋានគ្រឹះនៃការអភិវឌ្ឍសង្គម និងសេដ្ឋកិច្ចដែលមិនអាចខ្វះបានរបស់ប្រជាពលរដ្ឋគ្រប់ៗរូប ដែលរស់នៅក្នុងប្រទេសនីមួយៗ ។

- **អំពីសាលា( ទិន្នន័យឆ្នាំ២០១៩ )**

វិស័យនេះប្លែកពីវិស័យដទៃៗទៀត ព្រោះមានវិសាលភាពគ្របដណ្តប់លើប្រជាពលរដ្ឋគ្រប់ៗរូប គ្រប់ៗគ្រួសារ និយាយជារួមប្រសិនបើអនក្ខរជនមានចំនួនតិចឬច្រើនវាជះឥទ្ធិពលអាក្រក់ដល់គ្រួសារ និងសង្គមទាំងមូលក៏អាចថាបានក្នុងនោះសង្កេតឃើញថា ៖

១-ថ្នាក់ដំបូង គឺថ្នាក់មត្តេយ្យសិក្សាកុមារដែលដល់អាយុចូលរៀនមានសមាមាត្រតែ49% ប៉ុណ្ណោះដែលគិតជាភាគរយ 4.168នាក់ នៅសល់កុមារក្រៅសាលារហូតដល់ 4.316 នាក់គិតជាភាគរយ 50,90% នៃកុមារ

3-5 ឆ្នាំសរុប ។

២-ចំពោះបឋមសិក្សា គឺកុមារអាយុ 6ឆ្នាំ ដែលត្រូវបានចូលរៀនទោះកុមារនេះរៀននៅថ្នាក់មត្តេយ្យក៏ដោយ ក៏អត្រាកុមារ 6ឆ្នាំ នៅក្រៅសាលានៅមានកម្រិតខ្ពស់គិតជាភាគរយ10,20% នៃកុមារអាយុ 6 ឆ្នាំ សរុប ។

៣-នៅថ្នាក់បឋមសិក្សាដែលកុមារចាប់ពីអាយុ 6-11 ឆ្នាំ នៅក្រៅសាលានៅតែរក្សាតួលេខ4ខ្ទង់ នៅឡើយគឺ1.169 នាក់ ដែលបោះបង់ចោលការសិក្សា ។

៤-ដោយឡែកកុមារដែលត្រូវចូលអនុវិទ្យាល័យហើយបោះបង់ការសិក្សានៅតែរក្សាតួលេខ ៣ខ្ទង់ គឺ575 នាក់ គិតជាភាគរយ7,10% ។

- ❖ សរុបមកអត្រាការបោះបង់កាសិក្សារបស់កុមារនៅមានគ្រប់កម្រិតគឺ ៖
  - អត្រាបោះបង់នៅមត្តេយ្យសិក្សាគិតជាភាគរយ 50,90% គឺ(ចំនួន4.316 នាក់)
  - អត្រាបោះបង់នៅបឋមសិក្សាគិតជាភាគរយ 10,20% គឺ(ចំនួន 388 នាក់)
  - អត្រាបោះបង់នៅអនុវិទ្យាល័យគិតជាភាគរយ 7,10% គឺ (ចំនួន 575 នាក់)។

### ៣.២.៤. បញ្ហាប្រឈមវិស័យសុខាភិបាល

បញ្ហាប្រឈមវិស័យសុខាភិបាលគឺ

- ចំនួនកុមារកំព្រាដែលឪពុកម្តាយស្លាប់ដោយជំងឺអេដស៍មាន 45នាក់
- ចំនួនចាស់ជរាគ្មានទីពឹងអាយុ61ឆ្នាំ ឡើងទៅមាន 45 នាក់
- ចំនួនស្ត្រីរងគ្រោះដោយអំពើហិង្សា 7 នាក់
- ចំនួនស្ត្រីរងគ្រោះដោយចាប់រំលោភ 5 នាក់។

### ៣.២.៥. បញ្ហាប្រឈមវិស័យការគ្រប់គ្រងធនធានធម្មជាតិ បរិស្ថាន ការសន្សំនិងការប្រែប្រួលអាកាសធាតុ

គ្រួសារទទួលរងផលប៉ះពាល់ធ្ងន់ធ្ងរពីទឹកជំនន់មាន ៤៩ គ្រួសារ ស្ថិតក្នុងឃុំដីឥដ្ឋ កំពង់ស្វាយ និងគគីរធំ មានមនុស្សចំនួន ១៥២ នាក់ ក្នុងនោះស្លាប់ ៣នាក់ នៅឃុំបន្ទាយដែក ។

- ឃុំសំរោងធំខូចខាតស្រូវអស់២០ ហិកតា
- ខូចខាតផ្លូវប្រវែង ៧,៤៧៦ គីឡូម៉ែត្រ
- អត្រាគ្រួសារប្រើប្រាស់ជីគីមីមាន ៣៦,៥០%
- អត្រាគ្រួសារប្រើប្រាស់ថ្នាំគីមីមាន ៣៦,៥០%
- ចំនួនគ្រួសារពុំមានសេវាប្រមូលសំរាម ៩៤%។

### ៣.២.៦. បញ្ហាប្រឈមវិស័យគ្រប់គ្រងរដ្ឋបាល និងសណ្តាប់ធ្នាប់សាធារណៈ

#### ៣.២.៦.១. បញ្ហាប្រឈមវិស័យគ្រប់គ្រងរដ្ឋបាលសាធារណៈ

អនុវត្តតាមស្មារតីអនុក្រឹត្យ លេខ ១៨៤ អនក្រ.បក ចុះថ្ងៃចន្ទ ៦កើត ខែមិគសិរ ឆ្នាំកុរ ឯកស័ក ពស ២៥៦៣ ត្រូវនឹងថ្ងៃទី២ ខែធ្នូ ឆ្នាំ២០១៩ ស្តីពីមុខងារ និងរចនាសម្ព័ន្ធរដ្ឋបាលស្រុក ។

- ការិយាល័យមួយចំនួនពុំមានមន្ត្រីបំរើការគ្រប់គ្រាន់
- ការងារច្រើនចំនួនមន្ត្រីមានតិច
- ការដោះស្រាយទំនាស់ក្រៅប្រព័ន្ធតុលាការមានការយឺតយ៉ាវ
- មន្ត្រីមួយចំនួនតូចការយល់ដឹងនៅមានកម្រិត។

#### ៣.២.៦.២.បញ្ហាប្រឈមសណ្តាប់ធ្នាប់សាធារណៈ

ទោះបីគណៈបញ្ជាការឯកភាពស្រុកខិតខំយ៉ាងណាក៏ដោយ ស្រុកនៅតែទទួលរងនូវបញ្ហាប្រឈមខ្លះ ដូចជា ៖

- ការងារគ្រប់គ្រងមុខសញ្ញាពុំទាន់បានល្អ នៅមានចន្លោះប្រហោង
- សមាសភាពទាំងនេះនៅតែមានលទ្ធភាពអាចធ្វើសកម្មភាព បន្លំលួចម៉ូតូ និងគ្រឿងអលង្ការរបស់ប្រជាពលរដ្ឋ ក្នុងពេលកំពុងប្រារព្ធពិធីបុណ្យផ្សេងៗ ។
- ផ្តល់ប័ណ្ណក២ ក៤ ជូនប្រជាពលរដ្ឋពុំទាន់បានឆាប់រហ័ស
- ផ្តល់អត្តសញ្ញាណប័ណ្ណទុតិយតា ជូនប្រជាពលរដ្ឋពុំទាន់បានឆាប់រហ័ស
- ការគ្រប់គ្រងរដ្ឋបាលរបស់ប៉ុស្តិ៍ នៅចន្លោះប្រហោងមន្ត្រីមានចំនួនតិចវិសាលភាពឃុំធំ ។

## ៣.៣. យុទ្ធសាស្ត្រអភិវឌ្ឍរបស់ស្រុកកៀនស្វាយ

ប្រជាពលរដ្ឋក្នុងស្រុករស់នៅដោយភាពថ្លៃថ្នូរសមរម្យ ធានាបាននូវនិរន្តរភាពសន្តិសុខសុវត្ថិភាពទាំងផ្លូវកាយ ផ្លូវចិត្ត និងទទួលបាននូវសេវាកម្ម សុខុមាលភាពសង្គមដ៏ល្អប្រសើរ ព្រមជាមួយការធានាបាននូវនិរន្តរភាពបរិស្ថានល្អ ។

### ៣.៣.១.យុទ្ធសាស្ត្រអភិវឌ្ឍសេដ្ឋកិច្ច

ប្រជាពលរដ្ឋក្នុងស្រុកមានការហូបចុក ស្លៀកពាក់ ស្នាក់នៅមានមធ្យោបាយធ្វើដំណើរទៅមកសមរម្យ ។

- ➢ បង្កើនចំណូលសេដ្ឋកិច្ចគ្រួសារ
  - កែសម្រួលប្រពលវប្បកម្មដំណាំស្រូវគ្រប់ប្រភេទ
  - កែលម្អបច្ចេកទេសចិញ្ចឹមសត្វ វារីវប្បកម្ម
  - ធ្វើអោយមានឯកទេសកម្មដំណាំហូបផ្លែ

- ចំណូលពីការចិញ្ចឹមសត្វពាហនៈមធ្យមក្នុងមួយនាក់។

➢ បង្កើនផលិតកម្មសិប្បកម្ម និងសេវាកម្មគ្រប់ប្រភេទ

- ផ្តល់បច្ចេកទេស
- ប្រាក់ទុនភាពស្របច្បាប់ដល់បណ្តាសិប្បកម្ម សេវាកម្ម និងចែកចាយគ្រប់ប្រភេទ ។

➢ កែលម្អប្រព័ន្ធគមនាគមន៍ផ្លូវគោក

កែលម្អប្រព័ន្ធគមនាគមន៍ផ្លូវគោកតូច ធំក្នុងស្រុក បណ្តាញចែកចាយចរន្តអគ្គីសនីឲ្យបានដល់គ្រប់ខ្នងផ្ទះ ធានាបាននូវការផ្សាភ្ជាប់ទំនាក់ទំនងសេដ្ឋកិច្ចសង្គមកិច្ច សុវត្ថិភាពចរាចរណ៍ទំនិញបានល្អប្រសើរ ។

- ប្រើប្រាស់ទុនវិនិយោគស្រុក
- គៀគរប្រភពទុនផ្សេងៗក្នុងស្រុក និងក្រៅស្រុក
- កំណត់ទីតាំងសំខាន់ៗដែលត្រូវរៀបចំដាក់ ស្លាកសញ្ញាផ្សេងៗ។

➢ កែលម្អសេវាកម្មដឹកជញ្ជូនផ្លូវគោក

- គាំទ្រលើកទឹកចិត្តដល់មន្ទីរជំនាញ
- លើកទឹកចិត្ត និងគាំទ្រផ្តល់ភាពស្របច្បាប់ ។

➢ គ្រប់គ្រួសារ ឬខ្នងផ្ទះមានចរន្តអគ្គីសនីប្រើប្រាស់

- លើកទឹកចិត្ត និងគាំទ្រដល់ការពង្រឹងបណ្តាញចែកចាយចរន្តអគ្គីសនី
- លើកទឹកចិត្ត និងគាំទ្រផ្តល់ភាពស្របច្បាប់ ។

### ៣.៣.២.យុទ្ធសាស្ត្រអភិវឌ្ឍសង្គមកិច្ច

ប្រជាពលរដ្ឋក្នុងស្រុកទទួលបាននូវសេវាកម្មថែរក្សាសុខភាព ពិសេសការគាំពារមាតា និងទារកកាត់បន្ថយអត្រាការស្លាប់របស់ មាតា ទារកទាំងក្នុង និងក្រោយពេលសម្រាល ។

- ចាក់ថ្នាំបង្ការដល់មាតា និងទារក
- បំពាក់សម្ភារឧបករណ៍បរិក្ខាពេទ្យទាន់សម័យ
- ពង្រឹងសមត្ថភាពបច្ចេកទេសរបស់ពេទ្យឆ្មប
- អប់រំប្រជាពលរដ្ឋអោយប្រកាន់ទម្លាប់ផ្ញើពោះនឹងពេទ្យ។

➢ លើកកម្ពស់ការថែទាំសុខភាព អនាម័យរស់នៅរបស់ប្រជាពលរដ្ឋ

- អប់រំផ្សព្វផ្សាយអំពីជងឺឆ្លងនានា
- អប់រំផ្សព្វផ្សាយការរស់នៅតាមបែបអនាម័យ
- យុទ្ធនាការបាញ់ថ្នាំកំចាត់មូសខ្លា
- ចែកថ្នាំអាប៊ែតកំចាត់ដង្កូវទឹក

- អប់រំផ្សព្វផ្សាយអំពីផលប្រយោជន៍នៃការប្រើប្រាស់ទឹកដាំពុះ
- សហការជាមួយអង្គការជំនាញផ្នែកនេះក្នុងការជីកអណ្តូង ស្រះទឹក។

➢ ទប់ស្កាត់ និងថែរក្សាការពារដល់ជនដែលងាយរងគ្រោះ

- បង្កើតមូលនិធិគាំទ្រដល់ជនពិកា និងអានាថាតាមមូលដ្ឋានឃុំនីមួយៗ
- គៀរគរស្វែងរកការឧបត្ថមពីNGO ឬសប្បុរសជន
- សហការជាមួយអង្គការពាក់ព័ន្ធដើម្បីបណ្តុះបណ្តាលជំនាញសមស្រប។

➢ កុមារ យុវវ័យទទួលបាននូវការសិក្សា និងការបណ្តុះបណ្តាលនៅគ្រប់ភូមិសិក្សា

- បង្កើនអត្រាកុមារ៣-៥ឆ្នាំ ឲ្យបានចូលរៀនគ្រប់ៗគ្នា
- បង្កើនអត្រាកុមារពីអាយុ៦-១១ឆ្នាំ ឲ្យបានចូលរៀនគ្រប់ៗគ្នា
- បង្កើនអត្រាកុមារមានអាយុ ១២-១៤ ឆ្នាំ បានចូលរៀនក្នុងអនុវិទ្យាល័យអោយបានខ្ពស់។

### ៣.៣.៣.យុទ្ធសាស្ត្រអភិវឌ្ឍធនធានធម្មជាតិ បរិស្ថាន និងការបន្សុំនឹងការប្រែប្រួលអាកាសធាតុ

ការប្រើប្រាស់ដីធ្លី និងការគ្រប់គ្រងធនធានធម្មជាតិ បរិស្ថាន មានសង្គតិភាពជាមួយគោលនយោបាយរបស់រាជរដ្ឋាភិបាល ដើម្បីទប់ស្កាត់កាត់បន្ថយគ្រោះមហន្តរាយធម្មជាតិ និងការប្រែប្រួលអាកាសធាតុ ។ ការប្រើប្រាស់ដីធ្លីគ្រប់ប្រភេទត្រូវបានការពារដោយច្បាប់ទៅតាមប្រភេទដីនីមួយៗរួមមាន ដីសេដ្ឋកិច្ចគ្រួសារ ដីបម្រុងវិនិយោគ ដីរដ្ឋ ។

- ផ្សព្វផ្សាយណែនាំការចុះបញ្ជីដីធ្លី និងការធ្វើប័ណ្ណកម្មសិទ្ធដល់ប្រជាពលរដ្ឋ
- រៀបចំគំនូរប្លង់ជាប្រព័ន្ធរបស់ស្រុក។

➢ ការគ្រប់គ្រងធម្មជាតិនិងបរិស្ថាន

- ប្រជុំផ្សព្វផ្សាយអនុវត្តន៍ច្បាប់បរិស្ថាន និងផលប៉ះពាល់
- ប្រជុំផ្សព្វផ្សាយអនុវត្តន៍ច្បាប់ និងផលប្រយោជន៍ការប្រើប្រាប់ដីធម្មជាតិដោយធៀបនិងមជ្ឈដ្ឋានជាក់ស្តែង
- ផ្សព្វផ្សាយច្បាប់ស្តីពីការគ្រប់គ្រងបរិស្ថាន
- កាត់បន្ថយការប្រើប្រាស់ថ្នាំគីមី
- កាត់បន្ថយការប្រើប្រាស់ថ្នាំគីមី សត្វល្អិត និងស្មៅ
- បង្កើនភាគរយនៃចំនួនគ្រួសារមានបង្គន់អនាម័យប្រើប្រាស់
- បង្កើនភាគរយនៃចំនួនគ្រួសារមានទឹកស្អាតប្រើប្រាស់
- បង្កើនភាគរយនៃចំនួនគ្រួសារទម្លាប់ទទួលទានទឹកស្អាត។

### ៣.៣.៤.យុទ្ធសាស្ត្រអភិវឌ្ឍគ្រប់គ្រងរដ្ឋបាល និងសន្តិសុខសណ្តាប់ធ្នាប់សាធារណៈ

ធានាបានល្អនូវការចុះបញ្ជីអត្រានុកូលដ្ឋាន និងការរៀបចំបញ្ជីកម្មសិទ្ធដីធ្លី ។ ប្រជាពលរដ្ឋគ្រប់រូបនឹងទទួលបាននូវអត្រានុកូលដ្ឋាន៣ប្រភេទគឺ សំបុត្រកំណើត សំបុត្រអាពាហ៍ពិពាហ៍ និងសំបុត្រមរណភាព។

- ពង្រឹងសមត្ថភាព និងបណ្តុះបណ្តាលមន្ត្រីអត្រានុកូលដ្ឋានឃុំ- ស្រុក
- ស្គាល់ច្បាប់ និងឯកសារគ្រប់ទម្រង់
- ជម្រុញការចុះបញ្ជីសំបុត្រកំណើតរបស់កុមារក្រោយកើត៣០ថ្ងៃ
- ជម្រុញការចុះបញ្ជីកំណើតរបស់កុមារពីអាយុ ០-៥ឆ្នាំ
- ពង្រឹងសមត្ថភាពមន្ត្រីអត្រានុកូលដ្ឋាន
- ផ្តល់នូវឯកសារជាក់លាក់គ្រប់ទម្រង់
- ការបញ្ជាក់សំបុត្រកំណើត
- ការធ្វើនីត្យានុកូលកម្មលើឯកសារថតចម្លង
- ការចេញលិខិតគតិយុត្តនានា។

ប្រព័ន្ធនៃការចុះបញ្ជីដីធ្លី និងធ្វើប័ណ្ណកម្មសិទ្ធគ្រប់ប្រភេទដី ត្រូវបានធានាផ្តល់ជូនដោយតម្លាភាព គណនេយ្យភាព និងឆាប់រហ័ស ។

- ពន្លឿនការចេញប័ណ្ណកម្មសិទ្ធ
- សហការជាមួយរដ្ឋបាលមូលដ្ឋានឃុំ-ភូមិ ដើម្បីរៀបចំប្រព័ន្ធនេះ
- គ្រប់គ្រួសារមានប័ណ្ណកម្មសិទ្ធ
- ពង្រឹងប្រព័ន្ធនៃការចុះបញ្ជីដីធ្លី។

គ្រប់ប្រភេទ គ្រប់ទម្រង់នៃទំនាស់ទាំងអស់ ត្រូវបានដោះស្រាយជូនប្រជាពលរដ្ឋដោយតម្លាភាព គណនេយ្យភាព និងឆាប់រហ័ស ។

- បង្កើនប្រសិទ្ធភាព តម្លាភាព គណនេយ្យភាពរបស់ គណៈកម្មាធិការ ដោះស្រាយវិវាទដីធ្លីក្រៅប្រព័ន្ធតុលាការ
- ផលធៀបកំណើនទំនាស់ដីធ្លីក្នុង១០០០ គ្រួសារ
- ចំនួនករណីទំនាស់កម្រិតព្រហ្មទណ្ឌ
- ចំនួនករណីទំនាស់កម្រិតរដ្ឋប្បវេណី
- ចំនួនអ្នកស្លាប់ដោយគ្រោះថ្នាក់ចរាចរណ៍
- ចំនួនគ្រួសារមានអំពើហិង្សា
- ចំនួនករណីអំពើហិង្សាក្នុងគ្រួសារពាក់ព័ន្ធដល់អាជ្ញាធរ។

- កាត់បន្ថយអំពើអវិជ្ជមានក្នុងសង្គមអោយស្ថិតក្នុងកម្រិតអប្បបរិមា
  - រៀបចំអោយមានការសហការជាមួយប្រជាពលរដ្ឋនៅមូលដ្ឋានអាចផ្តល់ព័ត៌មាន និងចុះបង្ក្រាបទាន់ពេលវេលា
  - ជនរងគ្រោះដោយការចាប់រំលោភ
  - គ្រួសារមានសមាជិកប្រើប្រាស់គ្រឿងញៀន។

## ៣.៤. របបគំហើញ

បន្ទាប់ពីធ្វើការប្រៀបធៀបទ្រឹស្តីនិងការអនុវត្តរួចហើយ យើងនឹងធ្វើការវិភាគលើចំណុចខ្លាំង និងចំណុចខ្សោយនៃរដ្ឋបាលស្រុកកៀនស្វាយ ដើម្បីឲ្យការអនុវត្តការងារមានប្រសិទ្ធភាពដែលមានដូចខាងក្រោម៖

### ៣.៤.១. ចំណុចខ្លាំង

- មានរចនាសម្ព័ន្ធច្បាស់លាស់ ព្រមទាំងបែងចែកតួនាទី ភារកិច្ច និងអនុវត្តទៅ តួនាទីរៀងៗខ្លួន
- ទទួលខុសត្រូវក្នុងការអនុវត្តមុខងារ និងភារកិច្ចរបស់ខ្លួន
- កំណត់កាលវិភាគបំពេញការងារច្បាស់លាស់
- មានតម្លាភាព និងមានគណនេយ្យភាព
- ការងារមានសណ្តាប់ធ្នាប់ល្អ និងផ្តល់ព័ត៌មានបានច្បាស់លាស់តាមរយៈការដាក់ចេញនូវបទបញ្ជាផ្ទៃក្នុង
- ដាក់ចេញនូវផែនការអភិវឌ្ឍ និងអនុវត្តទៅតាមផែនការដែលបានដាក់ចេញសាលាស្រុកកៀនស្វាយមានក្រុមហ៊ុនឯកជនមួយចំនួនសម្រាប់ផ្តល់ការងារដល់ប្រជាពលរដ្ឋមានក្រុមហ៊ុនជីផ្កាយប្រាំពោងចក្រ
- គណៈអភិបាល ក្រុមប្រឹក្សា មានឆន្ទៈដ៏មុះមុតក្នុងការអភិវឌ្ឍផែនការ
- ការដោះស្រាយវិវាទតាមយន្តការរបស់ខ្លួនប្រកបដោយប្រសិទ្ធិភាព
- កាត់បន្ថយភាពក្រីក្រ។

### ៣.៤.២. ចំណុចខ្សោយ

ទោះបីជាការអនុវត្តតួនាទី ភារកិច្ច និងមានផែនការអភិវឌ្ឍច្បាស់លាស់យ៉ាងណាក៏ដោយ ក៏នៅមានចំណុចខ្វះខាតជៀសមិនរួចទោះតិចឬច្រើន។ ទន្ទឹមនឹងនេះរដ្ឋបាលស្រុកកៀនស្វាយបានប្រឈមទៅនឹងបញ្ហានានាដូចខាងក្រោម៖

- មន្ត្រីមួយចំនួនតូចខ្វះឆន្ទៈក្នុងការបំពេញការងារ
- ប្រព័ន្ធតាមដានត្រួតពិនិត្យ និងវាយតម្លៃមន្ត្រីពុំទាន់បានអនុវត្តបានល្អប្រសើរ

- ការចូលរួមក្នុងដំណើរការផ្សេងៗក្នុងស្រុករបស់ប្រជាពលរដ្ឋនៅមានកម្រិត ការប្រើប្រាស់គ្រឿងញៀន នៅតែបន្តកើតមាននៅក្នុងស្រុកកៀនស្វាយ
- ប្រជាពលរដ្ឋពុំសូវមានការចូលរួមសហការជាមួយអាជ្ញាធរក្នុងការផ្សព្វផ្សាយគោលនយោបាយ ផែនការអភិវឌ្ឍរបស់សាលាស្រុក
- ប្រជាពលរដ្ឋពុំសូវស្វែងយល់អំពីច្បាប់ទទួលព័ត៌មានឲ្យបានទូលំទូលាយ។

# សេចក្តីសន្និដ្ឋាន
# និងការផ្តល់អនុសាសន៍

# សេចក្តីសន្និដ្ឋាន និងការផ្តល់អនុសាសន៍

## ១.សេចក្តីសន្និដ្ឋាន

ក្រោយពីក្រុមយើងខ្ញុំបានធ្វើការសិក្សា និងការស្រាវជ្រាវទៅលើប្រធានបទ "ដំណើរការនៃការគ្រប់គ្រងរដ្ឋបាលស្រុកកៀនស្វាយ" តាមរយៈលិខិតបទដ្ឋានគតិយុត្តនានា ការចុះកម្មសិក្សានៅរដ្ឋបាលស្រុក ព្រមទាំងកិច្ចសម្ភាសន៍ជាមួយនឹងប្រធានការិយាល័យ នៅតាមមូលដ្ឋានកន្លងមក ក្រុមយើងខ្ញុំអាចធ្វើនូវសេចក្តីសន្និដ្ឋានបានថាតាមរយៈ កំណែទម្រង់រដ្ឋបាលស្តីពីវិមជ្ឈការ និងវិសហមជ្ឈការរបស់រាជរដ្ឋាភិបាលនេះ រដ្ឋបាលស្រុកកៀនស្វាយបានបំពេញកាតព្វកិច្ចរបស់ខ្លួនស្របទៅតាមការការកំណត់របស់ច្បាប់ និងលិខិតបទដ្ឋានគតិយុត្តនានាដែលបានផ្តល់តួនាទី និងភារកិច្ចដល់ខ្លួនសំដៅធ្វើឲ្យប្រសើរឡើងនូវជីវភាពប្រជាពលរដ្ឋ ការលើកកម្ពស់ប្រជាធិបតេយ្យនៅថ្នាក់ក្រោម និងការកាត់បន្ថយភាពក្រីក្រ កាត់បន្ថយអំពើហិង្សាក្នុងគ្រួសារ ក៏ប៉ុន្តែការអនុវត្តនៅផ្នែកខ្លះហាក់មានការខ្វះចន្លោះ ដែលតម្រូវឲ្យរដ្ឋបាលស្រុកគួរយកចិត្តទុកដាក់បន្ថែមទៀត ។

## ២.ការផ្តល់អនុសាសន៍

តាមរយៈសិក្សាស្រាវជ្រាវនិងចុះកម្មសិក្សាដែលក្រុមនិស្សិតយើងខ្ញុំបានចុះកម្មសិក្សា រដ្ឋបាលស្រុកកៀនស្វាយ គួរតែពង្រឹង និងបង្កើតនូវយន្តការបន្ថែមទៀតក្នុងគោលបំណងដើម្បីទប់ស្កាត់ទៅលើការប្រើប្រាស់និងជួញដូរគ្រឿងញៀន សណ្តាប់ធ្នាប់នៅតាមទីប្រជុំជននានា ការផ្សព្វផ្សាយព័ត៌មាន និងផែនការអភិវឌ្ឍមូលដ្ឋានឲ្យបានទូលំទូលាយ និងគួរតែពង្រឹងធនធានបុគ្គលិកតាមរយៈការបណ្តុះបណ្តាលបន្ថែម និងការប្រើប្រាស់ធនធានឲ្យចំគោលដៅ។ ម៉្យាងទៀតរដ្ឋបាលស្រុកគួរតែជម្រុញ និងលើកទឹកចិត្តឲ្យមានការចូលរួមសហការ របស់ប្រជាពលរដ្ឋតាមផែនការអភិវឌ្ឍនានា ដែលរដ្ឋបាលស្រុកខ្លួនឯងបានដាក់ចេញ។ ជាពិសេស ដើម្បីឲ្យការផ្តល់សេវារដ្ឋបាលនានា មានភាពងាយស្រួល រហ័សទាន់ចិត្ត អាចជឿទុកចិត្តបាន ដើម្បីផ្តល់សេវាកម្មជូនប្រជាពលរដ្ឋប្រកបដោយគុណភាព និងឆ្លើយតបតាមតម្រូវការមូលដ្ឋាន។

# ឯកសារយោង

# ឯកសារយោង

## ឯកសារជាភាសាខ្មែរ

ផែនការអភិវឌ្ឍន៍រយៈពេលប្រាំឆ្នាំ(២០២០-២០២៤)ស្រុកកៀនស្វាយខេត្តកណ្តាល

ការគ្រប់គ្រងរដ្ឋបាលស្រុកស្វាយឆ្នាំ(២០១៤-២០១៥)

សាលាជាតិរដ្ឋបាលមូលដ្ឋាន,ការគ្រប់គ្រងរដ្ឋបាលក្រុង,ឆ្នាំ២០២០

សៀវភៅប្រព័ន្ធគ្រប់គ្រងរដ្ឋបាល ឆ្នាំ២០១០-២០១១

សាលាជាតិរដ្ឋបាលមូលដ្ឋាន,ឆ្នាំ២០២២,ការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់

តាមអនុក្រឹត្យលេខ ១១៦ អនក្រ.បក ចុះថ្ងៃទី៦ ខែកញ្ញា ឆ្នាំ២០១៨ ស្តីពីការរៀបចំនិងការ ប្រព្រឹត្តទៅនៃទីស្តីការគណៈរដ្ឋមន្ត្រី

អនុវត្តតាមស្មារតីអនុក្រឹត្យ លេខ ១៨៤ អនក្រ.បក ចុះថ្ងៃចន្ទ ៦កើត ខែមិគសិរ ឆ្នាំកុរ ឯកស័ក ពស ២៥៦៣ ត្រូវនឹងថ្ងៃទី២ ខែធ្នូ ឆ្នាំ២០១៩ ស្តីពីមុខងារ និងរចនាសម្ព័ន្ធរដ្ឋបាលស្រុក

តាមមាត្រា១១៨ថ្មីមួយនៃរដ្ឋធម្មនុញ្ញ ចែងថា គណៈរដ្ឋមន្ត្រីជារាជរដ្ឋាភិបាលនៃ ព្រះរាជាណាចក្រកម្ពុជា

សេចក្តីសម្រេចស្តីពីការចែងចែក តួនាទី ភារកិច្ច និងរបៀបរបបធ្វើការងារ ជូនគណៈអភិបាលស្រុកកៀនស្វាយ

សេចក្តីសម្រេចស្តីពីការបែងចែកតួនាទី ភារកិច្ច និងរបៀបរបបធ្វើការងារ

កិច្ចប្រជុំពិគ្រោះយោបល់លើសេចក្តីផែនការអភិវឌ្ឍស្រុក រយៈពេល៥ឆ្នាំ (២០២០-២០២៤)

## ឯកសារស្រង់ពីគេហទំព័រ

https://elibrary.maff.gov.kh/assets/files/books/869f67423bc4ace84d3c6adb12e26fe41594868011.pdf

https://gdia.mef.gov.kh/wp-content/uploads/2017/01/.pdf

https://elibrary.maff.gov.kh/assets/files/books/adf4b8c615e7448b1bc1f49d31d2e3f21594868040.pdf

ក្រុង_សៀវភៅគ្រប់គ្រងរដ្ឋបាលក្រុង.pdf (ncdd.gov.kh)

https://pcasia.org/pic/wp-content/uploads/simple-file-list/20160825-Dispute-Resolution-Outside-the-Judicial-System-at-the-National-and-Sub-national-_KH_Final.pdf

https://km.wikipedia.org/wiki/%E1%9E%81%E1%9F%81%E1%9E%8F%E1%9F%92%E1%9E%8F%E1%9E%80%E1%9E%8E%E1%9F%92%E1%9E%8A%E1%9E%B6%E1%9E%9B

# ឧបសម្ព័ន្ធ

## ព្រះរាជាណាចក្រកម្ពុជា
## ជាតិ សាសនា ព្រះមហាក្សត្រ

## កំណត់ហេតុ

## កិច្ចប្រជុំវិសាមញ្ញលើកទី៣ អាណត្តិទី៣ របស់ក្រុមប្រឹក្សាស្រុកកៀនស្វាយ

ឆ្នាំពីរពាន់ម្ភៃ ខែកុម្ភៈ ថ្ងៃព្រហស្បតិ៍ ទីប្រាំមួយ វេលាម៉ោងប្រាំបីព្រឹក នៅសាលប្រជុំសាលាស្រុកកៀនស្វាយ មានបើកកិច្ចប្រជុំវិសាមញ្ញលើកទី៣ អាណត្តិទី៣ របស់ក្រុមប្រឹក្សាស្រុក ក្រោមអធិបតីភាព លោក ជា ប៊ុនធឿន ប្រធានក្រុមប្រឹក្សាស្រុក ។

### សមាសភាពអញ្ជើញចូលរួម

១- លោក លោកស្រី សមាជិកក្រុមប្រឹក្សាស្រុក ២១រូប លើ ២១រូប (បញ្ជីវត្តមាន)

២- លោក-លោកស្រីនាយក នាយករងរដ្ឋបាល

ជាកិច្ចចាប់ផ្តើមលោក ប្រធានអង្គប្រជុំបានប្រគល់នាទីជូនលោកស្រីនាយករដ្ឋបាល ជម្រាបជូននូវវត្តមានអង្គប្រជុំ ៖

សមាជិក ក្រុមប្រឹក្សាស្រុក បានអញ្ជើញចូលរួមចំនួន ២១ រូប លើ ២១ រូប ។

ជាកិច្ចបន្តលោកប្រធានអង្គប្រជុំបានប្រកាសថា ៖ កូរ៉ុមអង្គប្រជុំគ្រប់អាចដំណើរការកិច្ចប្រជុំវិសាមញ្ញលើកទី៣ អាណត្តិទី៣ នេះបាន បន្ទាប់មកលោកប្រធានបានជម្រាបជូនអំពីរបៀបវារៈអង្គប្រជុំដូចខាងក្រោម៖

១- ពិនិត្យ និងអនុម័តសេចក្តីព្រាងសេចក្តីសម្រេចស្តីពីការរៀបចំគោលការណ៍ផ្នែកគោលនយោបាយរបស់ក្រុមប្រឹក្សាស្រុកសម្រាប់ដំណើរការកសាងផែនការអភិវឌ្ឍរយៈពេល៥ឆ្នាំ(២០២០-២០២៤) និងកម្មវិធីវិនិយោគ បីឆ្នាំរំកិលស្រុក ។

២- បញ្ហាផ្សេងៗ

៣- មតិបូកសរុបរបស់លោកប្រធានអង្គប្រជុំ

ក្រោយពីបានពិនិត្យរួចមក អង្គប្រជុំបានអនុម័តមានសម្លេងគាំទ្រ២១រូប លើ២១រូប ។

<u>របៀបវារៈទី១</u> ៖ ពិនិត្យ និងអនុម័តសេចក្តីព្រាងសេចក្តីសម្រេចស្តីពីការរៀបចំគោលការណ៍ផ្នែកគោលនយោបាយរបស់ក្រុមប្រឹក្សាស្រុកសម្រាប់ដំណើរការកសាងផែនការអភិវឌ្ឍរយៈពេល៥ឆ្នាំ (២០២០-២០២៤) និងកម្មវិធីវិនិយោគ បីឆ្នាំរំកិលស្រុក ។

ជាកិច្ចចាប់ផ្តើមលោកប្រធានអង្គប្រជុំបានប្រគល់នាទីជូនលោកស្រីនាយករដ្ឋបាល អានសេចក្តីព្រាងសេចក្តីសម្រេចស្តីពីការរៀបចំគោលការណ៍ផ្នែកគោលនយោបាយរបស់ក្រុមប្រឹក្សាស្រុក សម្រាប់ដំណើរការកសាងផែនការអភិវឌ្ឍ រយៈពេល៥ឆ្នាំ(២០២០-២០២៤) និងកម្មវិធីវិនិយោគបីឆ្នាំរំកិលស្រុកទាំងស្រុងជូនអង្គប្រជុំដើម្បីពិនិត្យ និងអនុម័ត ។

មតិលោក ឯក សុផាត សមាជិកក្រុមប្រឹក្សាស្រុក ៖ ក្រោយពីបានពិនិត្យខ្លឹមសារសេចក្តីព្រាងសេចក្តីសម្រេច ពីដើមហូតចប់ ដែលក្នុងនោះមានផ្នែកយោង និងប្រការទាំង៨ ឃើញថាត្រឹមត្រូវខ្ញុំបាទសូមឯកភាព ។

មតិលោក ញ៉េប ប៊ុនតិច សមាជិកក្រុមប្រឹក្សាស្រុក ៖ ខ្ញុំបាទសូមឯកភាពតាមមតិលើកឡើងរបស់លោក ឯក សុផាត ទាំងស្រុង ព្រោះខ្លឹមសារសេចក្ដីព្រាងសេចក្ដីសម្រេចនេះមានលក្ខណៈគ្រប់ជ្រុងជ្រោយអាចដាក់ជូនទៅក្រុមការងារកសាងផែនការដំណើរការងារបាន រួមមានសៀវភៅណែនាំបច្ចេកទេសស្ដីពីការរៀបចំកសាងផែនការអភិវឌ្ឍរបស់ស្រុកដែលមាន៣ជំហាន ។

មតិលោក ហេង សំអុល សមាជិកក្រុមប្រឹក្សាស្រុក ៖ ខ្ញុំបាទសូមឯកភាពតាមមតិលើកឡើងរបស់លោក ឯក សុផាត និងលោក ញ៉េប ប៊ុនតិច ព្រោះខ្លឹមសារពិតជាគ្រប់គ្រាន់សម្រាប់ក្រុមការងារកសាងផែនការយកទៅអនុវត្ត ។

បន្ទាប់ពីពិភាក្សារួចមកសមាជិកក្រុមប្រឹក្សាបានអនុម័តមានសម្លេងគាំទ្រ២១ លើ២១ រូប ។

<u>របៀបវារៈទី២</u> ៖ បញ្ហាផ្សេងៗ

ពុំមានសមាជិកណាម្នាក់មានមតិទេ

<u>របៀបវារៈទី៣</u> ៖ មតិបូកសរុបរបស់លោកប្រធានអង្គប្រជុំ

សូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅចំពោះលោក លោកស្រីសមាជិកក្រុមប្រឹក្សាស្រុកទាំងអស់ដែលបានឆ្លៀត ឱកាសចូលរួមកិច្ចប្រជុំវិសាមញ្ញលើកទី៣នេះ ។ ក្រោយពីក្រុមប្រឹក្សាបានអនុម័តហើយ ក្រុមការងារកសាងផែនការអភិវឌ្ឍ និងយកទៅធ្វើជាត្រីវិស័យ គួបផ្សំជាមួយសៀវភៅណែនាំបច្ចេកទេស ដើម្បីសម្រេចអោយបាននូវសៀវភៅ ផែនការអភិវឌ្ឍន៍រយៈពេល៥ឆ្នាំ (២០២០-២០២៤) របស់ស្រុក ដែលជាឯកសារគតិយុត្តមិនអាចខ្វះបាន ។ មុននឹងបញ្ចប់ខ្ញុំសូមប្រសិទ្ធពរជ័យ សូមលោក-លោកស្រីទាំងអស់សមប្រកបនូវពុទ្ធពរទាំង៤ប្រការ គឺ អាយុ វណ្ណៈ សុខៈ ពលៈ កុំបីឃ្លៀងឃ្លាតឡើយ ។

អង្គប្រជុំបានដំណើរការតាមរបៀបវារៈ ដែលបានគ្រោងទុក និងបានបញ្ចប់នៅវេលាម៉ោងដប់ និងសាមសិបនាទី នាថ្ងៃ ខែ ឆ្នាំ ដដែលក្រោមបរិយាកាសស្និទ្ធស្នាល និងទទួលខុសត្រូវខ្ពស់ ។

លេខាកត់ត្រា

ចាម ចាសនា

ជ.ក្រុមប្រឹក្សាស្រុកកៀនស្វាយ

ប្រធានអង្គប្រជុំ

BUNTHOEUN

ដា.ប៊ុនធឿន

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**កំណត់ហេតុ**
**កិច្ចប្រជុំពិគ្រោះយោបល់លើសេចក្តីព្រាងបឋមផែនការអភិវឌ្ឍស្រុក**
**រយៈពេល៥ឆ្នាំ (២០២០-២០២៤)**

ឆ្នាំពីរពាន់ម្ភៃ ខែមេសា ថ្ងៃទីម្ភៃមួយ វេលាម៉ោងប្រាំបីព្រឹក នៅសាលប្រជុំសាលាស្រុកកៀនស្វាយមាន បើកកិច្ចប្រជុំពិគ្រោះយោបល់លើសេចក្តីព្រាងបឋមផែនការអភិវឌ្ឍ រយៈពេល៥ឆ្នាំ (២០២០-២០២៤)ជាមួយគណៈអភិបាល ក្រោមអធិបតីភាព លោក អ៊ូ ឈាង អភិបាល នៃគណៈអភិបាលស្រុកកៀនស្វាយ និងជាប្រធានក្រុមការងារកសាងផែនការអភិវឌ្ឍ និងកម្មវិធីវិនិយោគស្រុកកៀនស្វាយ ។

**សមាសភាពចូលរួម៖**

១. លោក លោកស្រីតំណាងក្រុមប្រឹក្សាស្រុក ០៣ រូប
២. លោក លោកស្រីអភិបាលរងស្រុក ០៤ រូប
៣. លោក លោកស្រីតំណាងក្រុមប្រឹក្សាឃុំ ០៨ រូប
៤. លោក លោកស្រី ក្រុមការងារកសាងផែនការថ្នាក់ស្រុក ២៥ រូប
៥. លោក លោកស្រីគណៈកម្មាធិការសម្របសម្រួលបច្ចេកទេស ០៥ រូប
សរុប ៤៥ រូប

របៀបវារៈអង្គប្រជុំ

១. មតិបើកអង្គប្រជុំដោយលោក អ៊ូ ឈាង អភិបាលស្រុក
២. បទបង្ហាញសេចក្តីព្រាងផែនការអភិវឌ្ឍរយៈពេល៥ឆ្នាំ
៣. មតិផ្តល់យោបល់របស់សមាជិកក្រុមការងារកសាងផែនការ
៤. មតិបូកសរុប របស់លោកប្រធានអង្គប្រជុំ

របៀបវារៈទី១ ៖ មតិបើកអង្គប្រជុំដោយលោក អ៊ូ ឈាង អភិបាលនៃគណៈអភិបាលស្រុក

សូមថ្លែងអំណាគុណយ៉ាងជ្រាលជ្រៅបំផុតចំពោះវត្តមានលោក លោកស្រីទាំងអស់នាឱកាសនេះ ពិសេស សូមកោតសរសើរដោយស្មោះ លោក លោកស្រីក្រុមការងារកសាងផែនការ ដែលបានខិតខំយកចិត្តទុកដាក់ អនុវត្តតាមប្រិទិនដែលបានរៀបចំកន្លងមកសម្រេចបានសេចក្តីព្រាងបឋម ដែលយកមកពិគ្រោះយោបល់ជា មួយគណៈអភិបាល ។ ដើម្បីកុំអោយអូសបន្លាយពេលយូសូមក្រុមការងារអនុវត្ត និតិវិធីតាមលំដាប់លំដោយ ។

របៀបវារៈទី២ ៖ ការធ្វើបទបង្ហាញសេចក្តីព្រាងបឋមផែនការអភិវឌ្ឍរយៈពេល៥ឆ្នាំ

លោក ពៅ គីមលី អភិបាលរងស្រុក និងជាអនុប្រធានក្រុមការងារកសាងផែនការស្រុក បានធ្វើបទបង្ហាញខ្លឹមសារតាមលំដាប់លំដោយនៃសេចក្តីព្រាងបឋមផែនការអភិវឌ្ឍស្រុក ជូនអង្គប្រជុំ ដែលចែកជា៤ជំពូក ៖

ជំពូកទី១ ៖ បង្ហាញពីស្ថានភាពទូទៅ និងបញ្ហាប្រឈម ផ្តោតសំខាន់ទៅលើវិស័យទាំង៤ គឺ

- វិស័យសេដ្ឋកិច្ច
- វិស័យសង្គមកិច្ច
- វិស័យធនធានធម្មជាតិ និងបរិស្ថានរស់នៅ
- វិស័យរដ្ឋបាល និងសន្តិសុខសណ្តាប់ធ្នាប់សាធារណៈ

ជំពូកទី២ ៖ ក្របខណ្ឌអភិវឌ្ឍរយៈពេល៥ឆ្នាំសម្រាប់អាណត្តិរបស់ក្រុមប្រឹក្សាស្រុក និងតារាងក្របខណ្ឌអភិវឌ្ឍ ។

ជំពូកទី៣ ៖ កម្មវិធីអភិវឌ្ឍរយៈពេល៥ឆ្នាំ ដោយផ្តោតសំខាន់ទៅលើ ៖

- ក្របខណ្ឌវិនិយោគ
- ក្របខណ្ឌផ្តល់សេវារដ្ឋបាល
- ការដាក់ចេញលិខិតបទដ្ឋានគតិយុត្តនានា
- ក្របខណ្ឌចំណាយរយៈពេលមធ្យម

ជំពូកទី៤ ៖ ក្របខណ្ឌតាមដាន និងវាយតម្លៃនៃការអនុវត្តផែនការអភិវឌ្ឍរួមមាន ៖

១- តារាងក្របខណ្ឌតាមដាន និងវាយតម្លៃការអនុវត្តក្របខណ្ឌផែនការអភិវឌ្ឍ

២- តារាងក្របខណ្ឌតាមដាន និងវាយតម្លៃការអនុវត្តក្របខណ្ឌវិនិយោគរយៈពេល៥ឆ្នាំ

៣-តារាងក្របខណ្ឌតាមដាន និងវាយតម្លៃការអនុវត្តក្របខណ្ឌផ្តល់សេវារដ្ឋបាល

របៀបវារៈទី៣ ៖ មតិផ្តល់យោបល់ និងកែលម្អរបស់គណៈអភិបាល

មតិលោក សុខ ពិសិទ្ធ អភិបាលរងស្រុក ៖ ក្រោយពីបានពិនិត្យលើសេចក្តីព្រាងបឋមផែនការអភិវឌ្ឍស្រុក រយៈពេល៥ឆ្នាំ ដែលបានបញ្ចប់ទាំងស្រុង ឃើញថាបានអនុវត្តទៅតាមច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ សៀវភៅណែនាំស្តីពីការរៀបចំនិងកសាងផែនការអភិវឌ្ឍស្រុក និងសូមអគុណ ចំពោះក្រុមការងារកសាងផែនការស្រុកទាំអស់ដែលបានខិតខំយកចិត្តទុកដាក់ និងមានស្មារតីទទួលខុសត្រូវ ខ្ពស់លើកិច្ចការនេះ។

របៀបវារៈទី៤ ៖ មតិបូកសរុបរបស់លោកប្រធានអង្គប្រជុំ

សូមថ្លែងអំណរគុណជាថ្មីម្តងទៀត ចំពោះក្រុមការងារទាំងអស់ដែលបានរៀបចំសេចក្តីព្រាង ផែនការអភិវឌ្ឍស្រុកនេះឡើង ស្របតាមការណែនាំរបស់រាជរដ្ឋាភិបាល និងដាក់ស្តែតាមតម្រូវការរបស់ប្រជាពលរដ្ឋ ប៉ុន្តែដើម្បី អោយសេចក្តីព្រាងផែនការនេះកាន់តែមានភាពសុក្រឹត្យថែមទៀតនោះ យើងនៅមានគណៈកម្មាធិ

ការសម្របសម្រួលបច្ចេកទេស ដែលត្រូវពិនិត្យ និងកែលម្រួលលើកិច្ចការនេះបន្ថែមទៀត ដូចនេះសូមលោកអនុប្រធានក្រុមការងាររៀបចំកិច្ចការនេះ និងស្នើសុំពិគ្រោះយោបល់ទៅគណៈកម្មាធិការសម្របសម្រួលបច្ចេកទេស ទៅតាមកាលបរិច្ឆេទដែលបានកំណត់ក្នុងប្រតិទិន ដាក់ជូនក្រុមប្រឹក្សាពិនិត្យ និងអនុម័តនៅក្នុងកិច្ចប្រជុំសាមញ្ញលើកទី១២ អាណត្តិទី៣ របស់ក្រុមប្រឹក្សាស្រុក នាថ្ងៃទី២១ ខែឧសភា ឆ្នាំ២០២០ ខាងមុខ ។

អង្គប្រជុំបានដំណើរការបញ្ចប់ទៅតាមរបៀបវារៈដែលគ្រោងទុកនៅវេលាម៉ោង ដប់ និងសាមសិបនាទីព្រឹក នាថ្ងៃ ខែ ឆ្នាំ ដដែល ក្រោមបរិយាកាស រីករាយ ស្និទ្ធស្នាល និងទទួលខុសត្រូវខ្ពស់ ។

| | |
|---|---|
| បានឃើញ និងឯកភាព | លេខាអង្គប្រជុំ |
| **ប្រធានអង្គប្រជុំ** | |
| **អ៊ុំ ឈឿន** | **ទិាម ទាសនា** |

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**កំណត់ហេតុ**

**កិច្ចប្រជុំពិនិត្យ និងផ្តល់យោបល់របស់គណៈកម្មាធិការសម្របសម្រួលបច្ចេកទេស លើសេចក្តីព្រាងបឋមផែនការអភិវឌ្ឍស្រុករយៈពេល៥ឆ្នាំ ( ២០២០-២០២៤ )**

ឆ្នាំពីរពាន់ម្ភៃ ខែមេសា ថ្ងៃទីម្ភៃប្រាំបួន វេលាម៉ោងប្រាំបីព្រឹក នៅសាលប្រជុំសាលាស្រុកកៀនស្វាយ មានរៀបចំកិច្ចប្រជុំពិគ្រោះគណៈកម្មាធិការសម្របសម្រួលបច្ចេកទេស របស់ក្រុមប្រឹក្សាស្រុក លើសេចក្តីព្រាងបឋមផែនការអភិវឌ្ឍស្រុក រយៈពេល៥ឆ្នាំ ក្រោមអធិបតីភាព លោក អ៊ូ ឈាង ប្រធានគណៈកម្មាធិការសម្របសម្រួលបច្ចេកទេសរបស់ក្រុមប្រឹក្សាស្រុក ។

**សមាសភាពចូលរួម៖**

- លោក លោកស្រី សមាជិកគណៈកម្មាធិការសម្របសម្រួលបច្ចេកទេសរបស់ក្រុមប្រឹក្សាស្រុក ចំនួន ៣៨ រូប ដូចមានក្នុងបញ្ជីវត្តមាន ។

របៀបវារៈអង្គប្រជុំ

១. មតិណែនាំរបស់លោកប្រធានគណៈកម្មធិការសម្របសម្រួលបច្ចេកទេស

២. ការបង្ហាញសេចក្តីព្រាងផែនការអភិវឌ្ឍ

៣. មតិផ្តល់យោបល់របស់សមាជិកអង្គប្រជុំ

៤. មតិបូកសរុប និងបិទអង្គប្រជុំ

របៀបវារៈទី១ ៖ មតិណែនាំរបស់លោកប្រធានគណៈកម្មធិការសម្របសម្រួលបច្ចេកទេស

ជាកិច្ចចាប់ផ្តើមលោកអភិបាលស្រុក និងជាប្រធានគណៈកម្មាធិការសម្របសម្រួលបច្ចេកទេសស្រុក បានជម្រាបជូនអង្គប្រជុំថា សេចក្តីព្រាងបឋមផែនការអភិវឌ្ឍរយៈពេល៥ឆ្នាំ របស់ស្រុក បានឆ្លងកាត់ការប្រជុំពិនិត្យ និងពិគ្រោះយោបល់ពីគ្រប់មជ្ឈដ្ឋានពាកព័ន្ធ និងគណៈអភិបាលស្រុក ហើយបានធ្វើការកែលម្អជាបន្តបន្ទាប់រួចហើយដែរ ។ ដើម្បីអោយសេចក្តីព្រាងផែនការនេះកាន់តែសុក្រឹតថែមទៀតមុននឹងដាក់ជូនក្រុមប្រឹក្សាពិនិត្យ និងអនុម័ត សូមអោយសមាជិកគណៈកម្មាធិការសម្រសម្រួលបច្ចេកទេសយកចិត្តទុកដាក់ចូលរួមផ្តល់យោបល់អោយបានទូលំទូលាយ ពិសេសបញ្ហាយុទ្ធសាស្ត្រសម្រាប់ការអភិវឌ្ឍស្រុកយើង ក្នុងគោលដៅកាត់បន្ថយភាពក្រីក្រអោយបានជាអតិបរិមា ។

របៀបវារៈទី២ ៖ ការបង្ហាញសេចក្តីព្រាងផែនការអភិវឌ្ឍ

លោក ពៅ គីមលី អនុប្រធានក្រុមការងារកសាងផែនការអភិវឌ្ឍស្រុក បានធ្វើបទបង្ហាញខ្លឹមសារសេចក្តីព្រាងបឋមផែនការអភិវឌ្ឍ តាំងពីទំព័រដើម រហូតដល់ទំព័រចុងក្រោយ ជូនសមាជិកគណៈកម្មាធិការសម្របសម្រួលបច្ចេកទេសបានជ្រាប ។

របៀបវារៈទី៣ ៖ មតិផ្តល់យោបល់របស់សមាជិកអង្គប្រជុំ

មតិលោកស្រី ពេជ ជារ៉ែ សមាជិកក្រុមប្រក្សាស្រុក និងជាសមាជិកគណៈកម្មាធិការពិគ្រោះ យោបល់កិច្ចការស្ត្រី និងកុមារស្រុក ស្នើសុំបញ្ចូលគម្រោងកិច្ចប្រជុំប្រចាំខែ ត្រីមាស ឆមាស និងការចុះតាមដាន ការងារសេវាសង្គមនៅតាមឃុំនានា ក្នុងស្រុកដែលជាកិច្ចការសំខាន់ ចាំបាច់ ដើម្បីជួយដល់ប្រជាពលរដ្ឋក្រីក្រ ជនពិការ ជនងាយរងគ្រោះ និងសកម្មភាពសេវាសង្គមផ្សេងៗទៀត ទៅក្នុងសេចក្តីព្រាងបឋមផែនការអភិវឌ្ឍស្រុកនេះ ។

មតិលោក ញ៉េប ប៊ុនតិច សមាជិកក្រុមប្រឹក្សាស្រុក និងជាសមាជិកគណៈកម្មាធិការសម្របសម្រួលបច្ចេកទេសស្រុក ៖ សេចក្តីព្រាងបឋមផែនការអភិវឌ្ឍដែលបានរៀបចំឡើងនេះ ស្របតាមគោលដៅអភិវឌ្ឍសហសវត្សកម្ពុជា មានសង្គតិភាពជាមួយលិខិតបទដ្ឋានគតិយុត្តទាំងអស់ ។ ក្នុងសេចក្តីព្រាងបឋមនេះគម្រោងទាំង៥១ តើការវាយតម្លៃប៉ាន់ស្មានគម្រោងនីមួយៗសមស្របដែរឺទេ? ហើយប្រសិនបើការវាយតម្លៃនេះ ខុសគ្នាខ្លាំងពេកអាចធ្វើឲ្យគម្រោងរបស់យើងយកទៅអនុវត្តពុំកើត ដូច្នេះសូមអោយជំនាញនីមួយៗ ពិនិត្យបន្ថែមទៀត អោយបានល្អិតល្អន់។

របៀបវារៈទី៤ ៖ មតិបូកសរុប និងបិទកម្មវិធី

ការផ្តល់យោបល់របស់លោក លោកស្រីទៅលើសេចក្តីព្រាងផែនការអភិវឌ្ឍស្រុកនេះ មានសារៈសំខាន់ណាស់សូមក្រុមការងារកសាងផែនការធ្វើការកែលម្អតាមការផ្តល់យោបល់របស់អង្គប្រជុំអោយបាន រួចរាល់ ដើម្បីដាក់ជូនក្រុមប្រឹក្សាអនុម័ត នាពេលខាងមុខតាមប្រតិទិនដែលបានកំណត់ ។

អង្គប្រជុំ បានដំណើរការទៅតាមកម្មវិធីដែលបានគ្រោងទុក និងចប់សព្វគ្រប់នៅវេលាម៉ោង ដប់មួយព្រឹក នាថ្ងៃ ខែ ឆ្នាំដដែល ក្រោមបរិយាកាស រីករាយ ស្និទ្ធស្នាល និងទទួលខុសត្រូវខ្ពស់បំផុត ។

បានឃើញ និងឯកភាព
ប្រធានអង្គប្រជុំ

អ៊ូ ឈាង

លេខាកត់ត្រា

ទ៉ាម ទាសនា

# ព្រះរាជាណាចក្រកម្ពុជា
## ជាតិ សាសនា ព្រះមហាក្សត្រ

## កំណត់ហេតុ

កិច្ចប្រជុំសាមញ្ញលើកទី១២ អាណត្តិទី៣ របស់ក្រុមប្រឹក្សាស្រុកកៀនស្វាយ

ឆ្នាំពីរពាន់ម្ភៃ ខែឧសភា ថ្ងៃព្រហស្បតិ៍ ទីម្ភៃមួយ វេលាម៉ោងប្រាំបីព្រឹក នៅសាលប្រជុំសាលាស្រុកកៀនស្វាយ មានបើកកិច្ចប្រជុំសាមញ្ញលើកទី១២ អាណត្តិទី៣ របស់ក្រុមប្រឹក្សាស្រុក ក្រោមអធិបតីភាពលោក ជា ប៊ុនធឿន ប្រធានក្រុមប្រឹក្សាស្រុក ។

## សមាសភាពអញ្ជើញចូលរួម

១- លោក លោកស្រី សមាជិកក្រុមប្រឹក្សាស្រុក ២១រូប លើ ២១រូប (បញ្ជីវត្តមាន)

២- លោក លោកស្រីក្នុងគណៈអភិបាលស្រុក ចំនួន ០៣រូប

អវត្តមាន ៖ កញ្ញា តាំង សេរីពេជ្ជរ៉ា អភិបាលរងស្រុក ៖ បំពេញការសិក្សានៅសាលាភូមិន្ទរដ្ឋបាល

លោក ឡូវ សុខសាន្ត អភិបាលរងស្រុក ៖ ជាប់ចូលរួមសម្ពោធអាគារមន្ទីរពាណិជ្ជកម្មខេត្ត

៣- លោកប្រធានការិយាល័យប្រជាពលរដ្ឋ

៤- លោក លោកស្រីនាយក នាយករងរដ្ឋបាល

៥- លោកលោកស្រីប្រធានការិយាល័យ អង្គភាព ចំណុះរដ្ឋបាលស្រុក ចំនួន ១៣ រូប

៦- លោកប្រធាន ឬតំណាងអង្គភាព ការិយាល័យជុំវិញស្រុក ចំនួន០៤រូប

ជាកិច្ចចាប់ផ្តើមលោក ជា ប៊ុនធឿន ប្រធានក្រុមប្រឹក្សាស្រុក បានប្រគល់នាទីជូនលោកស្រី នាយករដ្ឋបាល ជម្រាបជូននូវវត្តមានអង្គប្រជុំ ៖

សមាជិក ក្រុមប្រឹក្សាស្រុក បានអញ្ជើញចូលរួមចំនួន ២១ រូប លើ ២១ រូប ។

ជាកិច្ចបន្តលោកប្រធានអង្គប្រជុំបានប្រកាសថា ៖ ក្អូរមអង្គប្រជុំអាចដំណើរការកិច្ចប្រជុំសាមញ្ញ លើកទី១២ អាណត្តិ ទី៣ នេះបាន ។

បន្ទាប់មកលោកប្រធានអង្គប្រជុំបានជម្រាបនូវរបៀបវារៈកិច្ចប្រជុំសាមញ្ញលើកទី១២ អាណត្តិទី៣ជូនអង្គប្រជុំដើម្បីអនុម័តដូចខាងក្រោម៖

១-ពិនិត្យ និងអនុម័តសេចក្តីព្រាងកំណត់ហេតុកិច្ចប្រជុំសាមញ្ញលើក១១ អាណត្តិទី៣ របស់ក្រុមប្រឹក្សាស្រុក កាលពីថ្ងៃអង្គារ ទី២១ ខែមេសា ឆ្នាំ២០២០ ។

២-ពិនិត្យ និងអនុម័តសេចក្តីព្រាងរបាយការណ៍ ស្តីពីស្ថានភាពនៃការអនុវត្តការងាររបស់រដ្ឋបាលស្រុក ប្រចាំខែឧសភា ឆ្នាំ២០២០ ។

៣-ពិនិត្យ និងអនុម័តសេចក្តីព្រាងប្រតិទិនកិច្ចប្រជុំសាមញ្ញ របស់ក្រុមប្រឹក្សាស្រុករយៈពេល១២ខែ គិតចាប់ពីកិច្ចប្រជុំលើកទី១៣ ដល់កិច្ចប្រជុំលើកទី២៤

៤-បញ្ហាផ្សេងៗ

៥-ការកំណត់របៀបវារៈពេលវេលា និងទីកន្លែងកិច្ចប្រជុំលើកក្រោយ

៦-មតិបូកសរុប របស់លោកប្រធានអង្គប្រជុំ និងបិទកម្មវិធី

ក្រោយពីបានពិនិត្យ និងពិភាក្សារួចមក អង្គប្រជុំបានអនុម័តយល់ព្រមមានសម្លេងគាំទ្រ ២១ លើ ២១។

<u>របៀបវារៈទី១</u> ៖ ពិនិត្យ និងអនុម័តសេចក្តីព្រាងកំណត់ហេតុកិច្ចប្រជុំសាមញ្ញលើកទី១១ អាណត្តិទី៣ របស់ក្រុមប្រឹក្សាស្រុក កាលពីថ្ងៃអង្គារ ទី២១ ខែមេសា ឆ្នាំ២០២០ ។

ជាកិច្ចចាប់ផ្តើមលោកប្រធានអង្គប្រជុំបានប្រគល់នាទីជូន លោកស្រីនាយករដ្ឋបាលស្រុក អានសេចក្តីព្រាងកំណត់ហេតុកិច្ចប្រជុំសាមញ្ញលើកទី១១ របស់ក្រុមប្រឹក្សាស្រុកជូនអង្គប្រជុំ ។

មតិលោក ឯក សុផាត សមាជិកក្រុមប្រឹក្សាស្រុក ៖ លើសំណើសុំបញ្ចូលរបៀបវារៈរបស់គណៈអភិបាល ស្តីពីការពិនិត្យ និងអនុម័តសេចក្តីព្រាងផែនការអភិវឌ្ឍន៍រយៈពេល៥ ឆ្នាំ(២០២០-២០២៤ ) របស់រដ្ឋបាលស្រុកកៀនស្វាយ យើងឃើញថាកាលបរិច្ឆេទចុះថ្ងៃទី២០ ខែឧសភា ឆ្នាំ២០២០ គឺមុនកិច្ចប្រជុំរបស់យើង១ថ្ងៃតែប៉ុណ្ណោះ។ បើយោងទៅតាមបទ បញ្ជាផ្ទៃក្នុង របស់ក្រុមប្រឹក្សាស្រុករាល់សំណើ សុំបញ្ចូល របៀបវារៈត្រូវបញ្ជូនមកប្រធានក្រុមប្រឹក្សា ៣ថ្ងៃ មុនកិច្ចប្រជុំក្រុមប្រឹក្សាស្រុក ។

ក្រោយពីពិនិត្យ និងពិភាក្សារួចមក អង្គប្រជុំបានអនុម័តយល់ព្រមមានសម្លេងគាំទ្រ២១ លើ២១ ។

<u>របៀបវារៈទី២</u> ៖ ពិនិត្យ និងអនុម័តសេចក្តីព្រាងរបាយការណ៍ ស្តីពីស្ថានភាពនៃការអនុវត្តការងាររបស់រដ្ឋបាលបាលស្រុកប្រចាំខែឧសភា ឆ្នាំ២០២០ ។

មតិលោក ញ៉េប ប៊ុនតិច សមាជិកក្រុមប្រឹក្សាស្រុក ៖ នៅទំព័រទី៨ ចំណុចទី១ តារាងទី៦ សូមរដ្ឋបាលថែមកិច្ចប្រជុំសៃមញ្ញក្រុមប្រឹក្សាលើកទី១ គឺនៅខែមករា ឆ្នាំ២០២០ ដូច្នេះដើមគ្រា សូមដាក់០១ បូកយោង សូមដាក់០១ ។ ដោយឡែកនៅលេខរៀងទី៤ កិច្ចប្រជុំគណៈកម្មាធិការសម្របសម្រួលបច្ចេកទេស សូមដាក់ ០១ បូកយោង០១ ។

-ការងារសមគមមនុស្សចាស់ នៅឃុំសំរោងធំ តាមគោលការណ៍សព០១ ត្រូវឧបត្ថម្ភ១លានរៀល ប៉ុន្តែថវិកាតម្កល់មានតែ ៨០០,០០០រៀល (ប៉ែតសិបម៉ឺនរៀល ) និងឃុំបន្ទាយដែកមិនបានដាក់ថវិកាតម្កល់ ទេ ។ កាលពីកិច្ចប្រជុំលើកមុនខ្ញុំបានលើករួចមក តែមកទល់ខែនេះឃើញថាទិន្នន័យនៅដដែល ដូច្នេះសូមរដ្ឋបាលឃុំជួយបន្ថែមផង ។

មតិលោក សួន ស៊ីថុល សមាជិកក្រុមប្រឹក្សាស្រុក ៖ នៅត្រង់ទំព័រទី២ ការងារបញ្ជព័ត៌មាន ខ្ញុំបានលើកឡើងកាលពីកិច្ចប្រជុំខែមុន តែមកដល់របាយការណ៍ខែនេះ គឺឃើញថាដាក់សូន្យដដែល ។ ដូច្នេះសូមរដ្ឋបាលជួយពិនិត្យលើរបាយការណ៍នេះផង ។

-មតិលោក អ៊ួ ឈាង អភិបាលស្រុក ៖ ក្រុមប្រឹក្សាស្រុកមានសកម្មភាពច្រើន សមាជិកនីមួយៗបានចុះជាប់ជាមួយគណៈអភិបាល ដើម្បីចុះតាមដានត្រួតពិនិត្យ ពិសេសការងារប្រយុទ្ធប្រឆាំងជំងឺ Covid-19 ដូច្នេះសូមនាយករដ្ឋបាលយកសកម្មភាពរបស់ពួកគាត់មកដាក់បញ្ចូល បន្ទាប់មកទើបដាក់សកម្មភាពរបស់ គណៈអភិបាលតាមក្រោយ ។ ដោយឡែកការងារដោះស្រាយទំនាស់ដីធ្លី ជារៀងរាល់ខែគឺយើងបានដោះស្រាយច្រើនខ្លាំងណាស់ តែក្នុងរបាយការណ៍ពុំឃើញមាន សូមរដ្ឋបាលពិនិត្យឡើងវិញ ។

ក្រោយពីបានពិនិត្យ និងពិភាក្សារួចមកអង្គប្រជុំបានអនុម័តយល់ព្រមមានសម្លេងគាំទ្រ២១ លើ ២១ ។

របៀបវារៈទី៣ ៖ ពិនិត្យ និងអនុម័តសេចក្តីព្រាងប្រតិទិនកិច្ចប្រជុំសាមញ្ញ របស់ក្រុមប្រឹក្សាស្រុករយៈពេល១២ខែ គិតចាប់ពីកិច្ចប្រជុំលើកទី១៣ ដល់កិច្ចប្រជុំលើកទី២៤ ។

លោកប្រធានក្រុមប្រឹក្សាស្រុកបានប្រគល់នាទីនេះជូន លោក ញ៉េប ប៊ុនតិច សមាជិកក្រុមប្រឹក្សាស្រុកអាន សេចក្តីព្រាងប្រតិទិនកិច្ចប្រជុំសាមញ្ញ របស់ក្រុមប្រឹក្សាស្រុករយៈពេល ១២ខែ គិតចាប់ពីកិច្ចប្រជុំលើកទី១៣ ដល់កិច្ចប្រជុំលើកទី២៤ ។

មតិលោក សុខ ពិសិទ្ធ អភិបាលរងស្រុក ៖ នៅក្នុងដីកាបទបញ្ជាផ្ទៃក្នុងរបស់ក្រុមប្រឹក្សា កិច្ចប្រជុំរបស់ក្រុមប្រឹក្សាមិនអោយលើស ៣៥ ថ្ងៃ ។ ប៉ុន្តែខែក្រោយ ត្រូវនឹងកិច្ចប្រជុំលើកទី១៣ ធ្វើឡើងនៅថ្ងៃទី១៩ មិថុនា ឆ្នាំ២០២០ យើងឃើញថា មានរយៈពេលខ្លីជាងកិច្ចប្រជុំកល់ដង ហើយស្របពេលនឹងការបូកសរុប របាយការណ៍ឆមាសទី១ ស្តីពីស្ថានភាពការអនុវត្តរដ្ឋបាល ដែលមានលក្ខណៈច្រើនក្នុងការបូកសរុប ។ ជាសំណូមពរ គឺសូមអោយដាក់នៅក្រោយថ្ងៃទី២០ ។

មតិលោក ញ៉េប ប៊ុនតិច សមាជិកក្រុមប្រឹក្សាស្រុក ៖ ដូចខ្ញុំបានជម្រាបជូនរួចមកហើយ បើយើងកែសម្រួលពេល កិច្ចប្រជុំលើកទី១៣ គឺវាធ្វើខុសដល់តួលេខដែលយើងគណនាថ្ងៃខែកិច្ចប្រជុំលើកក្រោយ បន្តបន្ទាប់ខាងក្រោមទៀត ដូចច្នេះជាយោបល់ខ្ញុំយើងមិនចាំបាច់កែប្រតិទិនទេ។ គ្រាន់តែកិច្ចប្រជុំនៅខែក្រោយ គណៈអភិបាល លោកអាចសុំពេលវេលាកិច្ចប្រជុំពីលោកប្រធានក្រុមប្រឹក្សា ដើម្បីធ្វើការបូកសរុប របាយការណ៍អោយបានទាន់ ពេលហើយ ដាក់កាលបរិច្ឆេទក្នុងឯកសារ ឬ របាយការណ៍ អោយត្រឹមត្រូវតាមប្រតិទិនកំណត់ ។

ក្រោយពីបានពិនិត្យ និងពិភាក្សារួចមកអង្គប្រជុំបានអនុម័តយល់ព្រមមានសម្លេងគាំទ្រ២១រូបលើ ២១រូប ។

របៀបវារៈទី៤ ៖ ពិនិត្យ និងអនុម័ត សេចក្តីព្រាងសៀវភៅផែនការអភិវឌ្ឍន៍រយៈពេល ៥ឆ្នាំ(២០២០-២០២៤)

លោកប្រធានក្រុមប្រឹក្សាស្រុក បានប្រគល់នាទីជូនលោក ពៅ គីមលី អភិបាលរងស្រុក អានបទបង្ហាញសង្ខេបស្តីពីផែនការអភិវឌ្ឍរយៈពេល៥ ឆ្នាំ ។

ក្រោយពីបានពិនិត្យ និងពិភាក្សារួចមកអង្គប្រជុំបានអនុម័តយល់ព្រមមានសម្លេងគាំទ្រ២១លើ ២១។

របៀបវារៈទី៥ ៖បញ្ហាផ្សេងៗ

មតិលោក ហេង សំអុល សមាជិកក្រុមប្រឹក្សាស្រុក ៖ កាលពីម្សិលមិញ ខ្ញុំបានចូលរួមកិច្ចប្រជុំនៅឃុំសំរោងធំ សង្កេតឃើញថាផ្លូវភូមិសំរោងក្អែរ៣ ដែលប្រើប្រាស់ថវិកាគុណប្រយោជន៍ខេត្ត ឆ្នាំ២០១៩ មានការខូចខាតបើក ហុយជាបណ្តើរៗ ។

មតិលោក ប៊ិច អាយ អនុប្រធានការិយាល័យអប់រំស្រុក ៖ សូមរាយការណ៍ស្តីពីស្ថានភាពការសិក្សា ពីចម្ងាយរបស់ សិស្សានុសិស្សតាមរយៈប្រព័ន្ធអនឡាញ (Online) ទូរទស្សន៍ទទក ។ ដូច្នេះខ្ញុំសំណូមពរអោយ អាជ្ញាធរ ភូមិឃុំ ចូលរួមចុះពិនិត្យតាមខ្នងផ្ទះដើម្បីគ្រប់គ្រងការសិក្សារៀនសូត្រ របស់សិស្សក្នុងអំឡុងពេលជំងឺ Covid-19 ។

របៀបវារៈទី៦ ៖ ការកំណត់របៀបវារៈពេលវេលា និងទីកន្លែងកិច្ចប្រជុំលើកក្រោយ

កិច្ចប្រជុំសាមញ្ញលើកទី១៣ អាណត្តិទី៣ របស់ក្រុមប្រឹក្សាស្រុកនឹងប្រព្រឹត្តទៅនៅថ្ងៃសុក្រ ទី១៩ ខែមិថុនា ឆ្នាំ២០២០ តាមរបៀបវារៈដូចខាងក្រោម ៖

១-ពិនិត្យ និងអនុម័តសេចក្តីព្រាងកំណត់ហេតុកិច្ចប្រជុំសាមញ្ញលើក១២ អាណត្តិទី៣ របស់ក្រុមប្រឹក្សាស្រុក កាលពីថ្ងៃព្រហស្បតិ៍ ទី២១ ខែឧសភា ឆ្នាំ២០២០ ។

២-ពិនិត្យ និងអនុម័តសេចក្តីព្រាងរបាយការណ៍ ស្តីពីស្ថានភាពនៃការអនុវត្តការងាររបស់រដ្ឋបាលស្រុក ប្រចាំឆមាសទី១ ឆ្នាំ២០២០ ។

៣-បញ្ហាផ្សេងៗ

៤-ការកំណត់របៀបវារៈពេលវេលា និងទីកន្លែងកិច្ចប្រជុំលើកក្រោយ

៥-មតិបូកសរុប របស់លោកប្រធានអង្គប្រជុំ និងបិទកម្មវិធី

<u>របៀបវារៈទី៥</u>៖ មតិបូកសរុប និងបិទអង្គប្រជុំ

មតិលោក អ៊ូ ឈាង អភិបាលស្រុក ៖ សូមបកស្រាយចំនុចផ្លូវបេតុង ស្ថិតនៅភូមិសំរោងក្អែរ៣ កសាងឆ្នាំ២០១៩ ដោយថវិកាគុណប្រយោជន៍ខេត្ត សូមអោយការិយាល័យពាក់ព័ន្ធចុះ ត្រួតពិនិត្យព្រោះមានការខូច ខាត ។

-ការងារអប់រំ គឺជាតួនាទីរបស់ការិយាល័យអប់រំ ដូច្នេះសូមអោយសហការជាមួយមូលដ្ឋាន ចុះធ្វើការណែនាំព្រោះជាជំនាញរបស់ការិយាល័យ ។

-ការប្រជុំបូកសរុបលទ្ធផលការងារប្រយុទ្ធប្រឆាំងជំងឺCovid-19 ជាលទ្ធផលដែលក្រុមការងារខិតខំប្រឹងប្រែង យើងទទួលបានការកោតសរសើរពីថ្នាក់ដឹកនាំ ។

-ការងារសមាគមមនុស្សចាស់ ប្រសិនបើការងារនេះកើតហើយ ប៉ុន្តែបាត់ទៅវិញ គឺមកពីអ្នកអនុវត្តខ្សោយ ដូច្នេះសូមអោយ នាយករដ្ឋបាលបន្តយកចិត្តទុកដាក់លើកិច្ចការងារនេះ រង់ចាំអភិបាលរងទទួលបន្ទុកបញ្ចប់ការសិក្សា ។

-ការងារសណ្តាប់ធ្នាប់តាមដងផ្លូវ គឺប្រគល់នាទីនេះជូន លោក សុខ ពិសិទ្ធ ចុះត្រួតពិនិត្យ ចាប់រាល់រថយន្តដឹកដី ដែលមិនបានគ្រប់គម្រប ធ្វើអោយជ្រុះរាយប៉ាយ និងហុយ តាមផ្លូវ ។ ត្រូវចុះឃាត់ការដឹក និងឃាត់យករថយន្តមករក្សាទុកនៅសាលាស្រុករង់ចាំការណែនាំ ។ ម្យ៉ាងទៀតត្រូវចុះត្រួតពិនិត្យ តាមដេប៉ូសំណង់ គឺតម្រូវអោយ មានកន្លែងលាងកង់រថយន្តដឹកដី ទើបអាចអនុញ្ញាតបើកអាជីវកម្មបន្ត ។

-ការងារកសាងផែនការអភិវឌ្ឍន៍៥ឆ្នាំ សូមលោកប្រធានក្រុមការងារកសាងផែនការពន្លឿនការងារនេះ អោយបានត្រឹមត្រូវ ដើម្បីដាក់ស្នើសុំអនុលោមភាពពីឯកឧត្តមអភិបាលខេត្ត ។

មតិលោកប្រធានអង្គប្រជុំ ៖ ក្នុងនាមក្រុមប្រឹក្សាស្រុកក៏សូមកោតសរសើរដល់អស់លោកលោកស្រីក្រុមការងារទាំងអស់ ជាពិសេសគណៈអភិបាលស្រុកដែលបានធ្វើកិច្ចការងារនេះយ៉ាងយកចិត្តទុកដាក់ ក្នុងការប្រយុទ្ធប្រឆាំងនឹងជំងឺ Covid-19 ជាមួយរាជរដ្ឋាភិបាល ។ ចំពោះស្រុកកៀនស្វាយយើងទទួលបានការកោតសរសើរពីថ្នាក់ដឹកនាំ ។ ដូចនេះ សូមអោយយើងយកចិត្តទុកដាក់បន្តទៀត ដើម្បីការពារការរីករាលដាលលេកទី២ ។ មួយវិញទៀតសូមអរគុណដល់ក្រុមការងារកសាងផែនការអភិវឌ្ឍន៍៥ឆ្នាំ ដែលបានខិតខំរៀបចំស្រាវជ្រាវចងក្រងជាសៀវភៅផែនការ ដើម្បីរង់ចាំការអនុលោមភាពពីឯកឧត្តមអភិបាលខេត្ត ។

ជាទីបញ្ចប់ខ្ញុំសូមថ្លែងអំណរគុណ និង គោរពជូនពរ អស់លោក លោកស្រីទាំងអស់ សូមសមប្រកប នូវ ពុទ្ធពរទាំង៤ប្រការ គឺ អាយុ វណ្ណៈ សុខៈ ពលៈ កុំបីឃ្លៀងឃ្លាតឡើយ ។

អង្គប្រជុំបានដំណើរការតាមរបៀបវារៈ ដែលបានគ្រោងទុក និងបានបញ្ចប់នៅវេលាម៉ោងដប់មួយ និងសាមសិប នាទី នាថ្ងៃ ខែ ឆ្នាំ ដដែលក្រោមបរិយាកាសស្និទ្ធស្នាល និងទទួលខុសត្រូវខ្ពស់ ។

លេខាកត់ត្រា

ថ៊ាម ចាសណា

ជ.ក្រុមប្រឹក្សាស្រុកកៀនស្វាយ

ប្រធានអង្គប្រជុំ

ជា_ប៊ុនធឿន



ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា
លេខ: ១៨៧ អនក្រ.បក

# អនុក្រឹត្យ
## ស្ដីពី
## មុខងារ និងរចនាសម្ព័ន្ធរដ្ឋបាលក្រុង

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៨/៩២៥ ចុះថ្ងៃទី០៦ ខែកញ្ញា ឆ្នាំ២០១៨ ស្ដីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីការបង្កើតក្រសួងមហាផ្ទៃ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៧ ចុះថ្ងៃទី២៨ ខែឧសភា ឆ្នាំ២០០៨ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១២០៨/១៤២៩ ចុះថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០០៨ ស្ដីពីការបង្កើតគណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ
- បានឃើញអនុក្រឹត្យលេខ២១៦ អនក្រ.បក ចុះថ្ងៃទី១៤ ខែធ្នូ ឆ្នាំ២០០៩ ស្ដីពីតួនាទី ភារកិច្ច និងទំនាក់ទំនងការងាររបស់ក្រុមប្រឹក្សា គណៈអភិបាលខេត្ត ក្រុមប្រឹក្សា គណៈអភិបាលក្រុង និងក្រុមប្រឹក្សា គណៈអភិបាលស្រុក
- បានឃើញអនុក្រឹត្យលេខ១០៩ អនក្រ.បក ចុះថ្ងៃទី១៩ ខែសីហា ឆ្នាំ២០១៥ ស្ដីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងមហាផ្ទៃ
- បានឃើញអនុក្រឹត្យលេខ១១៤ អនក្រ.បក ចុះថ្ងៃទី០៧ ខែកញ្ញា ឆ្នាំ២០១៥ ស្ដីពីការកំណត់រចនាសម្ព័ន្ធគ្រប់គ្រង និងមុខតំណែងក្នុងរចនាសម្ព័ន្ធគ្រប់គ្រងនៃក្រសួង ស្ថាប័នថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ

- បានឃើញអនុក្រឹត្យលេខ១៩១ អនក្រ.បក ចុះថ្ងៃទី១៤ ខែកញ្ញា ឆ្នាំ២០១៦ ស្ដីពីការប្រគល់មុខងារនានាពាក់ព័ន្ធនឹងការគ្រប់គ្រងការអប់រំកុមារតូច ការអប់រំបឋមសិក្សា និងការអប់រំក្រៅប្រព័ន្ធឱ្យទៅដល់រដ្ឋបាលក្រុង ស្រុក
- បានឃើញអនុក្រឹត្យលេខ១៨ អនក្រ.បក ចុះថ្ងៃទី០៨ ខែកុម្ភៈ ឆ្នាំ២០១៧ ស្ដីពីការបង្កើតយន្តការច្រកចេញចូលតែមួយសម្រាប់ការផ្ដល់សេវារដ្ឋបាលនៅរដ្ឋបាលថ្នាក់ក្រោមជាតិ
- បានឃើញអនុក្រឹត្យលេខ១៩ អនក្រ.បក ចុះថ្ងៃទី០៨ ខែកុម្ភៈ ឆ្នាំ២០១៧ ស្ដីពីការបង្កើតការិយាល័យប្រជាពលរដ្ឋនៅរដ្ឋបាលថ្នាក់ក្រោមជាតិ
- យោងតាមសំណើរបស់គណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ (គ.ជ.អ.ប)

# សម្រេច

## ជំពូកទី១

## បទប្បញ្ញត្តិទូទៅ

**មាត្រា ១.-**

អនុក្រឹត្យនេះមានគោលបំណងលើកកម្ពស់ប្រសិទ្ធភាពក្នុងការគ្រប់គ្រងរដ្ឋបាល ការផ្ដល់សេវាសាធារណៈ និងការអភិវឌ្ឍមូលដ្ឋាននៅថ្នាក់ក្រុង។

**មាត្រា ២.-**

អនុក្រឹត្យនេះមានគោលដៅកំណត់អំពីមុខងារ រចនាសម្ព័ន្ធ តួនាទី ភារកិច្ច ទំនាក់ទំនងការងារ និងគណនេយ្យភាពរបស់រដ្ឋបាលក្រុង។

**មាត្រា ៣.-**

អនុក្រឹត្យនេះមានវិសាលភាពអនុវត្តចំពោះរដ្ឋបាលក្រុងទូទាំងព្រះរាជាណាចក្រកម្ពុជា។

## ជំពូកទី២

## មុខងាររបស់រដ្ឋបាលក្រុង

**មាត្រា ៤.-**

រដ្ឋបាលក្រុងត្រូវបំពេញមុខងារតាមការកំណត់នៃច្បាប់ស្ដីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ និងមុខងារដែលបានផ្ទេរពីរាជរដ្ឋាភិបាល ក្រសួង ស្ថាប័ន និងអាជ្ញាធរគ្រប់លំដាប់ថ្នាក់។

មុខងារពាក់ព័ន្ធនឹងការផ្ដល់សេវាសាធារណៈ និងការអភិវឌ្ឍមូលដ្ឋានក្នុងវិស័យនីមួយៗត្រូវបានប្រគល់ និងប្រតិភូកម្មទៅឱ្យរដ្ឋបាលក្រុងដូចមានកំណត់ក្នុងឧបសម្ព័ន្ធទី១នៃអនុក្រឹត្យនេះ លើកលែងតែមុខងារក្នុងវិស័យអប់រំ យុវជន និងកីឡារបស់រដ្ឋបាលក្រុងនៃខេត្តបាត់ដំបងមានចែងក្នុងជំពូកទី៧នៃអនុក្រឹត្យនេះ។

**មាត្រា ៨.-**

ក្រសួងមហាផ្ទៃមានតួនាទី ភារកិច្ចដឹកនាំ ណែនាំ តម្រង់ទិស សម្របសម្រួល គាំទ្រ តាមដាន ត្រួតពិនិត្យ និងវាយតម្លៃរដ្ឋបាលក្រុង ដើម្បីធានាឱ្យរដ្ឋបាលក្រុងគ្រប់គ្រង ចាត់ចែង និងអនុវត្តមុខងាររបស់ខ្លួនបានត្រឹមត្រូវស្របតាមច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ លិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធនានា និងអនុក្រឹត្យនេះ។

## ជំពូកទី៣

## ការបង្កើត តួនាទី ភារកិច្ច និងរបៀបរបបការងារនៃការិយាល័យ និងអង្គភាពនានាចំណុះរដ្ឋបាលក្រុង

### ផ្នែកទី១

### ការបង្កើតការិយាល័យ និងអង្គភាពនានាចំណុះរដ្ឋបាលក្រុង

**មាត្រា ៩.-**

រដ្ឋបាលក្រុងនីមួយៗត្រូវមានការិយាល័យ និងអង្គភាពមួយចំនួនជាចំណុះដូចខាងក្រោម៖

- ការិយាល័យរដ្ឋបាល និងហិរញ្ញវត្ថុ
- អង្គភាពលទ្ធកម្ម
- ការិយាល័យគ្រប់គ្រងធនធានមនុស្ស
- ការិយាល័យផែនការ និងគាំទ្រសង្កាត់
- ការិយាល័យត្រួតពិនិត្យផ្ទៃក្នុង
- ការិយាល័យលេខាធិការក្រុមប្រឹក្សា
- ការិយាល័យអប់រំ យុវជន និងកីឡា
- ការិយាល័យរៀបចំដែនដី នគរូបនីយកម្ម សំណង់ និងភូមិបាល
- ការិយាល័យនីតិកម្ម និងសម្រុះសម្រួលវិវាទមូលដ្ឋាន
- ការិយាល័យសាធារណការ ដឹកជញ្ជូន អនាម័យ បរិស្ថាន និងសណ្តាប់ធ្នាប់សាធារណៈ
- ការិយាល័យសេដ្ឋកិច្ច និងអភិវឌ្ឍន៍សហគមន៍
- ការិយាល័យសង្គមកិច្ច និងសុខុមាលភាពសង្គម
- ការិយាល័យច្រកចេញចូលតែមួយ។

**មាត្រា ១០.-**

អង្គការលេខរបស់រដ្ឋបាលក្រុងមានកំណត់នៅក្នុងឧបសម្ព័ន្ធទី២នៃអនុក្រឹត្យនេះ។

**មាត្រា ១១.-**

ការិយាល័យ និងអង្គភាពនីមួយៗចំណុះរដ្ឋបាលក្រុងត្រូវដឹកនាំដោយប្រធានមួយ(០១)រូប និងមានអនុប្រធានយ៉ាងច្រើនចំនួនពីរ(០២)រូបជាជំនួយការ។

ការតែងតាំងប្រធាន និងអនុប្រធានការិយាល័យ និងអង្គភាពនានាចំណុះរដ្ឋបាលក្រុងត្រូវអនុវត្ត

## ផ្នែកទី២

## តួនាទី ភារកិច្ចរបស់ការិយាល័យ និងអង្គភាពនានាចំណុះរដ្ឋបាលក្រុង

**មាត្រា ១៥.-**

**ការិយាល័យរដ្ឋបាល និងហិរញ្ញវត្ថុ**ត្រូវបំពេញតួនាទីជាសេនាធិការឱ្យរដ្ឋបាលក្រុងលើការងាររដ្ឋបាល និងហិរញ្ញវត្ថុ និងមានភារកិច្ចចាត់ចែងលើការងារដូចខាងក្រោម៖

- ការងាររដ្ឋបាល លិខិតស្នាមផ្សេងៗ ព័ត៌មាន ពិធីការ ទំនាក់ទំនងសាធារណៈ និងសហប្រតិបត្តិការអន្តរជាតិ
- ការងារអគ្រានុកូលដ្ឋាន
- ការគ្រប់គ្រង និងការថែរក្សាត្រា ឯកសារ លិខិតបទដ្ឋាននានារបស់រដ្ឋបាលក្រុង
- ការពិនិត្យ និងការកែសម្រួលរចនាសម្ព័ន្ធរបស់រដ្ឋបាលក្រុង
- ការរៀបចំនីតិវិធីរដ្ឋបាល និងនីតិវិធីហិរញ្ញវត្ថុសម្រាប់អង្គភាពរបស់រដ្ឋបាលក្រុង ផ្អែកតាមគោលការណ៍ និងបទប្បញ្ញត្តិជាធរមាន
- ការងារហិរញ្ញវត្ថុ ថវិកា និងទ្រព្យសម្បត្តិរបស់រដ្ឋបាលក្រុង
- ការងាររបាយការណ៍ប្រចាំខែ ប្រចាំត្រីមាស ប្រចាំឆមាស និងប្រចាំឆ្នាំ និងរបាយការណ៍ហិរញ្ញវត្ថុរបស់រដ្ឋបាលក្រុង
- ការងារផ្សេងទៀតតាមការប្រគល់ភារកិច្ចរបស់អភិបាលក្រុង។

**មាត្រា ១៦.-**

**អង្គភាពលទ្ធកម្ម**ត្រូវបំពេញតួនាទីជាសេនាធិការឱ្យរដ្ឋបាលក្រុងលើការងារលទ្ធកម្មសាធារណៈ និងមានភារកិច្ចចាត់ចែងលើការងារដូចខាងក្រោម៖

- ការរៀបចំផែនការលទ្ធកម្មប្រចាំឆ្នាំ
- ការរៀបចំឯកសារដេញថ្លៃ ការរៀបចំ និងការផ្សព្វផ្សាយអំពីកិច្ចលទ្ធកម្ម ការផ្ដល់ឯកសារដេញថ្លៃ ការទទួលសំណើដេញថ្លៃ ការរៀបចំទុកដាក់ឯកសារសំណើដេញថ្លៃ ការរៀបចំទីកន្លែង និងការរៀបចំបើកសំណើដេញថ្លៃ
- ការរៀបចំរបាយការណ៍ និងកំណត់ហេតុស្ដីពីការបើកសំណើដេញថ្លៃ
- ការរៀបចំ និងការសម្របសម្រួលក្នុងការវាយតម្លៃលើបច្ចេកទេសនៃសំណើដេញថ្លៃ
- ការរៀបចំកិច្ចសន្យា និងលិខិតជូនដំណឹងអំពីការប្រគល់កិច្ចសន្យា
- ការផ្សព្វផ្សាយលទ្ធផលនៃការដេញថ្លៃ
- ការតាមដានការអនុវត្តកិច្ចសន្យា និងការរៀបចំរបាយការណ៍ស្ដីពីការអនុវត្តកិច្ចលទ្ធកម្ម
- ការងារផ្សេងទៀតតាមការប្រគល់ភារកិច្ចរបស់អភិបាលក្រុង។

**មាត្រា ១៧.-**

**ការិយាល័យគ្រប់គ្រងធនធានមនុស្ស**ត្រូវបំពេញតួនាទីជាសេនាធិការឱ្យរដ្ឋបាលក្រុងលើការងារ

គ្រប់គ្រងធនធានមនុស្ស និងមានភារកិច្ចចាត់ចែងលើការងារដូចខាងក្រោម៖

- ការគ្រប់គ្រង ការចាត់ចែង និងការប្រើប្រាស់បុគ្គលិករបស់រដ្ឋបាលក្រុង
- ការបណ្តុះបណ្តាល និងការអភិវឌ្ឍសមត្ថភាពបុគ្គលិករបស់រដ្ឋបាលក្រុង
- ការគ្រប់គ្រងបុគ្គលិកផ្សេងទៀតតាមការផ្ទេរសិទ្ធិអំណាចពីរាជរដ្ឋាភិបាល ឬក្រសួង ស្ថាប័ន
- ការងារផ្សេងទៀតតាមការប្រគល់ភារកិច្ចរបស់អភិបាលក្រុង។

**មាត្រា ១៨.-**

**ការិយាល័យផែនការ និងគាំទ្រសង្កាត់**ត្រូវបំពេញតួនាទីជាសេនាធិការឱ្យរដ្ឋបាលក្រុងលើការងារផែនការ និងគាំទ្រសង្កាត់ក្នុងក្រុង និងមានភារកិច្ចចាត់ចែងលើការងារដូចខាងក្រោម៖

- ការរៀបចំ និងការអនុវត្តផែនការអភិវឌ្ឍន៍ប្រាំ(០៥)ឆ្នាំ កម្មវិធីវិនិយោគបី(០៣)ឆ្នាំរំកិល ផែនការសកម្មភាពនិងថវិកាប្រចាំឆ្នាំ និងគម្រោងអភិវឌ្ឍន៍នានារបស់រដ្ឋបាលក្រុង
- ការតាមដាន ការត្រួតពិនិត្យ និងការវាយតម្លៃលើការអនុវត្តផែនការអភិវឌ្ឍន៍ប្រាំ(០៥)ឆ្នាំ កម្មវិធីវិនិយោគបី(០៣)ឆ្នាំរំកិល ផែនការសកម្មភាពនិងថវិកាប្រចាំឆ្នាំ និងគម្រោងអភិវឌ្ឍន៍នានារបស់រដ្ឋបាលក្រុង
- ការងារស្ថិតិប្រជាជន
- ការគាំទ្រ ការសម្របសម្រួល និងការតាមដាន ត្រួតពិនិត្យ វាយតម្លៃរដ្ឋបាលសង្កាត់ក្នុងក្រុង លើការរៀបចំ និងការអនុវត្តផែនការអភិវឌ្ឍន៍ប្រាំ(០៥)ឆ្នាំ កម្មវិធីវិនិយោគបី(០៣)ឆ្នាំរំកិល និងគម្រោងនានារបស់រដ្ឋបាលសង្កាត់ក្នុងក្រុង
- ការណែនាំ និងការជំរុញការប្រមូលទិន្នន័យមូលដ្ឋានសង្កាត់ និងទិន្នន័យថ្នាក់ក្រុងតាមការកំណត់
- ការគ្រប់គ្រង និងការស្វែងរកការគាំទ្រការកែច្នៃទិន្នន័យមូលដ្ឋានសង្កាត់ និងទិន្នន័យថ្នាក់ក្រុង
- ការបណ្តុះបណ្តាល និងការអភិវឌ្ឍសមត្ថភាពបុគ្គលិក និងក្រុមប្រឹក្សាសង្កាត់តាមតម្រូវការចាំបាច់
- ការគាំទ្របច្ចេកទេសលើការងាររដ្ឋបាល និងហិរញ្ញវត្ថុដល់រដ្ឋបាលសង្កាត់
- ការដោះស្រាយសំណើ សំណូមពរ និងបញ្ហាប្រឈមនានារបស់រដ្ឋបាលសង្កាត់
- ការងារផ្សេងទៀតតាមការប្រគល់ភារកិច្ចរបស់អភិបាលក្រុង។

**មាត្រា ១៩.-**

**ការិយាល័យត្រួតពិនិត្យផ្ទៃក្នុង**ត្រូវបំពេញតួនាទីជាសេនាធិការឱ្យរដ្ឋបាលក្រុងលើការត្រួតពិនិត្យការបំពេញការងាររបស់ការិយាល័យ និងអង្គភាពនានាចំណុះរដ្ឋបាលក្រុង និងមានភារកិច្ចចាត់ចែងលើការងារដូចខាងក្រោម៖

- ការត្រួតពិនិត្យលើការអនុវត្តតាមច្បាប់ ដីកា លិខិតបទដ្ឋានគតិយុត្ត និងស្តង់ដាសេវានានាដែលបានកំណត់ជាធរមាន
- ការត្រួតពិនិត្យលើការងាររដ្ឋបាល ការងារបុគ្គលិក ការងារហិរញ្ញវត្ថុ និងទ្រព្យសម្បត្តិរបស់រដ្ឋបាលក្រុង

- ការត្រួតពិនិត្យការអនុវត្តវិន័យ បទបញ្ជាផ្ទៃក្នុង ក្រមសីលធម៌ និងម៉ោងបំពេញការងាររបស់បុគ្គលិករដ្ឋបាលក្រុង
- ការងារផ្សេងទៀតតាមការប្រគល់ភារកិច្ចរបស់អភិបាលក្រុង។

មាត្រា ២០.-

**ការិយាល័យលេខាធិការក្រុមប្រឹក្សា**ត្រូវបំពេញតួនាទីជាសេនាធិការឱ្យរដ្ឋបាលក្រុងលើការងារលេខាធិការដ្ឋានជូនក្រុមប្រឹក្សាក្រុង និងមានភារកិច្ចចាត់ចែងលើការងារដូចខាងក្រោម៖

- ការរៀបចំកិច្ចប្រជុំសាមញ្ញ និងវិសាមញ្ញរបស់ក្រុមប្រឹក្សា
- ការរៀបចំកំណត់ហេតុនៃកិច្ចប្រជុំនានារបស់ក្រុមប្រឹក្សា
- ការរៀបចំវេទិកាផ្សព្វផ្សាយ និងពិគ្រោះយោបល់នានារបស់ក្រុមប្រឹក្សា
- ការគ្រប់គ្រង ការថែរក្សា និងការទុកដាក់ឯកសារនានារបស់ក្រុមប្រឹក្សា
- ការបិទផ្សាយ និងការផ្សព្វផ្សាយនូវសេចក្តីសម្រេច និងឯកសារនានារបស់ក្រុមប្រឹក្សា
- ការងារផ្សេងទៀតតាមការប្រគល់ភារកិច្ចរបស់ប្រធានក្រុមប្រឹក្សា និងអភិបាលក្រុង។

មាត្រា ២១.-

**ការិយាល័យអប់រំ យុវជន និងកីឡា**ត្រូវបំពេញតួនាទីជាសេនាធិការឱ្យរដ្ឋបាលក្រុងលើការងារអប់រំ យុវជន និងកីឡា និងមានភារកិច្ចគ្រប់គ្រង គាំទ្រ សម្របសម្រួល និងតាមដាន ត្រួតពិនិត្យ វាយតម្លៃលើមុខងារមួយចំនួនដូចខាងក្រោម៖

- ការអប់រំកុមារតូច
- ការអប់រំបឋមសិក្សា
- ការងាររដ្ឋបាលគាំទ្រគ្រឹះស្ថានមធ្យមសិក្សាចំណេះទូទៅ
- ការអប់រំក្រៅប្រព័ន្ធ
- ការអភិវឌ្ឍយុវជន
- ការអប់រំកាយ និងកីឡា
- ការងារផ្សេងទៀតតាមការប្រគល់ភារកិច្ចរបស់អភិបាលក្រុង។

មាត្រា ២២.-

**ការិយាល័យរៀបចំដែនដី នគរូបនីយកម្ម សំណង់ និងភូមិបាល**ត្រូវបំពេញតួនាទីជាសេនាធិការឱ្យរដ្ឋបាលក្រុងលើការងាររៀបចំដែនដី នគរូបនីយកម្ម សំណង់ និងភូមិបាល និងមានភារកិច្ចចាត់ចែងលើមុខងារមួយចំនួនដូចខាងក្រោម៖

- ការងាររៀបចំដែនដី និងនគរូបនីយកម្ម
- ការងារភូមិបាល
- ការងារសំណង់
- ការងារលំនៅឋាន

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**ខេត្តកណ្ដាល**
**រដ្ឋបាលស្រុកកៀនស្វាយ**
លេខ៖....០២៤......ស.ស.រ

# សេចក្ដីសម្រេច
# ស្ដីពី
# ការបែងចែកតួនាទី ភារកិច្ច និងរបៀបរបបធ្វើការងារ ជូនគណៈអភិបាលស្រុកកៀនស្វាយ

## អភិបាល នៃគណៈអភិបាលស្រុកកៀនស្វាយ

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ ស្ដីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៨/៩២៥ ចុះថ្ងៃទី០៦ ខែកញ្ញា ឆ្នាំ២០១៨ ស្ដីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឲ្យប្រើច្បាប់ស្ដីពីការបង្កើតក្រសួងមហាផ្ទៃ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៧ ចុះថ្ងៃទី២៤ ខែឧសភា ឆ្នាំ២០០៨ ដែលប្រកាសឲ្យប្រើច្បាប់ស្ដីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១១៩/០០៤ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ២០១៩ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីវិសោធនកម្មច្បាប់ស្ដីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ
- បានឃើញអនុក្រឹត្យលេខ ២១៦ អនក្រ.បក ចុះថ្ងៃទី១៤ ខែធ្នូ ឆ្នាំ២០០៩ ស្ដីពីតួនាទី ភារកិច្ច និងទំនាក់ទំនងការងារ របស់ក្រុមប្រឹក្សា គណៈអភិបាលខេត្ត ក្រុមប្រឹក្សា គណៈអភិបាលក្រុង និងក្រុមប្រឹក្សា គណៈអភិបាលស្រុក
- បានឃើញអនុក្រឹត្យលេខ ១០៩ អនក្រ.បក ចុះថ្ងៃទី១៩ ខែសីហា ឆ្នាំ២០១៥ ស្ដីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃក្រសួងមហាផ្ទៃ
- បានឃើញអនុក្រឹត្យលេខ ១៨៤ អនក្រ.បក ចុះថ្ងៃទី០២ ខែធ្នូ ឆ្នាំ២០១៩ ស្ដីពីមុខងារ និងរចនាសម្ព័ន្ធរដ្ឋបាលស្រុក
- បានឃើញអនុក្រឹត្យលេខ ១១៩ អនក្រ.បក ចុះថ្ងៃទី១៧ ខែមិថុនា ឆ្នាំ២០២២ ស្ដីពីការកំណត់ចំនួន គណៈអភិបាលរាជធានី គណៈអភិបាលខេត្ត គណៈអភិបាលក្រុង គណៈអភិបាលស្រុក គណៈអភិបាលខណ្ឌ ✓



អាសយដ្ឋាន ផ្លូវជាតិលេខ១ ភូមិគគីរ ឃុំគគីរ ស្រុកកៀនស្វាយ ខេត្តកណ្ដាល ព្រះរាជាណាចក្រកម្ពុជា | NR #1, kokir Village, Kokir Commune, Kean Svay District, Kandal Province, Cambodia.
• Hotline: 097 7 255 218 • Facebook page: រដ្ឋបាលស្រុកកៀនស្វាយ • Email: keansvay2018@gmail.com

Scanned with CamScanner

- បានឃើញអនុក្រឹត្យលេខ ៤៦៥ អនក្រ.តត ចុះថ្ងៃទី៣០ ខែមិថុនា ឆ្នាំ២០២២ ស្ដីពីការតែងតាំងមន្ត្រីរាជការឱ្យកាន់មុខតំណែងជា អភិបាល នៃគណៈអភិបាលស្រុកកៀនស្វាយ
- បានឃើញប្រកាសលេខ ៤២៦៥ប្រក ចុះថ្ងៃទី០២ ខែវិច្ឆិកា ឆ្នាំ២០២០ របស់ក្រសួងមហាផ្ទៃ ស្ដីពីការតែងតាំងមន្ត្រីរាជការ ឱ្យកាន់មុខតំណែងជាអភិបាលរង នៃគណៈអភិបាលស្រុកកៀនស្វាយ សម្រាប់អាណត្តិទី២
- បានឃើញប្រកាសលេខ ៤១៨១ ប្រក ចុះថ្ងៃទី០៦ ខែកក្កដា ឆ្នាំ ២០២២ របស់ក្រសួងមហាផ្ទៃ ស្ដីពីការផ្ទេរ ភារកិច្ច និងតែងតាំងមន្ត្រីរាជការឱ្យកាន់មុខតំណែងជាអភិបាលរង នៃគណៈអភិបាលស្រុកកៀនស្វាយ
- បានឃើញប្រកាសលេខ ៥៦៤៩ ប្រក ចុះថ្ងៃទី១៨ ខែតុលា ឆ្នាំ២០២២ របស់ក្រសួងមហាផ្ទៃ ស្ដីពីការតែងតាំងមន្ត្រីរាជការ ឱ្យកាន់មុខតំណែងជាអភិបាលរង នៃគណៈអភិបាលស្រុកកៀនស្វាយ
- យោងសេចក្ដីណែនាំលេខ ០៤៧ សណន ចុះថ្ងៃទី៣០ ខែកញ្ញា ឆ្នាំ២០២២ របស់ក្រសួងមហាផ្ទៃ ស្ដីពីការបែងចែកតួនាទី ភារកិច្ច និងរបៀបរបបធ្វើការងារ ជូនគណៈអភិបាលខេត្ត គណៈអភិបាលក្រុង គណៈអភិបាលស្រុក
- យោងស្មារតីកិច្ចប្រជុំគណៈអភិបាលស្រុកកៀនស្វាយ នាថ្ងៃទី២៣ ខែវិច្ឆិកា ឆ្នាំ២០២២
- ទទួលបានការអនុម័តពីក្រុមប្រឹក្សាស្រុកកៀនស្វាយក្នុងកិច្ចប្រជុំវិសាមញ្ញលើកទី៤២ អាណត្តិទី៣ កាលពីរសៀល ថ្ងៃទី២៣ ខែវិច្ឆិកា ឆ្នាំ២០២២

## សម្រេច

**ប្រការ ១.-**

គណៈអភិបាលស្រុកកៀនស្វាយ ត្រូវគ្រប់គ្រង និងដឹកនាំដោយអភិបាលស្រុក ០១រូប និងអភិបាលរង ចំនួន ០៦រូប ជាជំនួយការ។

**ប្រការ ២.-**

អភិបាល និងអភិបាលរងស្រុកកៀនស្វាយ ត្រូវរួមគ្នាដឹកនាំ គ្រប់គ្រងកិច្ចការរដ្ឋបាលដែនដី ការពារសន្តិសុខ សណ្ដាប់ធ្នាប់ សុវត្ថិភាពសង្គម និងលើកកម្ពស់ការអភិវឌ្ឍន៍សេដ្ឋកិច្ច សង្គមកិច្ច វប្បធម៌ នៅក្នុងក្របខណ្ឌ នៃភូមិសាស្ត្រស្រុកកៀនស្វាយ ខេត្តកណ្ដាល ស្របទៅតាមគោលនយោបាយ របស់រាជរដ្ឋាភិបាល ច្បាប់ លិខិតបទដ្ឋានជាធរមាន និងសេចក្ដីសម្រេចរបស់ក្រុមប្រឹក្សា។

**ប្រការ ៣.-**

អភិបាល និងអភិបាលរងស្រុក ត្រូវបំពេញមុខងារ និងទទួលខុសត្រូវស្របទៅតាមលំដាប់ឋានានុក្រម និងអនុវត្តតួនាទី ភារកិច្ច ដែលបានបែងចែក ដូចមានក្នុងប្រការ៤។

អភិបាលរងស្រុក ដែលបានទទួលការបែងចែកភារកិច្ចនេះ ត្រូវទទួលខុសត្រូវចំពោះមុខអភិបាលស្រុក លើភារកិច្ចនានា ដែលបានប្រគល់ ហើយត្រូវរួមជាមួយអភិបាលស្រុក ទទួលខុសត្រូវអំពីការសម្រេច និងសកម្មភាពការងារក្នុងគណៈអភិបាលរបស់ខ្លួន។

**ប្រការ ៤.-**

អភិបាល និងអភិបាលរងស្រុកកៀនស្វាយ ត្រូវបានកំណត់នូវការបែងចែកតួនាទី ភារកិច្ច ដូចខាងក្រោម ៖



អាសយដ្ឋាន ផ្លូវជាតិលេខ១ ភូមិគគីរ ឃុំគគីរ ស្រុកកៀនស្វាយ ខេត្តកណ្ដាល ព្រះរាជាណាចក្រកម្ពុជា | NR #1, Kokir Village, Kokir Commune, Kean Svay District, Kandal Province, Cambodia.
• Hotline: 097 7 255 218 • Facebook page: រដ្ឋបាលស្រុកកៀនស្វាយ • Email: keansvay2018@gmail.com

Scanned with CamScanner

១- លោក **ឡុង សុខសាន** អភិបាលស្រុកកៀនស្វាយ ទទួលបន្ទុកដឹកនាំការងាររួម និងដឹកនាំផ្ទាល់លើការងាររដ្ឋបាលទូទៅ ការងារសន្តិសុខ សណ្តាប់ធ្នាប់សាធារណៈ កិច្ចការប្រយុទ្ធប្រឆាំងគ្រឿងញៀន កិច្ចការប្រយុទ្ធប្រឆាំងការជួញដូរមនុស្ស កិច្ចការ គ្រប់គ្រងគ្រោះមហន្តរាយ និងជាអាណាប័កក្នុងនាមក្រុមប្រឹក្សារបស់ខ្លួន។

២- លោក **សន ហុងសេង** អភិបាលរងស្រុកកៀនស្វាយ ទទួលជួយអភិបាលស្រុក លើការងាររដ្ឋបាល ការងារគ្រប់គ្រង និងអភិវឌ្ឍធនធានមនុស្ស ការងារផ្តល់សេវារដ្ឋបាល ការងារលេខាធិការក្រុមប្រឹក្សា និងការងារទំនាក់ទំនងសាធារណៈ។

៣- លោក **ស៊ុម ធន** អភិបាលរងស្រុកកៀនស្វាយ ទទួលជួយអភិបាលស្រុក លើការងារហិរញ្ញវត្ថុ ការងារថវិកា ការងារលទ្ធកម្មសាធារណៈ ការងារគ្រប់គ្រងទ្រព្យសម្បត្តិរដ្ឋ ការងារផែនការនិងគាំទ្រឃុំ សង្កាត់ ការងារស្ថិតិប្រជាជន ការងារអភិវឌ្ឍន៍សហគមន៍។

៤- លោកស្រី **ហាឡូ ចន្ថា** អភិបាលរងស្រុកកៀនស្វាយ ទទួលជួយអភិបាលស្រុក លើការងារអគ្រានុកូលដ្ឋាន ការងារសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា ការងារសុខាភិបាល កិច្ចការនារី ការងារធម្មការ និងសាសនា ការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ការងារវប្បធម៌ និងវិចិត្រសិល្បៈ។

៥- លោក **សុខ ពិសិទ្ធ** អភិបាលរងស្រុកកៀនស្វាយ ទទួលជួយអភិបាលស្រុក លើការងាររៀបចំដែនដី នគរូបនីយកម្ម និងសំណង់ និងការងារគ្រប់គ្រងតំបន់ការពារធម្មជាតិ និងការងារនីតិកម្ម និង សម្រុះសម្រួលវិវាទនៅមូលដ្ឋាន។

៦- លោក **ពៅ គីមលី** អភិបាលរងស្រុកកៀនស្វាយ ទទួលជួយអភិបាលស្រុក លើការងារសាធារណការ និងដឹកជញ្ជូន ការងារពាណិជ្ជកម្ម ឧស្សាហកម្ម សិប្បកម្ម ការងាររ៉ែនិងថាមពល ការងារទេសចរណ៍ ការងារប្រៃសណីយ៍និងទូរគមនាគមន៍ ការងារអភិវឌ្ឍន៍ជនបទ ការងារគ្រប់គ្រងសំរាម សំណល់រឹងទីប្រជុំជន ការគ្រប់គ្រងប្រព័ន្ធលូ ការងារបំភ្លឺសាធារណៈ ការងារដាំដើមឈើ និងសួនច្បារសាធារណៈ។

៧- លោក **លីវ ចណ្ណាថេង** អភិបាលរងស្រុកកៀនស្វាយ ទទួលជួយអភិបាលស្រុក លើការងារកសិកម្ម រុក្ខាប្រមាញ់និងនេសាទ ការងារធនធានទឹក ការងារអប់រំ យុវជន និងកីឡា ការងារត្រួតពិនិត្យផ្ទៃក្នុង និងការងារវេទិកាសាធារណៈ។

ក្រៅពីភារកិច្ចដែលបានបែងចែកខាងលើ អភិបាលស្រុក អាចប្រគល់ភារកិច្ចបន្ថែមជូនអភិបាលរងស្រុក ទៅតាមសំណូមពរការងារជាក់ស្តែងរបស់រដ្ឋបាលស្រុកកៀនស្វាយ។



អាសយដ្ឋាន ផ្លូវជាតិលេខ១ ភូមិគគីរ ឃុំគគីរ ស្រុកកៀនស្វាយ ខេត្តកណ្តាល ព្រះរាជាណាចក្រកម្ពុជា | NR #1, kokir Village, Kokir Commune, Kean Svay District, Kandal Province, Cambodia.
• Hotline: 097 7 255 218 • Facebook page: រដ្ឋបាលស្រុកកៀនស្វាយ • Email: keansvay2018@gmail.com

Scanned with CamScanner

**ប្រការ ៥.-**

ចំពោះរបៀបរបបធ្វើការងារ របស់គណៈអភិបាលស្រុកកៀនស្វាយ ត្រូវអនុវត្តឲ្យបានស្របទៅតាមសេចក្តីណែនាំលេខ ០៤៧ សណន ចុះថ្ងៃទី៣០ ខែកញ្ញា ឆ្នាំ២០២២ របស់ក្រសួងមហាផ្ទៃ ស្តីពីការបែងចែក តួនាទី ភារកិច្ច និងរបៀបរបបធ្វើការងារ ជូនគណៈអភិបាលខេត្ត គណៈអភិបាលក្រុង គណៈអភិបាលស្រុក។

**ប្រការ ៦.-**

បទប្បញ្ញត្តិទាំងឡាយណាដែលមានខ្លឹមសារផ្ទុយនឹងសេចក្តីសម្រេចនេះ ត្រូវទុកជានិរាករណ៍។

**ប្រការ ៧.-**

នាយករដ្ឋបាលសាលាស្រុក ប្រធានការិយាល័យ អង្គភាពចំណុះរចនាសម្ព័ន្ធរដ្ឋបាលស្រុក ប្រធានការិយាល័យ អង្គភាពជុំវិញស្រុក មេឃុំ និងសាមីខ្លួនដែលមានឈ្មោះក្នុងប្រការ៤ ខាងលើត្រូវអនុវត្តសេចក្តីសម្រេចនេះតាមភារកិច្ចរៀងៗខ្លួនឱ្យមានប្រសិទ្ធភាពខ្ពស់ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ថ្ងៃព្រហស្បតិ៍ ២រោច ខែកត្តិក ឆ្នាំខាល ចត្វាស័ក ព.ស.២៥៦៦

ធ្វើនៅស្រុកកៀនស្វាយ,ថ្ងៃទី ១០ ខែ វិច្ឆិកា ឆ្នាំ២០២២

**អភិបាលស្រុក**

**ឡូច សុខសាន**

<u>កន្លែងទទួល៖</u>

- ក្រសួងមហាផ្ទៃ
- លេខាធិការដ្ឋាន គ.ជ.អ.ប
- រដ្ឋបាលខេត្តកណ្តាល
- មន្ទីរ អង្គភាព ជំនាញជុំវិញខេត្តកណ្តាល
- ដូចប្រការ៧
- ឯកសារ-កាលប្បវត្តិ

លេខ៖.................

**បានឃើញ និងឯកភាព**

ថ្ងៃ.....................ខែ................ឆ្នាំខាល ចត្វាស័ក ព.ស.២៥៦៦

កណ្តាល,ថ្ងៃទី ................ ខែ ............... ឆ្នាំ២០........

**អភិបាលខេត្ត**



អាសយដ្ឋាន ផ្លូវជាតិលេខ១ ភូមិគគីរ ឃុំគគីរ ស្រុកកៀនស្វាយ ខេត្តកណ្តាល ព្រះរាជាណាចក្រកម្ពុជា | NR #1, kokir Village, Kokir Commune, Kean Svay District, Kandal Province, Cambodia.
• Hotline: 097 7 255 218 • Facebook page: រដ្ឋបាលស្រុកកៀនស្វាយ • Email: keansvay2018@gmail.com

Scanned with CamScanner

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ខេត្តកណ្ដាល
រដ្ឋបាលស្រុកកៀនស្វាយ
លេខៈ ០០៣ ស.ស.រ

# សេចក្ដីសម្រេច
## ស្ដីពី
## គោលការណ៍ណែនាំផ្នែកគោលនយោបាយ សម្រាប់ការកសាងផែនការអភិវឌ្ឍន៍រយៈពេល៥ឆ្នាំ (២០២០-២០២៤) និងកម្មវិធីវិនិយោគបីឆ្នាំរំកិល( ២០២០-២០២២) ស្រុកកៀនស្វាយ

## ក្រុមប្រឹក្សាស្រុកកៀនស្វាយ

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខនស/រកត/០៩១៨/៩២៥ ចុះថ្ងៃទី០៦ ខែកញ្ញា ឆ្នាំ២០០៨ ស្ដីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា ។
- បានឃើញព្រះរាជក្រមលេខ នស/រកម០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសអោយប្រើច្បាប់ស្ដីពីការរៀបចំ និងប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី ។
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសអោយប្រើច្បាប់ស្ដីពីការបង្កើតក្រសួងមហាផ្ទៃ ។
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៧ ចុះថ្ងៃទី ២៤ ខែ ឧសភា ឆ្នាំ ២០០៨ ដែលប្រកាសឲ្យប្រើច្បាប់ស្ដីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ។
- បានឃើញព្រះរាជក្រមលេខ នស/រកម០១១៩/០០៤ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ២០១៩ ដែលប្រកាសអោយប្រើច្បាប់ស្ដីពីវិសោធនកម្មច្បាប់ស្ដីពីការគ្រប់គ្រង់រដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ។
- បានឃើញព្រះរាជក្រមលេខ នស/រកម០១១៩/០០៤ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ២០១៩ ដែលប្រកាសអោយប្រើច្បាប់ស្ដីពីវិសោធនកម្មច្បាប់ស្ដីពីការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សារាជធានី ក្រុមប្រឹក្សាខេត្ត ក្រុមប្រឹក្សាក្រុង ក្រុមប្រឹក្សាស្រុក ក្រុមប្រឹក្សាខណ្ឌ ។
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៨ ចុះថ្ងៃទី ២៤ ខែ ឧសភា ឆ្នាំ ២០០៨ ដែលប្រកាសឲ្យប្រើច្បាប់ស្ដីពីការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សារាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ។
- បានឃើញអនុក្រឹត្យលេខ ៦៣៧ អនក្រ.គត ចុះថ្ងៃទី១០ ខែមិថុនា ឆ្នាំ២០១៩ ស្ដីពី ការទទួលស្គាល់សមាសភាពក្រុមប្រឹក្សាស្រុកកៀនស្វាយ អាណត្តិទី៣ ។

- បានឃើញអនុក្រឹត្យលេខ ២១៦អនក្រ.បក ចុះថ្ងៃទី ១៤ ខែ ធ្នូ ឆ្នាំ ២០០៩ ស្ដីពីតួនាទី ភារកិច្ច និងទំនាក់ទំនងការងាររបស់ក្រុមប្រឹក្សា គណៈអភិបាលខេត្ត ក្រុមប្រឹក្សា គណៈអភិបាលក្រុង និងក្រុមប្រឹក្សា គណៈអភិបាលស្រុក ។
- បានឃើញអនុក្រឹត្យលេខ ២១៩ អនក្រ.បក ចុះថ្ងៃទី ១៤ ខែ ធ្នូ ឆ្នាំ ២០០៩ ស្ដីពីការកសាងផែនការអភិវឌ្ឍន៍ និងកម្មវិធីវិនិយោគ៣ឆ្នាំរំកិល រាជធានីខេត្ត ក្រុង ស្រុក ខណ្ឌ ។
- បានឃើញអនុក្រឹត្យលេខ ១៥២ អនក្រ.បក ចុះថ្ងៃទី ០៦ ខែ ធ្នូ ឆ្នាំ ២០១០ ស្ដីពីការកែសម្រួលមាត្រា១២ នៃអនុក្រឹត្យលេខ ២១៩ អនក្រ.បក ចុះថ្ងៃទី ១៤ ខែ ធ្នូ ឆ្នាំ ២០០៩ ស្ដីពីផែនការអភិវឌ្ឍន៍ និងកម្មវិធីវិនិយោគបីឆ្នាំរំកិលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ។
- យោងប្រកាសអន្តរក្រសួងលេខ ២៤១៧ ប្រ.ក ចុះថ្ងៃទី ២៧ ខែ ធ្នូ ឆ្នាំ ២០១០ របស់ក្រសួងមហាផ្ទៃ និងក្រសួងផែនការ ស្ដីពីការកសាងផែនការអភិវឌ្ឍន៍ និងកម្មវិធីវិនិយោគបីឆ្នាំរំកិល រាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ។
- យោងស្មារតីកិច្ចប្រជុំសាមញ្ញ លើកទី២ របស់ក្រុមប្រឹក្សាស្រុកកាលពីថ្ងៃសុក្រ ១៤កើត ខែមាឃ ឆ្នាំកុរ ឯកស័ក ពស ២៥៦៣ ត្រូវនឹងថ្ងៃទី០៧ ខែកុម្ភៈ ឆ្នាំ ២០២០

## សម្រេច

**ប្រការ១:**

សេចក្ដីសម្រេចនេះ មានគោលបំណងណែនាំផ្នែកគោលនយោបាយសម្រាប់ការកសាងផែនការអភិវឌ្ឍន៍ និងកម្មវិធីវិនិយោគបីឆ្នាំរំកិលស្រុកកៀនស្វាយ ។

**ប្រការ២:**

ដំណើរការកសាងផែនការអភិវឌ្ឍន៍ និងកម្មវិធីវិនិយោគបីឆ្នាំរំកិលស្រុកកៀនស្វាយ ត្រូវអនុវត្តទៅតាមសេចក្ដីណែនាំបច្ចេកទេសស្ដីពីការកសាងផែនការអភិវឌ្ឍន៍ និងកម្មវិធីវិនិយោគបីឆ្នាំរំកិលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ។

**ប្រការ៣:**

ផែនការអភិវឌ្ឍន៍ និងកម្មវិធីវិនិយោគបីឆ្នាំរំកិលស្រុកកៀនស្វាយ ត្រូវបានរៀបចំឡើងដោយផ្អែកលើគោលការណ៍សំខាន់ៗទាំង៩ គឺ ៖

១.ការចែករំលែកព័ត៌មាន
២.តម្លាភាព
៣.គណនេយ្យភាពតាមបែបប្រជាធិបតេយ្យ
៤.សង្គតិភាព និងសុខដុមនីយកម្ម
៥.ការចូលរួមពិគ្រោះយោបល់ជាទូទៅ
៦.ការឆ្លើយតប តាមតម្រូវការ
៧.ប្រសិទ្ធភាព និងស័ក្តិសិទ្ធភាព ផ្នែកសេដ្ឋកិច្ច និងសង្គមកិច្ច

៨.ការធានាឲ្យមានចីរភាព ធនធានធម្មជាតិ និងបរិស្ថាន
៩.ការធានាសមធម៌ ។

**ប្រការ៤:**

ផែនការអភិវឌ្ឍន៍ និងកម្មវិធីវិនិយោគបីឆ្នាំរំកិលស្រុកកៀនស្វាយ ត្រូវមានលក្ខណៈគ្រប់ជ្រុងជ្រោយដែលគ្របដណ្តប់លើគ្រប់វិស័យអាទិភាព ឆ្លើយតបទៅនិងតម្រូវការជាក់ស្តែង និងស្របតាមគោលនយោបាយអភិវឌ្ឍន៍ខេត្ត និងត្រូវមានសង្គតិភាពជាមួយគោលនយោបាយថ្នាក់ជាតិ ដូចជាផែនការអភិវឌ្ឍន៍ជាតិ ដើម្បីអភិវឌ្ឍន៍សេដ្ឋកិច្ច និងធ្វើឲ្យប្រសើរឡើងនូវគុណភាពជីវិត និងសុខុមាលភាពប្រជាពលរដ្ឋ នៅក្នុងដែនសមត្ថកិច្ចរបស់ស្រុក។

**ប្រការ៥:**

ចក្ខុវិស័យអភិវឌ្ឍន៍ គោលដៅអភិវឌ្ឍន៍ គោលបំណងអភិវឌ្ឍន៍ និងយុទ្ធសាស្ត្រអភិវឌ្ឍន៍ទាំងអស់នៃផែនការអភិវឌ្ឍន៍ស្រុកកៀនស្វាយ និងគម្រោងទាំងអស់នៃកម្មវិធីវិនិយោគបីឆ្នាំរំកិលស្រុកកៀនស្វាយត្រូវយកចិត្តទុកដាក់ក្នុងការអភិវឌ្ឍ សេដ្ឋកិច្ច និងសង្គមកិច្ចនៅមូលដ្ឋាន ព្រមទាំងកែលំអគុណភាពសេវានានា សំដៅរួមចំណែកកាត់បន្ថយភាពក្រីក្រ និងការលើកកម្ពស់ជីវភាពរស់នៅ សុខុមាលភាពសេចក្តីថ្លៃថ្នូរ និងសុវត្ថិភាពរបស់ប្រជាពលរដ្ឋព្រមទាំងធានាបាននូវបរិស្ថានល្អ និរន្តរភាពធនធានធម្មជាតិសមភាព និងសមធម៌យេនឌ័រ ។

**ប្រការ៦:**

ផែនការអភិវឌ្ឍន៍ និងកម្មវិធីវិនិយោគបីឆ្នាំរំកិលស្រុកកៀនស្វាយ ត្រូវយកចិត្តទុកដាក់ជាសំខាន់ទៅលើវិស័យនិងសកម្មភាពសំខាន់ៗដូចខាងក្រោម ៖

១. ពង្រឹង និងពង្រីកផលិតកម្ម កសិកម្ម ទាំងបរិមាណ និងគុណភាព

២. យកចិត្តទុកដាក់ទៅលើការស្តារ ការកសាង និងការជួសជុល ការថែទាំ និងការគ្រប់គ្រងប្រព័ន្ធធារាសាស្ត្រ ដើម្បីធានាបាននូវការស្រោចស្រព ។

៣. កសាង និងជួសជុលហេដ្ឋារចនាសម្ព័ន្ធគមនាគមន៍គ្រប់ប្រភេទ

៤. ពង្រឹង និងពង្រីកបរិមាណ និងគុណភាពនៃការអប់រំ

៥. យកចិត្តទុកដាក់សេវាសុខុមាលភាពរបស់ប្រជាពលរដ្ឋ ពិសេសស្ត្រី និងកុមារ

៦. ជំរុញការអនុវត្តច្បាប់នានា ពិសេសច្បាប់ព្រៃឈើ ច្បាប់ជលផល ច្បាប់ភូមិបាល ការធ្វើប័ណ្ណកម្មសិទ្ធិគ្រប់គ្រងដីធ្លី ច្បាប់ចរាចរណ៍ផ្លូវគោក ច្បាប់ស្តីពីការកាត់បន្ថយអំពើហិង្សាក្នុងគ្រួសារ និងកិច្ចការពារជនរងគ្រោះ ច្បាប់ប្រឆាំងអំពើពុករលួយ និងច្បាប់ផ្សេងៗដែលរដ្ឋកំណត់ ។

៧. យកចិត្តទុកដាក់ទៅលើផែនការទប់ស្កាត់ និងកាត់បន្ថយហានីភ័យគ្រោះមហន្តរាយ

៨. លើកកម្ពស់ការអភិវឌ្ឍតំបន់ទេសចរណ៍ និងបរិស្ថាន

៩. យកចិត្តទុកដាក់លើការងារសណ្តាប់ធ្នាប់សាធារណៈ និងរក្សាសុវត្ថិភាពសហគមន៍ជូនប្រជាពលរដ្ឋ ។

១០.យកចិត្តទុកដាក់បណ្តុះបណ្តាលកសាងពង្រឹងសមត្ថភាព និងការបំពេញមុខងាររបស់រដ្ឋបាលថ្នាក់ក្រោមជាតិ។

១១. ពង្រឹង និងលើកកម្ពស់តួនាទីសិទ្ធិអំណាច និងការធ្វើសេចក្តីសម្រេចចិត្តរបស់ស្ត្រីក្នុងវិស័យនយោបាយសេដ្ឋកិច្ច និងសង្គមកិច្ច ។

**ប្រការ៧:**

ដំណើរការកសាងផែនការអភិវឌ្ឍន៍ និងកម្មវិធីវិនិយោគបីឆ្នាំរំកិលស្រុកកៀនស្វាយ ត្រូវផ្តល់ឱកាសឲ្យបានពេញលេញដល់អ្នកពាក់ព័ន្ធទាំងអស់ ដើម្បីចូលរួមនៅក្នុងដំណើរការទាំងមូល ។ អ្នកពាក់ព័ន្ធទាំងនោះ រួមមាន ក្រុមប្រឹក្សាស្រុក គណៈអភិបាលស្រុក ការិយាល័យទាំងបីរបស់សាលាស្រុក អង្គភាពជំនាញជុំវិញស្រុក ក្រុមប្រឹក្សាឃុំ អង្គការសង្គមស៊ីវិល វិស័យឯកជន ប្រជាពលរដ្ឋ ក្រុមតំណាងផលប្រយោជន៍ ក្រុមជនងាយរងគ្រោះ ។ល។

**ប្រការ៨:**

គណៈអភិបាលស្រុក ក្រុមការងារកសាងផែនការអភិវឌ្ឍន៍ និងកម្មវិធីវិនិយោគបីឆ្នាំរំកិលស្រុក ការិយាល័យចំណុះសាលាស្រុក អង្គភាព និងអ្នកពាក់ព័ន្ធទាំងអស់ក្នុងស្រុក ត្រូវអនុវត្តតាមសេចក្តីសម្រេចនេះឲ្យមានប្រសិទ្ធភាពចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

ថ្ងៃសុក្រ ១៤កើត ខែមាឃ ឆ្នាំកុរ ឯកស័ក ព.ស ២៥៦៣

[illegible]ថ្ងៃទី០៧ ខែកុម្ភៈ ឆ្នាំ២០២០

ជ.ក្រុមប្រឹក្សាស្រុក

ប្រធាន

ប៊ុនធឿន

**<u>ចម្លងជូន៖</u>**

- ក្រសួងមហាផ្ទៃ
- ក្រសួងផែនការ
- លេខាធិការដ្ឋានគ.ជ.អ.ប
- សាលាខេត្តកណ្តាល
  "ដើម្បីគោរពជូនជ្រាប"
- ដូចប្រការ ៨
  "ដើម្បីអនុវត្ត"
- ឯកសារ កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ខេត្តកណ្តាល
រដ្ឋបាលស្រុកក្បៀនស្វាយ

# ប្រតិទិនការងារសំរាប់ការកសាងផែនការអភិវឌ្ឍន៍ស្រុក រយៈពេល៥ឆ្នាំ ( ២០២០-២០២៤ )

| ល.រ | សកម្មភាព | ពេលវេលា | ទីតាំង | អ្នកទទួលខុសត្រូវ | ថវិកា | ផ្សេងៗ |
|---|---|---|---|---|---|---|
| ជំហានទី១៖ ការរៀបចំការកសាងផែនការអភិវឌ្ឍស្រុក | | | | | | |
| ១.១ | ការរៀបចំប្រតិទិនការងារសម្រាប់ដំណើរការកសាងផែនការស្រុក | សប្តាហ៍ទី១ មករា ២០២០ | សាលាស្រុក | ក្រុមការងារកសាងផែនការ | | |
| ១.២ | ផ្សព្វផ្សាយព័ត៌មានអំពីការកសាងផែនការអភិវឌ្ឍន៍ស្រុក | សប្តាហ៍ទី២ មករា ២០២០ | សាលាស្រុក | ក្រុមការងារកសាងផែនការ | | |
| ១.៣ | រៀបចំតារាងវិភាគស្ថានភាពស្រុក | សប្តាហ៍ទី៣-៤ មករា ២០២០ | សាលាស្រុក | ក្រុមការងារកសាងផែនការ<br>ឃុំទាំង៨<br>ការិយាល័យជុំវិញស្រុក | | |
| ១.៤ | រៀបចំគោលការណ៍ណែនាំផ្នែកគោលនយោបាយរបស់ក្រុមប្រឹក្សាស្រុក | សប្តាហ៍ទី១ កុម្ភៈ ២០២០ | សាលាស្រុក | ក្រុមប្រឹក្សាស្រុក<br>ក្រុមការងារកសាងផែនការ | | |
| ១.៥ | រៀបចំទិន្នន័យ និងឯកសារពាក់ព័ន្ធនានា | សប្តាហ៍ទី២-៣ កុម្ភៈ ២០២០ | សាលាស្រុក | ឃុំទាំង៨<br>ការិយាល័យជុំវិញស្រុក | | |

| | | | | | | |
|---|---|---|---|---|---|---|
| ១.៦ | ការប្រជុំផ្សព្វផ្សាយព័ត៌មានអំពីដំណើរការកសាងផែនការអភិវឌ្ឍស្រុក | សប្តាហ៍ទី៤ កុម្ភៈ ២០២០ | សាលាស្រុក | ក្រុមការងារកសាងផែនការ | | |
| **ជំហានទី២: ការរៀបចំសេចក្តីព្រាងផែនការអភិវឌ្ឍស្រុក** | | | | | | |
| ២.១ | ប្រជុំវិភាគស្ថានភាព និងរៀបចំសេចក្តីព្រាងក្របខណ្ឌអភិវឌ្ឍន៍ស្រុក | សប្តាហ៍ទី១ មីនា ២០២០ | សាលាស្រុក | .ក្រុមការងារកសាងផែនការ<br>ឃុំទាំង៨<br>ការិយាល័យជុំវិញស្រុក | | |
| ២.២ | ការពិនិត្យកែសម្រួល និងអនុម័តលើក្របខណ្ឌអភិវឌ្ឍស្រុក | សប្តាហ៍ទី២ មីនា ២០២០ | សាលាស្រុក | .ក្រុមការងារកសាងផែនការ | | |
| ២.៣ | ការរៀបចំក្របខណ្ឌចំណាយរយៈពេលមធ្យម | សប្តាហ៍ទី៣ មីនា ២០២០ | សាលាស្រុក | .ក្រុមការងារកសាងផែនការ | | |
| ២.៤ | ការរៀបចំក្របខណ្ឌតាមងាន គ្រួតពិនិត្យ និងវាយតម្លៃ | សប្តាហ៍ទី៤ មីនា ២០២០ | សាលាស្រុក | .ក្រុមការងារកសាងផែនការ | | |
| ២.៥ | ការរៀបចំសេចក្តីព្រាងផែនការអភិវឌ្ឍស្រុក | សប្តាហ៍ទី១ មេសា ២០២០ | សាលាស្រុក | .ក្រុមការងារកសាងផែនការ | | |
| ២.៦ | ការរៀបចំកិច្ចប្រជុំពិគ្រោះយោបល់លើសេចក្តីព្រាងផែនការអភិវឌ្ឍស្រុក | សប្តាហ៍ទី៣ មេសា ២០២០ | សាលាស្រុក | .ក្រុមការងារកសាងផែនការ | | |
| ២.៧ | ការពិនិត្យផ្តល់យោបល់របស់គណៈអភិបាល | សប្តាហ៍ទី៤ មេសា ២០២០ | សាលាស្រុក | គណៈអភិបាលស្រុក | | |
| ២.៨ | ការពិនិត្យ និងផ្តល់យោបល់របស់គណៈកម្មាធិការសម្របសម្រួលបច្ចេកទេស | សប្តាហ៍ទី១ ឧសភា ២០២០ | សាលាស្រុក | គណៈកម្មាធិការសម្របសម្រួលបច្ចេកទេស | | |
| **ជំហានទី៣: ការអនុម័តផែនការអភិវឌ្ឍស្រុក** | | | | | | |
| ៣.១ | ការអនុម័តផែនការអភិវឌ្ឍស្រុក | សប្តាហ៍ទី២ ឧសភា ២០២០ | សាលាស្រុក | ក្រុមប្រឹក្សាស្រុក | | |
| ៣.២ | ការផ្តល់អនុលោមភាពផែនការអភិវឌ្ឍស្រុក | សប្តាហ៍ទី៣ ឧសភា ២០២០ | សាលាស្រុក | គណៈអភិបាលស្រុក | | |

| | | | | | | |
|---|---|---|---|---|---|---|
| ៣.៤ | ការបោះពុម្ព និងផ្សព្វផ្សាយសៀវភៅផែនការអភិវឌ្ឍស្រុក | សប្តាហ៍ទី៤ ឧសភា ២០២០ | សាលាស្រុក | ក្រុមប្រឹក្សាស្រុក | | |

- ប្រតិទិនការងារកសាងផែនការខាងលើនេះ ត្រូវបានក្រុមប្រឹក្សាស្រុកកៀនស្វាយ អនុម័តក្នុងកិច្ចប្រជុំសាមញ្ញលើកទី.១៦.នាថ្ងៃព្រហស្បតិ៍.១៥រោចខែ.មិគសិរ..ឆ្នាំជូត ឯកស័ក ព.ស ២៥៦៤ ត្រូវនឹងថ្ងៃទី.៣១.ខែធ្នូ.ឆ្នាំ២០២០។

ថ្ងៃព្រហស្បតិ៍.១៥រោចខែ.មិគសិរ.ឆ្នាំជូត.....ឯកស័ក ព.ស ២៥៦៣

ត្រូវនឹងថ្ងៃទី.៣១.ខែធ្នូ.ឆ្នាំ២០២០

ជ.ក្រុមប្រឹក្សាស្រុក

ប្រធាន

[illegible]

ជា.ប៊ុនធឿន